ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Jul-2012, 15:28
CMS/CFO: Sann Rada

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២**

**ម៉ោង ០៩:០៦ នាទី**

**សវនាការលើកទី៧៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

លោក អេនឌ្រូ ចេមស៍ ម៉ាគីនថាយអឺរ
*(Andrew James MCINTYRE)*

លោក ស៊ីម៉ុន មេសិនប៊ឺដ
*(Mr. Simon MEISENBERG)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាវស្មី

កញ្ញា សុង ឆវ័ន្ត

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ(*Mr Jasper PAUW*)

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

(*Mr. Andrew IANUZZI*)

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

(*Mr. Arthur VERCKEN*)

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

(*Mr.Michael KARNAVAS*)

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

(*Ms. Elisabeth SIMONNEAU-FORT*)

លោកស្រី ទី ស្រ៊ីនណា

លោក វ៉ែន ពៅ

លោក ឡោ ជុនធី

លោក សំ សុគង់

លោក អូលីវីយ៉េ បាហ៊ូញ

(*Mr. Olivior BAHOUGNE*)

លោកស្រី គ្រីស្ទីន ម៉ាទីណូ

(*Ms. Chritine MARTINAU*)

លោកស្រី បេនី យេ (*Ms.Beini YE*)

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ច័ន្ទ តារាវស្មី | ខ្មែរ |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក ហ្សាស្ពើ ប៉ៅ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក អេនឌ្រូ អ៊ីន្ទូហ្វ៊ី | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ដេវីដ ឆេនដ៍ល័រ (TCE-11) | អង់គ្លេស |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅអ្នកជំនាញ៖ លោក ដេវីដ ឆេនដ័ល័រ** (TCE-11)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី៖........................................................................ទំព័រ ៩

សួរដោយលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ផ្តើមពី៖..................................................ទំព័រ១៦

សួរដោយលោក ច័ន្ទ តារាស្មី ផ្តើមពី៖ .....................................................................ទំព័រ៣៦

សួរដោយលោក អាប់ឌុលឡាក់ ថារីក ផ្តើមពី៖...............................................................ទំព័រ៨៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៦:៣៥]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការលើសំណុំរឿង០០២/០១។ ក្រឡាបញ្ជីសវនាការ លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាននិងអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមជម្រាបលោកប្រធាន! គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្តីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមបន្ទប់សវនាការ។ ជនជាប់ចោទ អៀង សារី តាមរយៈមេធាវីរបស់គាត់បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់សម្រាប់រយៈពេលពេញមួយថ្ងៃនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់គាត់បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ក្រឡាបញ្ជីកត់សម្គាល់ផងដែរ ពីវត្តមានរបស់លោកស្រី បេនីយេ ដែលជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយដែលមិនទាន់ត្រូវបានទទួលស្គាល់នៅចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេលកន្លងមកនៅឡើយ។

[០៩:០៨:៤៥]

ចំពោះអ្នកជំនាញដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះឈ្មោះ ដេវីដ ឆេនដ៍ល័រ *(David Chandler)*។ អ្នកជំនាញមានវត្តមាន រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ អ្នកជំនាញរូបនេះបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលបានទទួលស្គាល់នោះទេ។ អ្នកជំនាញរូបនេះនឹងធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

[០៩:០៩:២២]

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោក ផារី។ ឥឡូវនេះ អង្គជំនុំជម្រះជាបន្ត គឺពិនិត្យសម្រេចលើសំណើសុំរបស់ជនជាប់ចោទ អៀង សារី។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្ដីរបស់គាត់ ស្នើសុំលះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយគាត់សុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយមានមូលហេតុបញ្ហាសុខភាពមិនអាចអង្គុយតាមដានកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការដោយផ្ទាល់បាន។

[០៩:១០:១០]

អង្គជំនុំជម្រះបានឃើញអនុសាសន៍របស់វេជ្ជបណ្ឌិតទទួលបន្ទុកពិនិត្យ ថែទាំ ព្យាបាលជនជាប់ចោទនៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក បានផ្ដល់យោបល់ថា នៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ ជនជាប់ចោទ អៀង សារី គួរតែត្រូវបានទទួលការអនុញ្ញាតឱ្យនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ ដោយហេតុថា លោក អៀង សារី មានអាការៈហេវហត់ខ្លាំង នៅពេលគាត់ធ្វើចលនាបន្តិចបន្តិច ពេលឡើងរថយន្តដើម្បីមកកាន់បន្ទប់សវនាការនេះ។

[០៩:១០:៤៥]

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះជនជាប់ចោទ អៀង សារី បានសុំលះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់សវនាការដោយផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ និងក៏អាច-- គាត់អាចសម្រួលដល់ការទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីរបស់គាត់បានដែរ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់តាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ ឱ្យលោក អៀង សារី នៅតាមកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឱ្យផ្នែកខាងសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទ អៀង សារី

អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលនៃការធ្វើសវនាការពេញមួយថ្ងៃនេះ។

[០៩:១២:០៣]

អម្បាញ់មិញនេះ អង្គជំនុំជម្រះបានស្តាប់របាយការណ៍របស់ក្រឡាបញ្ជីសវនាការ បានកត់សម្គាល់ឃើញថា មានវត្តមានមេធាវីតំណាង-- មេធាវីអន្តរជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានវត្តមាននៅក្នុងសាលសវនាការនេះ ហើយមេធាវីរូបនោះមិនទាន់បានទទួលស្គាល់តាមវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះនៅឡើយ។ ហើយជាបន្តនេះ អង្គជំនុំជម្រះត្រូវបំពេញកិច្ចនីតិវិធីទទួលស្គាល់មេធាវីអន្តរ-ជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីរូបនេះជាមុនសិន មុននឹងចាប់ផ្តើមដំណើរការនីតិវិធីពិភាក្សាដេញដោលស្តាប់សក្ខីកម្មអ្នកជំនាញ ដេវីដ ឆេនដ័ល័រ។ ដោយអនុលោមតាមវិធាន២២(២)(ក) នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះសូមអញ្ជើញលោក ពេជ អង្គ ជាមេធាវីជាតិ នៃសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឡើងធ្វើការស្នើសុំការទទួលស្គាល់មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានវត្តមាននៅក្នុងសាលសវនាការនេះ។

សូមអញ្ជើញ!

[០៩:១៣:១៧]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន សូមលោកគោរពលោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល។ ថ្ងៃនេះ នៅឆ្វេងនិងខាងក្រោយខ្ញុំនេះ មានវត្តមានរបស់លោកស្រីមេធាវីបរទេសមួយរូប ដែលមានឈ្មោះ បេនីយេ ដែលជាមេធាវីដែលមានសញ្ជាតិអូទ្រីស ហើយជាសមាជិកនៃគណៈមេធាវីនៅអាល្លឺម៉ង់។ ហើយពេលនេះលោកស្រី តំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាកូនក្តីចំនួន៩៥នាក់ ជាមួយលោកស្រី ស៊ីន សុវ៉ន ដែលជាមេធាវីជាតិ លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី ដែលជាមេធាវីបរទេស។ ឯកសារតំណាងកូនក្តីបានបញ្ជូនទៅក្រឡាបញ្ជីរបស់អង្គជំនុំជម្រះរួចហើយ ដោយអង្គភាពគាំពារជនរងគ្រោះ។

លោកស្រីត្រូវបានក្រុមប្រឹក្សាគណៈមេធាវីយល់ព្រមឲ្យចុះបញ្ជីក្នុងបញ្ជីមេធាវីបរទេសរួចហើយនៅថ្ងៃទី១១ ឧសភា ឆ្នាំ២០១២ និងបានធ្វើសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍រួចហើយ នៅថ្ងៃទី៣០ ឧសភា ឆ្នាំ២០១២ នេះ។ អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាអនុញ្ញាតទទួលស្គាល់លោកស្រី បេនីយេ ដែលជាមេធាវីអន្តរជាតិមានសិទ្ធិពេញលេញ នៅក្នុងការតំណាងកូនក្តីរបស់ខ្លួន

នៅចំពោះមុខអង្គជំនុំជម្រះនេះ។ សូមអរគុណលោកប្រធាន។

[០៩:១៤:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោកស្រី បេនីយេ អង្គជំនុំជម្រះសាលាទទួលលោកស្រីជាមេធាវីអន្តរជាតិតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី សម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងសម្រាប់សំណុំរឿង០០២នេះ។ អនុលោមតាមការទទួលស្គាល់នេះ លោកស្រីមានសិទ្ធិបុព្វសិទ្ធិដូចគ្នានឹងមេធាវីជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែរ។

សូមអង្គុយចុះ!

[០៩:១៥:១៥]

អង្គជំនុំជម្រះក៏មុននឹងផ្ដើមដំណើរការសួរ ស្ដាប់សក្ខីកម្មអ្នកជំនាញ សូមជម្រាបជូនសាធារណជន និងភាគីបានជ្រាបផងដែរថា កាលវិភាគសវនាការដែលបានគ្រោងទុកនៅក្នុងសប្ដាហ៍នេះ ចាប់ពីថ្ងៃចន្ទ ទី១៦ ខែកក្កដា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងអញ្ជើញអ្នកជំនាញ ដាវីដ ឆេនដ៍ល័រ ដែលជាអ្នកជំនាញអន្តរជាតិមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងវិសាលភាពនៃអង្គហេតុសំណុំរឿង០០២ទាំងមូល តែអង្គជំនុំជម្រះសាលាដំបូងមានការសោកស្ដាយយ៉ាងខ្លាំងចំពោះការខកខាននៅក្នុងរយៈពេលពីរថ្ងៃកន្លងមកនេះ ដែលមិនអាចចាប់ផ្ដើមសវនាការទៅតាមកាលវិភាគដែលបានគ្រោងទុកនៅក្នុងការស្ដាប់សក្ខីកម្មអ្នកជំនាញ ដាវីដ ឆេនដ៍ល័រ ឬជាជម្រើសម្យ៉ាងទៀតស្ដាប់សក្ខីកម្មសាក្សីណាមួយរូបផ្សេងទៀត ជំនួសអ្នកជំនាញរូបនេះ។ ការខកខាននេះគឺមួយផ្នែកជាប់ពាក់ព័ន្ធទៅនឹងការមិនមានលទ្ធភាពរបស់ភាគីសហព្រះរាជអាជ្ញា ដោយសហព្រះរាជអាជ្ញារងអន្តរជាតិមួយរូបដែលទទួលបន្ទុកការសួរដេញដោលអ្នកជំនាញ ដាវីដ ឆេនដ៍ល័រ មានបញ្ហាសុខភាព។

[០៩:១៦:៣២]

អង្គជំនុំជម្រះសាលាដំបូងសូមរម្លឹកដល់ភាគីទាំងអស់នៃរឿងក្ដីនេះថា ភាគីត្រូវតែត្រៀមខ្លួនគ្រប់គ្រាន់ និងឲ្យរួចរាល់ក្នុងការសួរដេញដោលសាក្សី អ្នកជំនាញ ឬដើមបណ្ដឹងរដ្ឋប្បវេណី ទោះបីសាក្សីអ្នកជំនាញ ដើមបណ្ដឹងរដ្ឋប្បវេណីទាំងនោះមិនស្ថិតនៅក្នុងលំដាប់លំដោយដូចដែលបានកំណត់ក៏ដោយ។ ការធ្វើដូច្នេះ គឺមានសារសំខាន់ណាស់សម្រាប់អង្គជំនុំជម្រះសាលាដំបូងធ្វើសវនាការតាមកាលវិភាគដែលបានគ្រោងទុក និងអាចចៀសវាងបាននូវរាល់ការអាក់ខានផ្សេងៗដែលមិនចាំបាច់។

ហើយទន្ទឹមនេះដែរ អង្គជំនុំជម្រះ ប្រកាសនូវសេចក្តីសម្រេចផ្ទាល់មាត់ទៅលើសំណើសុំចំនួនពីរ ដែលធ្វើឡើង ទីមួយ គឺសំណើសុំដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ហើយនិងទីពីរគឺធ្វើឡើងដោយ ក្រុមមេធាវីការពារក្តីឲ្យលោក នួន ជា ដូចខាងក្រោមនេះ៖

[០៩:១៧:៣៩]

សេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំរបស់សហព្រះរាជអាជ្ញា ឯកសារ E126 តាមរយៈ សំណើសុំរបស់ខ្លួន E126 សហព្រះរាជអាជ្ញាបានស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូង ដើម្បីដាក់ ឯកសារចំនួនពីរនៅចំពោះមុខអង្គជំនុំជម្រះ និងសុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីប្រើប្រាស់ឯកសារ នេះក្នុងអំឡុងពេលសួរដេញដោលសាក្សី TCW-694។ នៅក្នុងសេចក្តីសម្រេចដែលបានចេញកាលពី ពេលមុន សេចក្តីសម្រេច E142/3 និង E96/7 អង្គជំនុំជម្រះធ្លាប់បានបញ្ជាក់ថា កំណត់ហេតុស្តាប់ ចម្លើយនានាកាលពីពេលមុន ដែលសាក្សីរូបនោះនឹងមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ អាចត្រូវ បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

[០៩:១៨:៣៦]

ឯកសារទាំងពីរដែលសហព្រះរាជអាជ្ញាបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនេះ ត្រូវបាន ប្រើប្រាស់ដោយសហចៅក្រមស៊ើបអង្កេតក្នុងអំឡុងពេលនៃការធ្វើសម្ភាសជាមួយសាក្សី។ ឯកសារ ដែលមានលេខ D154.2 និង D154.3 គឺជាផ្នែកមួយនៃកិច្ចសម្ភាសន៍របស់សាក្សី TCW-694 កាលពី ពេលមុន។ ហេតុដូច្នេះ ឯកសារនេះ អាចដាក់នៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមលក្ខណៈ វិនិច្ឆ័យនៃវិធាន៨៧ អនុវិធាន៣ នៃវិធានផ្ទៃក្នុង។

នៅក្នុងសំណើដដែលនេះដែរ សហព្រះរាជអាជ្ញាបានស្នើសុំបន្ថែមទៀតដល់អង្គជំនុំជម្រះបង្គាប់ ទៅសាក្សី ឬការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីផ្តល់ផ្នែកពាក់ព័ន្ធផ្សេងទៀតនៃឯកសារ។ អង្គជំនុំជម្រះនឹងចេញសេចក្តីណែនាំទាក់ទងនឹងបញ្ហានេះក្នុងពេលវេលាសមស្របខាងមុខ។

នេះជាសេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំរបស់សហព្រះរាជអាជ្ញា ឯកសារ E126។

ជាបន្តនេះជាសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះ ទៅលើសំណើសុំរបស់ក្រុមមេធាវី ការពារក្តីឲ្យលោក នួន ជា ឯកសារ E172/27/1។

[០៩:២០:០៦]

អង្គជំនុំជម្រះសាលាដំបូងទទួលសំណើពីក្រុមមេធាវីការពារក្តីលោក នួន ជា សុំប្រើប្រាស់

ឯកសារចំនួន២០ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីមានឱកាសប្រើប្រាស់ឯកសារនេះក្នុងអំឡុងពេលសួរដេញដោលអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ស្របតាមវិធាន៨៧ អនុវិធាន៣ និងអនុវិធាន៤ ក្នុងគោលបំណងធ្វើតេស្តអំពីភាពគួរឲ្យជឿជាក់បាននៃអ្នកជំនាញរូបនេះ។

នៅក្នុងចំណោមឯកសារចំនួនបី ដែលនៅក្នុងឧបសម្ព័ន្ធ-- នៅក្នុងបញ្ជីឧបសម្ព័ន្ធ គឺជាឯកសារចំណុច A ដល់ C ដែលមាននៅក្នុងសំណុំរឿងនោះ មានតែឯកសារចំណុច A ប៉ុណ្ណោះ ដែលមាននៅក្នុងបញ្ជីឯកសារ ដែលស្នើឡើងដោយភាគីផ្សេងទៀត។ ដូច្នេះ ឯកសារចំណុច A នេះអាចត្រូវបានប្រើនៅក្នុងសវនាការ និងមិនចាំបាច់ស្ថិតនៅក្រោមសំណើ ដែលធ្វើឡើងតាមវិធាន៨៧(៤) នោះទេ។

[០៩:២១:១២]

ឯកសារផ្សេងទៀតនៅក្នុងបញ្ជីឧបសម្ព័ន្ធនេះ ពីចំណុច D ដល់ចំណុច T មិនមាននៅក្នុងសំណុំរឿងទេ។

កន្លងមកអង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់នៅក្នុងអនុស្សរណៈរបស់ខ្លួន ឯកសារ E199 ថា ឯកសារណាមួយដែលភាគីមានបំណងប្រើប្រាស់នៅចំពោះមុខអង្គជំនុំជម្រះ ហើយឯកសារនោះពុំទាន់ទទួលបានចំណាត់ថ្នាក់ជាឯកសារ E3 ឬមិនត្រូវបានលើកឡើងនៅក្នុងបញ្ជីឯកសារណាមួយដែលត្រូវបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះត្រូវបំពេញលក្ខខណ្ឌតម្រូវនៃវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង។

អង្គជំនុំជម្រះបានបញ្ជាក់នាពេលកន្លងមកដែរថា អនុលោមតាមគោលការស្តីពីការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលត្រូវបានទទួលស្គាល់លក្ខខណ្ឌអប្បបរមាសម្រាប់ការសំអាងទៅលើឯកសារមួយនៅសវនាការដែលឯកសារនោះពុំស្ថិតនៅចំពោះមុខអង្គជំនុំជម្រះនៅឡើយ ឬត្រូវបានស្នើសុំឲ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះ គឺជាបញ្ហាពាក់ព័ន្ធទៅនឹងពេលវេលានៃការដាក់ឯកសារនៅក្នុងសំណុំរឿង និង/ឬស្នើសុំការទទួលយកឯកសារនេះ ដោយអនុលោមតាមវិធាននេះ។

[០៩:២២:៣៧]

គួរបញ្ជាក់ផងដែរថា ឯកសារភាគច្រើនដែលស្នើឡើងដោយក្រុមមេធាវីការពារក្តី នួន ជា នៅក្នុងឯកសារ E172/27/1 មិនមានជាភាសាខ្មែរ ឬភាសាបារាំងទេ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថាភាគច្រើននៃឯកសារក្នុងបញ្ជីដែលត្រូវបានស្នើឡើងសម្រាប់ការសួរដេញដោលអ្នកជំនាញ ដេវីដ ឆេនដ៍ល័រនេះ គឺជាការបោះពុម្ពផ្សាយ ដែលនិពន្ធឡើងដោយអ្នកជំនាញរូបនេះតែម្តង ឬក្នុងនាមគាត់ជាអ្នកផ្តល់បទសម្ភាសន៍ ហើយឯកសារទាំងនេះមានកាលបរិច្ឆេទចាប់តាំងពីឆ្នាំ១៩៧៩ មក រហូតដល់ ខែមីនា

ឆ្នាំ២០១២។

[០៩:២៣:២១]

អង្គជំនុំជម្រះបានគ្រោងពេលវេលាស្តាប់សក្ខីកម្មសាក្សីអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ នៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១២។ ឯកសារ E172/24។ ដូច្នេះ សំណើសុំរបស់ក្រុមការពារក្តីឲ្យលោក នួន ជា មិនអាចត្រូវបានពិចារណាថាធ្វើឡើងដោយទាន់ពេលវេលាស្របតាមការសម្រេចរបស់អង្គជំនុំជម្រះ នៅក្នុងអនុស្សរណ: E199 ឡើយ។ លើសពីនេះទៀត ក្រុមមេធាវីការពារក្តីនួន ជា មិនបានពន្យល់ឲ្យបានលម្អិតគ្រប់គ្រាន់អំពីពេលវេលាណា និងដោយមធ្យោបាយអ្វី ដែលខ្លួនរកបានឯកសារទាំងនេះ ដោយហេតុនេះហើយ អង្គជំនុំជម្រះមិនអាចធ្វើការវិភាគដឹងបានអំពីកិច្ចប្រឹងប្រែងក្នុងការទទួលបានឯកសារទាំងនេះ ថាតើត្រូវបានធ្វើឡើងកាលពីដើមដំបូងមក ឬយ៉ាងណានោះទេ។

ហេតុដូច្នេះ ក្រុមមេធាវីការពារក្តី នួន ជា មិនបានបំពេញតាមតម្រូវការនៃវិធាន -- តាមការតម្រូវនៃវិធាន៨៧(៤) ឡើយ។ អង្គជំនុំជម្រះបដិសេធសំណើសុំរបស់ក្រុមមេធាវីការពារក្តីលោក នួន ជា ទៅលើការប្រើប្រាស់ឯកសារពីចំណុច B ដល់ចំណុច T។

នេះចាត់ទុកជាសេចក្តីសម្រេចជាផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះសំណើសុំរបស់ក្រុមមេធាវីការពារក្តី នួន ជា ឯកសារ E172/27/1 ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១២។

បាទ ជាកិច្ចបន្ត អង្គជំនុំជម្រះបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ចូលមកកាន់ទីកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(អ្នកជំនាញចូលមកក្នុងបន្ទប់សវនាការ)*

[០៩:២៥:៤៩]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមគោរពលោកប្រធាន ខ្ញុំគិតថា ខ្ញុំត្រូវតែធ្វើការជំទាស់នៅក្នុងប្រតិចារិកទាក់ទងទៅនឹងសេចក្តីសម្រេចរបស់លោកប្រធាន។ ឯកសារនៅក្នុងបញ្ជីនោះ វាពាក់ព័ន្ធទៅនឹងលោក ដេវីដ ឆេនដ៍ល័រ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចរួចហើយ ហើយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ការតវ៉ា គឺធ្វើបណ្តឹងសាទុក្ខទៅតុលាការជាន់ខ្ពស់។ អង្គជំនុំជម្រះគ្មានភារកិច្ចក្នុងការពិនិត្យនូវសេចក្តីសម្រេចរបស់ខ្លួនទេ។ ដូច្នេះ អង្គជំនុំជម្រះមិនអនុញ្ញាតឡើយ។ នេះជាសេចក្តីសម្រេច។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

គឺនេះជាអ្វីដែលខ្ញុំត្រូវតែ -- ត្រូវនឹងអ្វីដែលខ្ញុំធ្វើហើយ គឺខ្ញុំត្រូវតែបញ្ជាក់ថា ខ្ញុំនឹងដាក់ពាក្យសុំប្តឹងសាទុក្ខ។

[០៩:២៦:៣៩]

**ប្រធានអង្គជំនុំ៖**

យើងនឹងមិនអនុញ្ញាតទេ ប្តឹងសាទុក្ខជាសិទ្ធិរបស់លោក។ លោកធ្វើបណ្តឹងសាទុក្ខតាមវិធានទាំងឡាយដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង អនុវត្តនៅ អ.វ.ត.ក ជាការស្រេចហើយ។

សូមអញ្ជើញលោកមេធាវី កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម។ អរុណសួស្តីអស់លោក លោកស្រី នៅក្នុងបន្ទប់សវនាការ និងជុំវិញបន្ទប់សវនាការ។ ប្រហែលយើងគិតថា មេធាវី នួន ជា គួរតែមានឱកាសក្នុងការបង្ហាញនូវយោបល់ខ្លីរបស់ខ្លួន ពាក់ព័ន្ធទៅនឹងពាក្យសុំប្តឹងសារទុក្ខ។ ចំណុចនេះ--

[០៩:២៧:២៥]

**ប្រធានអង្គជំនុំ៖**

នេះជារឿងរបស់មេធាវីការពារក្តី នួន ជា ទេ។ លោកមិនមានសិទ្ធិមកឆ្លៀតឱកាសក្នុងការធ្វើសេចក្តីថ្លែងការណ៍ពាក់ព័ន្ធនឹងបញ្ហានេះទេ។ មិនមែនជារឿងរបស់លោកទេ។ អង្គជំនុំជម្រះមិនអនុញ្ញាតឱ្យលោកធ្វើដូច្នេះទេ។

យើងបានសម្រេចរួចហើយ យើងមិនកែប្រែនូវសេចក្តីសម្រេចរបស់យើងទេ។

អញ្ជើញអង្គុយចុះ!

មានបញ្ហាអីផ្សេងថ្មីទេ?

[០៩:២៨:២៦]

**លោក អាកឡូរ វែកកែន៖**

បាទ លោកប្រធាន ខ្ញុំយល់ឃើញថា ជាសារៈសំខាន់ណាស់ ក្នុងការនិយាយ ដែលថាបញ្ហាដែលលើកដោយភាគីការពារក្តី អាចទាក់ទងទៅនឹងការ -- ក្រុមការពារក្តីទាំងអស់។ ដូច្នេះ ខ្ញុំគិតថា ជាការសមហេតុផល ដែលថាអនុញ្ញាតឱ្យបញ្ចេញមតិ--

**ប្រធានអង្គជំនុំ៖**

យើងកំណត់រួចហើយ។

[០៩:២៨:៥៣]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្តី លោក ដេវីដ ឆេនដ័ល័រ។ ឥឡូវនេះ មិននឹងដំណើរការពិភាក្សាដេញដោលចំពោះលោក ក្នុងនាមជាអ្នកជំនាញ ខ្ញុំសូមធ្វើការសួរសំណួរមួយចំនួនពាក់ព័ន្ធនឹងជីវប្រវត្តិរបស់លោកជាមុនសិន។ លោក ដេវីដ ឆេនដ័ល័រ តើលោកអាចប្រាប់ដល់អង្គជំនុំជម្រះបានទេ អំពីនាមត្រកូល និងនាមខ្លួនពេញលេញរបស់លោក?

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** ខ្ញុំឈ្មោះ ដេវីដ ហ្វរិច ឆេនដ័ល័រ។

**ស៖** បាទអរគុណ។ តើលោកមានអាយុប៉ុន្មាន?

**ឆ៖** ខ្ញុំមានអាយុ ៧៩ឆ្នាំ។

**ស៖** បាទ អរគុណ។ តើលោកមានសញ្ជាតិអ្វីដែរ?

**ឆ៖** ខ្ញុំមានលិខិតឆ្លងដែនចំនួនពីរ។ ទីមួយ គឺលិខិតឆ្លងដែនជនជាតិអូស្ត្រាលី និងលិខិតឆ្លងដែនជនជាតិអាមេរិក។

[០៩:៣០:០៤]

**ស៖** បាទអរគុណ។ តើសព្វថ្ងៃហ្នឹងលោករស់នៅទីកន្លែងណា?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** ម្តងទៀត អំមិញមិនទាន់មាន -- ក្បាលមីក្រូអត់ទាន់ប្រតិបត្តិការ។ សូមលោកអ្នកជំនាញបង្អង់បន្តិចដើម្បីឲ្យក្បាលមីក្រូប្រតិបត្តិការគឺដោយភ្លើង សញ្ញាភ្លើងក្រហមជាមុនសិនបាទ។

**ឆ៖** ខ្ញុំរស់នៅក្នុងទីក្រុងមែលប៊នប្រទេសអូស្រាលី។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

[០៩:៣០:៤៩]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ដើម្បីជាប្រយោជន៍របស់លោក មីក្រូហ្វូនរបស់លោកហ្នឹងគឺគេនឹងបើកឲ្យលោកពីចម្ងាយតែម្ដង លោកមិនចាំបាច់បើកដោយផ្ទាល់ខ្លួននោះទេ។ លោកគ្រាន់តែចាំរង់ -- គ្រាន់តែរង់ចាំមើលសញ្ញាភ្លើងពណ៌ក្រហមបានហើយ។

**លោក ដេវីដ ឆេនដ៍ល័រ៖**

បាទ សូមអរគុណច្រើនលោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីចៅក្រម!

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកអ្នកជំនាញ តើលោកប្រកបមុខរបរអ្វីដែរសព្វថ្ងៃនេះ?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំចូលនិវត្តន៍ ប៉ុន្តែជាសាស្ត្រាចារ្យប្រវត្តិសាស្ត្រនៅម៉ែលប៊ន ប្រទេសអូស្ត្រាលី។

[០៩:៣១:៣៣]

**ស៖** បាទ អរគុណ។ តើលោកមានចំណងទាក់ទងជាញាតិលោហិត ឬញាតិពន្ធជាមួយនឹងភាគីណាមួយនៃរឿងក្ដីនេះដែរឬទេ?

**ឆ៖** ទេ ខ្ញុំមិនមានទេ។

**ស៖** ដោយផ្អែកតាមវិធាន៣១ អនុវិធាន២ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លោក ដេវីដ ឆេនដ៍ល័រ ក្នុងនាមលោកជាអ្នកជំនាញដែលត្រូវផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនាពេលនេះ អង្គជំនុំជម្រះតម្រូវឲ្យលោកធ្វើសម្បថជាមុនសិនមុននឹងផ្ដល់សក្ខីកម្ម។ តើលោកយល់ព្រមដែរឬទេ?

**ឆ៖** ខ្ញុំយល់ព្រមបាទ។

[០៩:៣២:២៨]

**ប្រធានអង្គជំនុំ៖**

បង្គាប់ឲ្យក្រឡាបញ្ជីអន្តរជាតិលោក អេនឌ្រូ រៀបចំនីតិវិធី និងណែនាំលោក ដេវីដ ឆេនដ៍ល័រ ធ្វើសម្បថ!

**ក្រឡាបញ្ជី៖**

លោកសាស្ត្រាចារ្យ ឆេនដ័ល័រ សូមអានតាមខ្ញុំ។ ខ្ញុំសូមប្រកាសថា "ខ្ញុំនឹងផ្តល់ជំនួយដល់អង្គជំនុំជម្រះសាលាដំបូងដោយស្មោះត្រង់ រក្សាការសម្ងាត់និងខំប្រឹងប្រែងអស់ពីសមត្ថភាព។"

**លោក ដេវីដ ឆេនដ័ល័រ៖**

ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំនឹងផ្តល់ជំនួយដល់អង្គជំនុំជម្រះដោយស្មោះត្រង់ រក្សាការសម្ងាត់និងខំប្រឹងប្រែងអស់ពីសមត្ថភាព។

[០៩:៣៣:០៧]

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។

បាទ ឥឡូវនេះអ្នកជំនាញបានធ្វើសម្បថរួចហើយ ហើយអង្គជំនុំជម្រះនឹងមានសំណួរមួយចំនួនពាក់ព័ន្ធនឹងលោកក្នុងនាមជាអ្នកជំនាញ។ ហើយជាបឋមនេះ លោក ដេវីដ ឆេនដ័ល័រ អង្គជំនុំជម្រះសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកដែលបានធ្វើដំណើរពីចម្ងាយមកកាន់ អ.វ.ត.ក តាមការអញ្ជើញរបស់អង្គជំនុំជម្រះ ដើម្បីផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញ និងរួមវិភាគទានយ៉ាងសំខាន់ដល់អង្គជំនុំជម្រះក្នុងការលាតត្រដាងក្នុងការស្វែងរកការពិតនូវរឿងក្តីនេះ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក ដេវីដ ឆេនដ័ល័រ តើលោកអាចប្រាប់អំពីប្រវត្តិនៃការសិក្សារបស់លោកនៅកម្រិតថ្នាក់មហាវិទ្យាល័យបានដែរឬទេ?

[០៩:៣៣:៥៨]

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** ខ្ញុំទទួលការអប់រំនៅវិទ្យាល័យហាវើដ ហើយនៅសាកលវិទ្យាល័យមីឈីហ្គេន សហរដ្ឋអាមេរិក។

**ស៖** បាទ អរគុណ។ ហើយតើលោកប្រកមុខរបរវិជ្ជាជីវៈជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យមុននឹងចូលនិវត្តន៍អស់រយៈពេលប៉ុន្មានឆ្នាំដែរ?

**ឆ៖** ចាប់ពីឆ្នាំ១៩៧២ ដល់១៩៩៧ គឺ២៥ឆ្នាំ (ស៊ីក)។

**សៈ** បាទ អរគុណ។ ហើយតើលោកចេះភាសាខ្មែរដែរឬទេ? ចេះស្ដាប់ និយាយ អាន សរសេរជាដើម។

**ឆៈ** ខ្ញុំចេះនិយាយភាសាខ្មែរ និយាយ ប៉ុន្តែសរសេរខ្ញុំមិនសរសេរបានល្អទេ។

**សៈ** បាទ អរគុណ។ តើលោកធ្លាប់បានសិក្សាអំពីប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ជាពិសេសទាក់ទងនឹងប្រវត្តិសាស្ត្ររបស់ប្រទេសនេះ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺអំឡុងពេលចាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដល់០៦ មករា ឆ្នាំ១៩៧៩ ដែរឬទេ?

**ឆៈ** បាទ ខ្ញុំបានធ្វើការសិក្សាជាផ្នែកនៃវិជ្ជាជីវៈរបស់ខ្ញុំ គឺចាប់តាំងពីដំបូងមក ខ្ញុំបានសិក្សាសម័យខ្មែរក្រហម។ ភាគច្រើននៅពេលដែលវាចាប់ផ្ដើម គឺតាំងពីឆ្នាំ១៩៧៥ រហូតមកដល់ថ្ងៃបច្ចុប្បន្ននេះ។

**សៈ** បាទអរគុណ។ តើលោកធ្លាប់បានសរសេរសៀវភៅអំពីរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

[០៩:៣៥:៥៧]

**ឆៈ** ខ្ញុំបានបញ្ជាក់នៅក្នុងសៀវភៅស្ដីពីប្រវត្តិប្រទេសកម្ពុជា គឺពីឆ្នាំ២០០៧មក។ នៅក្នុងសៀវភៅឆ្នាំ១៩៩២ គឺ "សោកនាដកម្មកម្ពុជា" គឺឆ្នាំ១៩៩១ ហើយឆ្នាំ១៩៩២ ខ្ញុំបាននិយាយ សរសេរសៀវភៅ "បងទី១ ប៉ុល ពត" នោះ ១៩៩៨ គឺសៀវភៅមួយ គឺ "សំឡេងពីស-២១" និយាយអំពីគុកនៅទួលស្លែង។

**សៈ** បាទអរគុណ។ ហើយក្រៅពីនេះ តើលោកមានបានសរសេរនូវអត្ថបទផ្សេងទៀតដែលអំពីកម្ពុជាប្រជាធិបតេយ្យ និងរបបកម្ពុជាប្រជាធិបតេយ្យ នៅមហាវិទ្យាល័យដែលលោកបង្រៀនដែរឬទេ?

**ឆៈ** បាទ ខ្ញុំបានសរសេរអត្ថបទជាច្រើន ខ្ញុំអាចបញ្ជាក់គឺ ឆ្នាំ១៩៩០ គឺថាទិដ្ឋភាពជាច្រើននៃប្រវត្តិសាស្ត្រកម្ពុជា រហូតមកដល់នោះ គឺថាខ្ញុំបានសរសេរភាគច្រើន។

**សៈ** បាទ អរគុណ។ តើហេតុអ្វីបានជាលោកមានចំណាប់អារម្មណ៍លើការសិក្សាអំពីប្រវត្តិ-សាស្ត្ររបស់ប្រទេសកម្ពុជា ហើយជាពិសេសលើរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆៈ** ខ្ញុំចាប់អារម្មណ៍ប្រទេសកម្ពុជា គឺតាំងពីឆ្នាំ១៩៦០ នៅពេលដែលខ្ញុំបានធ្វើការជាមន្ត្រីការទូតក្មេងនៅស្ថានទូតអាមេរិក ហើយខ្ញុំបានរៀនភាសាខ្មែរ។ ក្នុងពីរឆ្នាំនោះ ខ្ញុំបាននៅកម្ពុជា ជាពិសេសដែលធ្វើឲ្យជីវិតខ្ញុំការកែប្រែ នៅពេលដែលខ្ញុំឈប់ពីក្រសួងការបរទេសនោះ ខ្ញុំយកអាជីពជាបណ្ឌិតនោះ គឺខ្ញុំបានសម្រេចយកការសិក្សា និងពីប្រវត្តិសាស្ត្រកម្ពុជា ហើយខ្ញុំចាប់ផ្ដើមតាំងពីមុនសម័យ

អាណានិគមកម្ពុជាមកម្ល៉េះ។ នេះគឺជា ខ្ញុំបានធ្វើនិក្ខេបបទអំពីកិច្ចការនេះ ហើយខ្ញុំបានប្តូរទៅការសិក្សាពីប្រវត្តិសាស្ត្រសម័យទំនើបរបស់កម្ពុជាបន្តមក បន្ទាប់ពីខ្មែរក្រហមចូលកាន់អំណាចមកនោះ។

[០៩:៣៨:៣៤]

**ស៖** បាទ អរគុណ។ ហើយខ្ញុំសំណួរមួយចំនួនទាក់ទងទៅនឹងសៀវភៅចំនួនបួនក្នុងចំណោមសៀវភៅផ្សេងៗទៀតដែលលោកបានសរសេរនិងបោះពុម្ពផ្សាយ។ សៀវភៅទីមួយដែលមានចំណងជើងថា "សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា" ដែលនិយាយអំពីនយោបាយសង្គ្រាម និងបដិវត្តន៍តាំងពីឆ្នាំ១៩៤៥ ដែលមានឯកសារ D108/50/6.75 តើលោកអាចប្រាប់បានឬទេថា តើលោកជាប់ផ្តើមធ្វើការស្រាវជ្រាវ ដើម្បីសរសេរសៀវភៅនេះចាប់ពីពេលណាមក? ហើយតើសៀវភៅនេះចាប់ផ្តើមបោះពុម្ពនៅពេលណា? តើលោកមានបានកែប្រែ និងបោះពុម្ពសៀវភៅនេះសាឡើងវិញដែរឬទេ?

**ឆ៖** សូមអរគុណ។ ខ្ញុំបានចាប់ផ្តើមលើសៀវភៅនេះ ឆ្នាំ១៩៨៥ បោះពុម្ពនៅឆ្នាំ១៩៩១ ហើយកែប្រែឡើងវិញ គឺនៅក្នុងឆ្នាំ១៩៩២។ ប៉ុន្តែខ្ញុំមិនបានកែសម្រួលឡើងវិញទេ ចាប់ពីឆ្នាំ៩២ មកនោះ។

**ស៖** ចុះសៀវភៅបន្ទាប់ ដែលមានចំណងជើងថា "ប៉ុល ពត រៀបចំផែនការសម្រាប់ពេលអនាគត" ដែលនិយាយអំពីឯកសារសម្ងាត់របស់កម្ពុជាប្រជាធិបតេយ្យ ឯកសារ IS6.4 តើសៀវភៅនេះលោកត្រូវបានសរសេរឡើងដោយមានសហការជាមួយនឹង ប៉ែន ឃៀវនិន និង ប៊ួ ចន្ធូ មែនដែរឬទេ? ហើយតើសៀវភៅនេះត្រូវបានសរសេរឡើងដោយផ្អែកលើឯកសារមួយចំនួនដែលលោកមាន ហើយឯកសារទាំងនោះត្រូវបានសរសេរឡើងក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសចន្លោះពីឆ្នាំ១៩៧៦ ដល់ ឆ្នាំ១៩៧៧ ថាតើពិតមែនដែរឬទេ?

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំបាននិពន្ធរួមគ្នាជាមួយ ប៉ែន ឃៀវនិន ហើយនិង ចន្ធូ ប៊ួ ហើយខ្ញុំបានពិនិត្យមើលការបកប្រែដោយខ្លួនឯង ហើយគាត់បានពិនិត្យផងដែរ។ ហើយផ្នែកខ្លះនៃសៀវភៅនោះត្រូវបានសរសេររួមគ្នា ហើយខ្ញុំបានឯកសារ -- អានឯកសារច្រើនដែលទាក់ទងទៅនឹងខ្លឹមសារនៃសៀវភៅនេះ។ ខ្ញុំគិតថាសៀវភៅនេះបានសរសេរឆ្នាំ១៩៨៤, ១៩៨៧ ហើយបោះពុម្ពនៅឆ្នាំ១៩៨០ (ស៊ីក)។

**អ្នកបកប្រែ៖**

បាទ បោះពុម្ពនៅឆ្នាំ១៩៩៨ សូមកែតម្រូវបាទ។

[០៩:៤១:១៨]

**សៈ** បាទ អរគុណ។ ហើយសៀវភៅទីបីដែលជាសៀវភៅមួយមានភាពល្បីល្បាញដែលមានចំណងជើងថា "បងទី១", ជីវប្រវត្តិនយោបាយរបស់ ប៉ុល ពត ឯកសារលេខ E3/17។ តើលោកចាប់ផ្ដើមធ្វើការសិក្សាស្រាវជ្រាវអំពីសៀវភៅនេះពីពេលណាមក? ហើយថាតើលោកបានធ្វើបច្ចុប្បន្នភាព ឬកែសម្រួលសៀវភៅនេះដែរឬទេ?

**ឆៈ** សូមអរគុណ។ ខ្ញុំគិតថា ខ្ញុំបានចាប់ផ្ដើមធ្វើការងារលើសៀវភៅនេះប្រហែលជានៅក្នុងពេលនៅចុងឆ្នាំ១៩៨៧ ខ្ញុំបានសរសេរ ហើយស្របជាមួយនឹងសៀវភៅស្ដីពី "សោកនាដកម្មកម្ពុជា" បោះពុម្ពទី១ នោះគឺនៅឆ្នាំ១៩៩២ ហើយបន្ទាប់មកនៅឆ្នាំ១៩៩៩ ខ្ញុំបានរៀបចំការកែសម្រួលដែលនិយាយអំពីហេតុការណ៍ទាក់ទងទៅនឹងការស្លាប់របស់ ប៉ុល ពត ហើយបានកែសម្រួលផ្នែកខ្លះពីខាងដើម។ ហើយខ្ញុំមិនបាន -- នេះជាច្បាប់ចុងក្រោយនៃសៀវភៅនេះ ហើយអង្គហេតុផ្សេងៗដែលជាប្រវត្តិរូបរបស់ ហ៊្វលីព ស្សូត ហ្នឹងគឺខ្ញុំមិនទាន់មានទេនៅពេលនោះ។

[០៩:៤២:៥៤]

**សៈ** បាទ អរគុណ។ នៅក្នុងសៀវភៅនិពន្ធរបស់លោកដែលមានចំណងជើងថា "សំឡេងពីមន្ទីរស-២១" ដែលមានឯកសារលេខ D108/50/1.4.6 ហើយដែលលោកបានធ្វើការបោះពុម្ព។ តើលោកបានចាប់ផ្ដើមធ្វើការសិក្សាស្រាវជ្រាវ ដើម្បីសរសេរសៀវភៅនេះចាប់តាំងពីពេលណាមក? និងថាតើលោកបានធ្វើការសិក្សាស្រាវជ្រាវនៅកន្លែងណា ដើម្បីសរសេរសៀវភៅនេះ?

**ឆៈ** ខ្ញុំបានចាប់ផ្ដើមធ្វើការសៀវភៅនេះចាប់ពីឆ្នាំ១៩៩៣ ហើយនៅទីក្រុងមែលប៊ន នៅពេលដែលខ្ញុំអាចបើកមើលបាននៅម៉ៃក្រូហ្វីម នៃឯកសារចម្លើយសារភាពជាច្រើននៅស-២១ នោះ ខ្ញុំបានពិនិត្យមើល ហើយខ្ញុំ នៅឆ្នាំ១៩៩៤ ខ្ញុំធ្វើការនៅវ៉ាស៊ីនតោនឌីស៊ី ហើយនៅកម្ពុជានៅឆ្នាំ១៩៩៥, ៩៧ ជាដើម។ ហើយដែល -- ហើយខ្ញុំត្រឡប់ទៅសហរដ្ឋអាមេរិកឆ្នាំ១៩៩៨ ហើយបោះពុម្ពឆ្នាំ១៩៩៩។

[០៩:៤៤:00]

ឯកសារចងក្រងពីសៀវភៅនេះគឺភាគច្រើននោះ គឺឯកសារកម្ពុជានិយាយពីសៀវភៅនេះ គឺជាឯកសារដែលបានសិក្សានៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏នៅស-២១ ជាសារមន្ទីរទួលស្លែងនោះ គឺជាឯកសារដែលខ្ញុំសិក្សានៅបណ្ណាល័យ ហើយការសិក្សាស្រាវជ្រាវ ខ្ញុំធ្វើការនៅអូស្ត្រាលី, នៅកម្ពុជា ហើយនៅសហរដ្ឋអាមេរិក ដើម្បីសរសេរសៀវភៅនេះបាទ។

**ស៖** បាទ អរគុណ។ ហើយក្នុងអំឡុងពេលសិក្សាស្រាវជ្រាវ ដើម្បីសរសេរសៀវភៅដែលមានចំណងជើងថា "សំឡេងពីមន្ទីរស-២១" ដែលលោកបានធ្វើការវិភាគនៅ -- តើលោកធ្វើការវិភាគនៅបណ្ណសារទាំងអស់នៅមន្ទីរស-២១ រួមទាំងចម្លើយសារភាពជាងបួនពាន់នៅមន្ទីរស-២១ ដែលបច្ចុប្បន្នដែលគេហៅថា "គុកទួលស្លែង" នោះ តើពិតមែនដែរឬទេ?

**ឆ៖** ទេ ខ្ញុំមិនបានពិនិត្យមើលចម្លើយសារភាពទាំងបួនពាន់នោះទេ ប៉ុន្តែខ្ញុំបានមើលមួយចំនួន ហើយខ្ញុំបានមើលត្រួសៗនូវឯកសារមួយចំនួន។ ហើយខ្ញុំផ្តោតអារម្មណ៍ចំណុចណាដែលចម្លើយសារភាពដែលខ្ញុំចាប់អារម្មណ៍ខ្លាំងទៅនឹងកិច្ចការរដ្ឋបាល ដែលចេញមកពីទួលស្លែង ហើយដែលខ្ញុំសិក្សាលម្អិត ដើម្បីរកឃើញថា តើគុកហ្នឹងដំណើរការដូចម្តេច? អ្នកណាជាអ្នកធ្វើការនៅទីនោះ? តើប្រភេទនៃគោលនយោបាយដូចម្តេចអ្វីខ្លះដែលគេធ្វើសម្រាប់សួរចម្លើយ? វិធីធ្វើទារុណកម្ម...។ល។ ហើយជាឯកសារដែលគួរឲ្យចាប់អារម្មណ៍ខ្លាំងអំពីគំនិតនយោបាយនោះ គឺថាជាឯកសារនិយាយអំពីការគ្រប់គ្រងគុក ហើយឯកសារ -- ចំណងជើងសៀវភៅនេះ គឺថាខ្ញុំគួរតែដាក់ថា ដូចដែលមានអត្ថន័យសម្រាប់អ្នកអាន គឺគួរតែដាក់ថា "សំឡេងពីស-២១" គឺជាសំឡេងដែលចេញពីជនរងគ្រោះ ហើយនិងពីចារីនៅ ស-២១ នោះដែរ។

[០៩:៤៦:១២]

**ស៖** បាទ អរគុណ។ ហើយតើលោកធ្លាប់បានជួបសម្ភាសជាមួយនឹងអតីតបុគ្គលមន្ទីរស-២១ អ្នករស់រានមានជីវិតពីមន្ទីរស-២១ ឬអ្នករក្សាបណ្ណសារនៅមន្ទីរស-២១ និងអ្នកផ្សេងទៀតដែលពួកគាត់បានដឹងច្បាស់អំពីរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងពេលដែលលោកសិក្សាស្រាវជ្រាវដើម្បីសរសេរសៀវភៅនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានសម្ភាសជាមួយ វ៉ាន់ ណាត ហើយនិងសម្ភាសជាមួយអ្នកយាមមួយចំនួន។ ខ្ញុំបានសម្ភាស ហ៊ឹម ហ៊ុយ ដែលគាត់បានឆ្លើយព័ត៌មានជាច្រើន ហើយខ្ញុំបានពិនិត្យមើលប្រតិចារឹកអំពីអ្នករស់រានមានជីវិតពីស-២១ ប៊ូ ម៉េង ជាដើម។ បាទ ខ្ញុំបាននិយាយជាមួយ ញ៉ែម អេន ជាអ្នកថតរូប នៅក្នុងឆ្នាំ១៩៩៧ ឬ៩៨ គឺ៩៧ ខ្ញុំបានសម្ភាសគាត់បីបួនដង ខ្ញុំបានសួរមនុស្សជាច្រើន គឺថាជាពិសេស គឺខ្ញុំធ្វើបទសម្ភាសន៍សម្រាប់សៀវភៅពីមុន ដែលទាក់ទងទៅនឹងបញ្ហាប្រវត្តិសាស្ត្រជាជាងបញ្ហានយោបាយដើម្បីប្រមូលព័ត៌មាន។

[០៩:៤៧:៣១]

**ស៖** បាទ អរគុណ។ សំណួរ ថាតើលោកធ្លាប់បានធ្វើសម្ភាសជាមួយជនជាប់ចោទ ទាំងបីរូប គឺមាន នួន ជា, អៀង សារី និង ខៀវ សំផន ដែរឬទេ នៅពេលដែលលោកសិក្សាស្រាវជ្រាវដើម្បីសរសេរសៀវភៅទាំងនោះ ឬសៀវភៅផ្សេងទៀត?

**ឆ៖** ទេ ខ្ញុំមិនបានសម្ភាសទេ ប៉ុន្តែខ្ញុំបាន -- សូមអរគុណចំពោះប្រតិចារឹក ហើយនិងបទសម្ភាសន៍ទាំងឡាយដែលខ្ញុំទទួលបានព័ត៌មានសម្រាប់សរសេរសៀវភៅនេះ។

**ស៖** បាទ អរគុណ។ កាលពីមុនលោកអ្នកជំនាញត្រូវបានកោះហៅមកផ្ដល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងម្ដងហើយ នៅក្នុងសវនាការពិភាក្សាដេញដោលពិនិត្យភស្តុតាងនៅក្នុងសំណុំរឿង០០១ ដែលមានជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាប្រធានមន្ទីរស-២១ ក្នុងឋានៈជាអ្នកជំនាញ។ តើពិតមែនដែរឬទេ? ហើយក៏បានពិភាក្សាយ៉ាងលម្អិតអំពីសៀវភៅដែលមានចំណងជើងថា "សំឡេងពីមន្ទីរស-២១" ផងដែរ តើពិតមែនដែរឬទេ?

[០៩:៤៨:៤៣]

**ឆ៖** បាទ ពិតហើយ ខ្ញុំបានផ្ដល់សក្ខីកម្មទាក់បញ្ហានោះ ខែសីហា ឆ្នាំ២០០៩ សៀវភៅនោះបានពិភាក្សាយ៉ាងលម្អិតនៅកាលនោះបាទ។

**ស៖** បាទ អរគុណ។ តើលោកមានដែលធ្លាប់ជួបសម្ភាសជាមួយលោក កាំង ហ្គេកអ៊ាវ ដែរឬទេ នៅពេលដែលលោកសិក្សាស្រាវជ្រាវ ដើម្បីសរសេរសៀវភៅ ឬអត្ថបទផ្សេងៗនោះ?

**ឆ៖** ទេ ខ្ញុំមិនបានជួបសម្ភាសជាមួយគាត់ទេ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណលោក ដេវីដ ឆេនដ៍ល័រ។ ហើយតើអស់លោក លោកស្រីចៅក្រមមានសំណួរអ្វីចង់សួរដល់ជំនាញរូបនេះដែរឬទេ? ប្រសិនបើមានសូមអញ្ជើញ។ សូមអញ្ជើញលោកស្រីចៅក្រម!

[០៩:៤៩:៤២]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំរួមជាមួយប្រធានសូមអរគុណលោក ដែលបានត្រឡប់មកផ្ដល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញក្នុងតុលាការនេះ។

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

**ស៖** ជាថ្មីម្ដងទៀត ហើយខ្ញុំចង់ត្រឡប់ដោយសង្ខេបទៅ អំពីការសិក្សាថ្នាក់បណ្ឌិតរបស់លោក

ជាអាជីពរបស់លោកពីដំបូងនោះ គឺជាគុណសម្បត្តិដើម្បីឲ្យលោកបញ្ជាក់ ដើម្បីតុលាការកត់ត្រា។

**ឆ៖** ខ្ញុំសញ្ញាបត្រថ្នាក់បណ្ឌិតរបស់លោកខ្ញុំគឺបរិញ្ញាបត្ររបស់ខ្ញុំពី អំពីៗ មីឈីហ្គេន ហើយខ្ញុំបានបង្រៀននៅសាលវិទ្យាល័យម៉ូណាស នៅប្រទេសអូស្ត្រាលី ហើយជាសាស្ត្រាចារ្យម្តងម្កាល ហើយនៅ ខូរណែល មីឈីហ្គេន ហើយ វិសខនស៊ិន ហើយនៅ អ័រវេហ្គិន ហើយនិង ចន ហប់ឃីន អំពីបាននៅ វ៉ាស៊ីនតោន ឌីស៊ី ផងដែរ។

**ស៖** សូមអរគុណ លោក ឆេនដ័ល័រ។ មុននឹងសួរសំណួរមួយចំនួនទៅលោក ខ្ញុំចង់បញ្ជាក់ជូនលោកអំពីកម្រិតព្រំដែនដែលថាជំនាញរបស់លោក គឺថាអាចនឹងទាក់ទងក្នុងការឆ្លើយថ្ងៃនេះ គឺការជំនុំជម្រះនេះគឺនិយាយអំពីផ្នែកមួយ អំពីសំណុំរឿងទាំងមូលទាក់ទងទៅនឹងជនជាប់ចោទ នួន ជា, អៀង សារី, និង ខៀវ សំផន នៅក្នុងដីកាបញ្ជូនរឿងមកជម្រះ។ កាលពីមុននោះ គឺអង្គជំនុំជម្រះបានបំបែកសំណុំរឿងទៅជាផ្នែកតូច ហើយនៅក្នុងការជំនុំជម្រះនេះ យើងបានស្តាប់នូវភស្តុតាងទាក់ទងទៅនឹងប្រវត្តិសាស្ត្រ អំពីការបង្កើត ហើយនិងការវិវត្តន៍នៃបក្សកុម្មុយនីស្តកម្ពុជាមុនឆ្នាំ១៩៧៥។ ហើយយើងក៏ពិនិត្យមើលនូវរចនាសម្ព័ន្ធរដ្ឋបាលនៃកម្ពុជាប្រជាធិបតេយ្យ នៃបក្សកុម្មុយនីស្តកម្ពុជាទាក់ទងទៅនឹងការពិនិត្យគណៈអចិន្ត្រៃយ៍ គណៈមជ្ឈិម ហើយនិងមន្ទីរ៨៧០ ព្រមទាំងការងាររបស់មន្ទីរនេះ ហើយនិងរចនាសម្ព័ន្ធថ្នាក់ជាតិកំពូលរបស់គេនោះផងដែរ។

[០៩:៥២:១១]

ហើយនិងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាចាប់ពីឆ្នាំ១៩៧៥ ដល់១៩៧៩ ហើយក៏ជាប្រធានបទនៃការសួរដេញដោលនេះដែរ។ យើងក៏ពិចារណា ពិនិត្យមើលប្រព័ន្ធទំនាក់ទំនង ហើយនិងការអនុវត្តនៅក្នុងថ្នាក់មជ្ឈិម ភូមិភាគ តំបន់ ស្រុក ហើយនិងពីផ្នែកខាងក្រៅ ដែលថា តើជនជាប់ចោទម្នាក់ៗអាចនឹងចូលរួមនៅក្នុងប្រព័ន្ធទំនាក់ទំនងនៃការបញ្ជានយោបាយ ហើយនិងបញ្ហាផ្សេងៗទៀត។

យើងនឹងពិនិត្យមើលទិដ្ឋភាពនៃប្រព័ន្ធឃោសនា ហើយនិងការពិចារណាទៅលើឯកសារលាយលក្ខណ៍អក្សរដូចជាទស្សនាវដ្តីទង់បដិវត្តជាដើម។ យើងនឹងពិនិត្យមើលរចនាសម្ព័ន្ធយោធា ហើយនិងខ្សែទំនាក់ទំនង ហើយនិងគោលនយោបាយដែលគាត់តែងឡើងដើម្បីដំណាក់កាលដំបូងនៃកម្ពុជាប្រជាធិបតេយ្យ ហើយនិងពិនិត្យមើលថាតើតួនាទីរបស់ជនជាប់ចោទម្នាក់ៗមានអ្វីខ្លះនៅក្នុងដំណាក់កាលនោះ។

[០៩:៥៣:២៤]

នៅផ្នែកមួយទៀត យើងនិងពិនិត្យមើលដំណាក់កាលទីមួយ ហើយនិងដំណាក់កាលទីពីរនៃការ

ជម្លៀសប្រជាជននៅក្នុងរបបនោះ ដែលគេបញ្ជាក់ថា បានកើតមានឡើងចាប់ពីផ្ដើមដំបូងនៃរបបនេះ រហូតដល់ពាក់កណ្ដាល និងចុងឆ្នាំ១៩៧៦។ នេះជារយៈកាលតាមលំដាប់លំដោយ ចាប់ពីឆ្នាំ១៩៧៥ រហូតទៅដល់ចុងឆ្នាំ១៩៧៦។ ហើយតាមពិតភាគី នឹងៗត្រូវផ្ដោតទៅលើបញ្ហាទាំងអស់នេះដែរនៅក្នុងការសួរដេញដោលនេះ។

ភាគីនឹងសួរលោកជាច្រើនទាក់ទងទៅនឹងការផ្ដល់សក្ខីកម្មនេះ ទាក់ទងនឹងសៀវភៅរបស់លោក ហើយនិងអត្ថបទដែលលោកបានសរសេរក្នុងនាមជាបណ្ឌិតនោះ។ ហើយខ្ញុំនឹងសួរសំណួរអំពីចំណុចមួយនៃក្នុងសៀវភៅមួយនោះទេ ខ្ញុំចាប់អារម្មណ៍ដែលលោកពិនិត្យមើលឯកសារ ដែលសល់ពីរបបនោះ។ សៀវភៅដែលនិយាយថា "ផែនការ -- ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត" នោះលោកបាននិយាយថាមានឯកសារៗ E3/8 គឺ E3/213 ហើយនិង E3/735។

[០៩:៥៤:៥៣]

ដូចដែលលោកបានបញ្ជាក់ សៀវភៅនេះ គឺផ្អែកទៅលើឯកសារចំនួនប្រាំបីដែលបានជ្រើសរើស ហើយនិងត្រូវបានបកប្រែ ហើយបាន លោកបានពិភាក្សាជាមួយនឹងសហអ្នកនិពន្ធ ហើយបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ១៩៨៨។ នៅក្នុងសេចក្ដីផ្ដើម ឬក៏អារម្ភកថានៃសៀវភៅនោះ គឺថាមិនទាន់ត្រូវបានបកប្រែទៅភាសាខ្មែរ ទៅជាអង់គ្លេសនោះទេ ហើយយើងមានតែជាភាសាអង់គ្លេស ERN គឺ 00103994 រហូតទៅដល់ 998។ លោកបានបញ្ជាក់ថា នៅក្នុងអារម្ភកថា នេះ នៅក្នុងៗរយៈកាលនៃការជំនុំ -- គឺនៅក្នុងឆ្នាំ១៩៧៥ ដល់ ៧៦ គឺមានសុទិដ្ឋិនិយមផ្ទាល់មាត់អំពីការសម្រេចបាននូវសង្គមនិយម នៅក្នុងកម្ពុជា។

[០៩:៥៥:៥៦]

ប៉ុន្តែបន្ទាប់ពីរយៈកាលដំបូងនេះ បក្សក្លាយទៅជាទុទិដ្ឋិនិយមជាង គឺថាវាមានគំនិតសងសឹកចងគំនុំ ហើយសម្លាប់ ហើយនិងសង្កត់ធ្ងន់ទៅលើកំណត់ខ្មាំងទៅវិញ។ អ៊ីចឹងគឺថា អ្នកណានៅក្នុងបក្សកុម្មុយនីស្តកម្ពុជាហ្នឹងជាអ្នកកំណត់ថាជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងដំណាក់កាលដំបូង នៃរបបនេះ?

**ឆ៖** នៅដំណាក់កាលដំបូងនៃរបបនេះគឺខ្មាំងជាបឋមដែលបានបញ្ជាក់នៅក្នុងរបបនេះ គឺថាមនុស្សដែលមានការពាក់ព័ន្ធទៅនឹងសាធារណរដ្ឋខ្មែរ ឬក៏ពួកកងទ័ពសាធារណរដ្ឋខ្មែរ។ នៅពេលដែលពេលចេះតែវិវត្តន៍ទៅមុខ គឺថា គឺគេបានផ្សាយទូលំទូលាយកាន់ទៅ គឺថាមនុស្សទូទៅដែលមានតំណែង

នៅក្នុងរដ្ឋាភិបាល ឬរហូតទៅដល់មនុស្សដែលរស់នៅក្នុងរបបនោះ នៅក្នុងភ្នំពេញ ឬក្នុងទីក្រុងផ្សេងទៀត ដែលគេហៅថាប្រជាជនថ្មី ឬក៏ប្រជាជន១៧ មេសា ដែលត្រូវបានជម្លៀសចេញពីក្រុងទាំងអស់នោះនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ហើយវាក្លាយទៅជាទិសដៅនៃៗ -- ប្រហែលជាការចាប់អារម្មណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ដែលគេចាត់ទុកថាជាប្រជាជនដែលមិនគោរពតាមបក្ស ហើយមានវណ្ណៈសង្គមចាស់ ហើយសង្គមនោះមិនពេញចិត្ត ដែលមនុស្សអ្នកមានប្រវត្តិរូបអាក្រក់។ នេះហើយជាគំនិតមួយចំនួន បើយើងមើលទូលស្តែងខ្លួនឯងគឺមិនបានបើកទេ រហូតទាល់តែឆ្នាំមួយពាន់ -- មេសា ១៩៧៦។

[០៩:៥៧:៥៦]

ហើយពីមុននោះគឺថាការលុបបំបាត់ខ្លាំង គឺថាដំណាក់កាលដំបូងនោះគឺថា គេរាប់បញ្ចូលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជានៅក្នុងរបប -- នៅក្នុងយោធាផងដែរ។ ប៉ុន្តែការផ្លាស់ប្តូរនោះគឺពាក់កណ្តាលឆ្នាំ១៩៧៦ ទេ ដែលគេកម្ទេចខ្លាំងដែលនៅក្នុងបក្សកុម្មុយនីស្តកម្ពុជារបស់គេនោះ។

ហើយនៅក្នុង វាមានលក្ខណៈទុទិដ្ឋិនិយមខ្លាំងចាប់ពីឆ្នាំ១៩៧៦ មកនោះ។

**ស៖** សូមអរគុណ។ នៅក្នុង ERN ជាភាសាខ្មែរនោះ ដើម្បីសម្រាប់ការសេចក្តីណែនាំទាក់ទងនឹងផែនការ ប៉ុល ពត ទៅអនាគតនោះគឺលេខ 002823693 រហូតទៅដល់ 823704 ហើយខ្ញុំនឹងសូមដកស្រង់ផ្នែកខ្លះអំពីសេចក្តីផ្តើមនៃសៀវភៅនោះ លោកបាននិយាយថា ឯកសារទាំងប្រាំបីនោះខ្ញុំសូមដកស្រង់គឺកើតចេញអំពីសម័យកាលដ៏សំខាន់ជាប្រវត្តិនៃក្រុម គឺថាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ហើយលោកបានបន្តនិយាយថា រយៈពេលនោះ ដែលឯកសារនេះដែលគេ បានឯកសារនោះ គឺខែមីនា ឆ្នាំ ១៩៧៦ ដល់ខែឧសភា ឆ្នាំ១៩៧៧ បានកំណត់អំពីកិច្ចប្រឹងប្រែងដ៏ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីត្រួតត្រា ដើម្បីប្តូរកម្ពុជាទាំងមូលហ្នឹង គឺពេលជាង២០ឆ្នាំបានកន្លងផុតទៅ គឺការបោះពុម្ពសៀវភៅរបស់ ប៉ុល ពត ដែលផែនការអនាគតរបស់ ប៉ុល ពត នោះគឺអ្វីដែលខ្ញុំចង់ដឹងនោះ ថាតើលោកនៅប្រកាន់នូវទស្សនៈដដែលនេះ ដូចដែលលោកបានបញ្ជាក់នៅក្នុងអារម្ភកថា ឬក៏នៅក្នុងពេលនេះ លោកមានអ្វីកែតម្រូវទៅលើខ្លឹមសារហ្នឹងដែរឬទេ?

[១០:០០:១០]

**ឆ៖** ខ្ញុំគិតថា ខ្ញុំមិន -- ខ្ញុំបានពិនិត្យមើល ប៉ុន្តែក្នុងន័យនេះ ខ្ញុំអាចកែសម្រួលតែបន្តិច ដើម្បីនិយាយថា គឺថាសុទិដ្ឋិនិយមដ៏ខ្ពស់បំផុតនោះ គឺថាមិនពង្រីករហូតដល់ឯកសារចុងក្រោយ ដែលចម្លើយ

សារភាពរបស់ ហ៊ូ នឹម នៅឆ្នាំ១៩៧៧ ទេ។ នៅពាក់កណ្តាលឆ្នាំ១៩៧៧ គឺថាយើងមានការបោះសម្អាតទូលំទូលាយនៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា ដែលថាមានអ្នកទោសរាប់ពាន់ដែលបានបញ្ជូនមកស-២១ នោះ។ ដូច្នេះ យើងត្រូវនិយាយថា ឥឡូវនេះ ខ្ញុំនឹងអាចកែប្រែប្រយោគនោះ ដើម្បីនិយាយថា ចាប់ពី ១៩៧៥ មកដល់ពាក់កណ្តាលឆ្នាំ១៩៧៦ គឺថាឯកសារដែលរកឃើញចេញពីមកអំពីរយៈកាលដែលមានការមិនប្រាកដនិយមដ៏ធ្ងន់ធ្ងរ អំពើហិង្សាធ្ងន់ធ្ងរ ឬក៏ការមិនទុកចិត្តធ្ងន់នោះ គឺថាវាមានបញ្ហាទុទ្ទិដ្ឋិនិយមខ្លាំង។

[១០:០១:២០]

**ស៖** សូមអរគុណ។ ដូច្នេះ ខ្ញុំសន្មតថា លោកបានពិនិត្យឯកសារជាច្រើនទៀត ចេញមកពីបណ្ណសារ ដែលលេចចេញនៅក្នុងសម័យរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងចំណោមឯកសារប្រាំបីដែលលោកបានពិនិត្យមើល។ តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** ខ្ញុំពិនិត្យឯកសារទាំងអស់នោះ។ ឯកសារបក្សកុម្មុយនីស្តកម្ពុជាចំនួន១៥ ដែលក្នុងនោះ គឺត្រូវបានប្រមូលដោយ យៀរនិន ហើយបន្ទាប់មក គឺខ្ញុំរកឃើញ។ ខ្ញុំពិនិត្យឯកសារទាំងអស់ ហើយអត្ថបទទាំងអស់នោះ ក៏ខ្ញុំពិនិត្យមើលផងដែរ។ វាមានការចាប់អារម្មណ៍នៅក្នុងឯកសារទាំងអស់នោះ។ បាទ ជាការពិត គឺខ្ញុំបានពិនិត្យមើលឯកសារទាំងអស់នោះ ហើយឯកសារដែលខ្ញុំដកស្រង់ចេញមកពីកំណត់ហេតុប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជាដែលខ្ញុំចាប់អារម្មណ៍។

**ស៖** និយាយឲ្យទូលាយជាងនេះ ឯកសារដែលលោកបានពិនិត្យទាក់ទងទៅនឹងសៀវភៅរបស់ ប៉ុល ពត រៀបចំផែនការសម្រាប់អនាគតនោះ តើលោកបានពិនិត្យមើលលើកំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមដែរឬទេ?

[១០:០២:៣១]

**ឆ៖** បាទ ដោយសារតែកំណត់ហេតុទាំងអស់នោះ មានតែមួយចំនួនតូចតែប៉ុណ្ណោះ ដែលនៅសល់នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន គឺខ្ញុំបានពិនិត្យខ្លះដែរ។

**ស៖** ចំណុចនេះ គឺខ្ញុំប្រហែលជាចង់សួរលោក ឲ្យលោកនឹកឃើញ ឲ្យលោករម្លឹកឡើងបន្តិចទៅមើល ថាតើលោកអាចនិយាយថាអ្នកណាគេជាអ្នកនិពន្ធឯកសារប្រាំបី ដែលលោកបានយកមកប្រើប្រាស់ជាមូលដ្ឋានសម្រាប់ឯកសារ ស្តីអំពី “ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត” នោះ?

[១០:០៣:១០]

**ឆ៖** ខ្ញុំគិតថា ឯកសារទាំងនេះមួយចំនួន មិនមានឯកសារណាមួយដែលមានអ្នកនិពន្ធនោះទេ ក៏ប៉ុន្តែចម្លើយសារភាព គឺគ្មានឈ្មោះ ហ៊ូ នឹម។ ហើយ កៀត ស៊ី សុន្ទរកថា កៀត ស៊ី ដែលខ្ញុំបានសរសេរនៅក្នុងជំពូកនៃឯកសាររបស់ខ្ញុំ ហើយយើងមិនឃើញមានភស្តុតាងពាក់ព័ន្ធណាមួយ ដែលថា ប៉ុល ពត ឬក៏ នួន ជា ជាអ្នកសរសេរនោះទេ។ តែយើងដឹងហើយថា អ្នកដែលជាអ្នកកំពូល ជាអ្នកធ្វើសុន្ទរកថា។ ខ្ញុំគិតថា ឯកសារគណៈអចិន្ត្រៃយ៍នោះ គឺមិនមានចុះហត្ថលេខា ឬបញ្ជាក់ថានរណាគេជាអ្នករៀបចំនោះទេ។ ឯកសារនីមួយៗនោះ វាមានលក្ខណៈខុសគ្នាបន្តិចបន្តួច។ សុន្ទរកថា ក៏មិនមានចុះហត្ថលេខា កំណត់ហេតុមិនមានចុះហត្ថលេខា ចម្លើយសារភាពជាការពិត គឺចុះហត្ថលេខាមានឈ្មោះបុគ្គលដែលគាត់ជាអ្នកសរសេរ។

[១០:០៥:១៥]

**ស៖** សូមអរគុណ។ ឯកសារមួយដែលលោកបានផ្តោតនៅក្នុងសៀវភៅ "ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត" នោះ គឺសេចក្តីសម្រេចរបស់គណៈមជ្ឈិមលើបញ្ហាផ្សេងៗ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។ ឯកសារនោះ មានលេខ E3/12។ នេះគឺលេខឯកសារ គឺ E3/12។ ERN ជាភាសាអង់គ្លេស គឺ 00182809 ដល់ 814, ខ្មែរ ERN មានលេខ 00003136 ដល់ 3140 និងលេខ ERN ជាភាសាបារាំង គឺ 00224363 ដល់ 4367។ ជាការពិត លោកស្គាល់ឯកសារមួយនេះរួចទៅហើយ។ ដូច្នេះតើលោក -- តាមការស្រាវជ្រាវរបស់លោកតើលោកអាចនិយាយបានដែរឬទេថា តើឯកសារនេះក្នុងពេលដែលគេរៀបចំកំណត់ហេតុនេះឡើង តើឯកសារកំណត់ហេតុសេចក្តីសម្រេចនេះបានបែងចែកជាទូទៅនៅក្នុងចំណោមប្រជាជនទូទៅនៅក្នុងប្រទេសកម្ពុជាដែរឬទេ ឬក៏ចែកក្នុងចំណោមមនុស្សមួយចំនួនតែប៉ុណ្ណោះ?

**ឆ៖** គឺឯកសារនេះមិនចែកជាទូលំទូលាយនោះទេ មិនមានប្រជាជនណា ទាំងឡាយ ទាំងអស់នោះបានទទួលជាលក្ខណៈទូលំទូលាយនោះទេ។ កំណត់ហេតុនៃគណៈអចិន្ត្រៃយ៍ គឺចែកកម្រិតតែលើបុគ្គលមួយចំនួនតែប៉ុណ្ណោះ ហើយវា -- ខ្ញុំមិនចាំចំនួនកម្រិតនៃការថតចម្លងនៃឯកសារនោះប៉ុន្មាននោះទេ។ កំណត់ហេតុគណៈអចិន្ត្រៃយ៍បញ្ជូនតែទៅសមាជិករបស់គណៈអចិន្ត្រៃយ៍ ហើយបណ្ណសារនៅក្នុងសម័យនោះក៏វាបាត់អស់ទៀត។

[១០:០៦:១៩]

ចំពោះតេឡេក្រាម ទូរលេខ ឬក៏កំណត់ហេតុទាំងអស់នេះ គឺវាមិនចែកចម្លងច្រើននោះទេ

ប្រហែលជា១០ ទៅ១៥ តែប៉ុណ្ណោះដែលគេរៀបចំនៅពេលនោះ ហើយគេមិនបានបញ្ជាក់ថា តើគេថតចម្លងចំនួនប៉ុន្មាននោះទេ។ ចំពោះសេចក្តីសម្រេចនោះ ដូច្នេះបានន័យថា សេចក្តីសម្រេចនេះគឺចែកផ្សាយក្នុងចំណោមបុគ្គលមួយចំនួនតែប៉ុណ្ណោះ ហើយបណ្ណសាររបស់គេគឺ គេរក្សាយ៉ាងសម្ងាត់។

**ស៖** លោកបានលើកឡើងថា បណ្ណសារសម័យនោះត្រូវបានគេបំផ្លិចបំផ្លាញចោល តើ ថាតើលោកអះអាងនេះដោយផ្អែកលើអ្វីដែរ?

**ឆ៖** បណ្ណសារត្រូវបានបំផ្លាញនោះ បានន័យថា មិនមានឯកសារនៅសល់ច្រើននោះទេ។ វាអាចនៅសល់ ក៏ប៉ុន្តែគឺការស្មានរបស់ខ្ញុំតែប៉ុណ្ណោះទៅលើចំណុចនេះ។ ភស្តុតាងបានបង្ហាញថា ឯកសារមួយចំនួនត្រូវបានគេរក្សាទុកទៅ នៅកន្លែងមួយចំនួន ក៏ប៉ុន្តែវាបាត់បង់ដោយសារតែមានការបំផ្លិចបំផ្លាញ។ សេចក្តីសម្រេចនិងកំណត់ហេតុ១០ច្បាប់ មួយចំនួននោះបាននៅសល់ ដែលសល់នៅក្នុងចំណោមបុគ្គលដែលចូលរួមនៅក្នុងការប្រជុំ។ ជួនកាលនៅឯកសារប្រាំបួនបានបាត់បង់ ត្រូវបានគេបំផ្លាញ ប៉ុន្តែគឺយ៉ាងហោចណាស់ក៏មាននៅសល់មួយច្បាប់នៅក្នុងបណ្ណសាររបស់គេផងដែរ។

[១០:០៧:៤៨]

**ស៖** តើលោកបានឃើញសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ នេះលើកដំបូងនៅឯណាដែរ?

**ឆ៖** ខ្ញុំប្រាកដជាបាន -- ខ្ញុំទាយថា ខ្ញុំឃើញឯកសារនេះនៅក្នុងឆ្នាំ១៩៨២, ៨៣ ខ្ញុំគិតថានៅពេលដែល ប៉ែន យៀរនិន បានផ្តល់ឯកសារនេះមកឲ្យខ្ញុំ។ ខ្ញុំមិនចាំការបរិច្ឆេទច្បាស់លាស់នោះទេ គឺនៅមុនឆ្នាំ១៩៩០ ប្រហែលជា៨៤, ៨៥ គឺបុគ្គលដែលគាត់កាន់កាប់ឯកសារនេះ គឺគាត់បានប្រមូលហើយប្រមូល ខ្ញុំបានទទួលមកពីគេ។ ខ្ញុំគិតថា ខ្ញុំទាយ ខ្ញុំគិតថា ប្រហែលជាឆ្នាំ៨៤, ៨៥ ដែលខ្ញុំបានឃើញឯកសារនេះលើកដំបូង។

[១០:០៨:៤៥]

**ស៖** តើលោកមានការងឿងឆ្ងល់ ការសង្ស័យទៅលើយថាភាពនៃឯកសារនេះដែរឬទេ? ជាពិសេសដែលវាសរសេរថា ជាសេចក្តីសម្រេចរបស់គណៈមជ្ឈិមនោះ តើលោកមានភាពសង្ស័យទៅលើសេចក្តីសម្រេចនេះដែរឬទេ?

**ឆ៖** ខ្ញុំមិនមានការសង្ស័យទៅលើសេចក្តីសម្រេចនេះទេ។ ថាតើយថាភាពនោះយ៉ាងណា? យើងអាចនិយាយថា វាជាឯកសារក្លែងក្លាយ មិនដឹងលេចមកពីណានោះទេ អ្នកខ្លះគេនិយាយថាវាមិន

មែនជាឯកសារក្លែងក្លាយនោះទេ។ ខ្ញុំគិតថា ខ្ញុំសន្និដ្ឋានថាឯកសារនេះ គឺជាឯកសារមានយថាភាពដែលវាសល់ដោយចៃដន្យ ហើយត្រូវបានរកឃើញដោយបុគ្គលមួយចំនួនបានផ្តល់ទៅ ប៉ែន យៀវនិន បន្ទាប់មកផ្តល់មកឱ្យខ្ញុំនៅក្នុងឆ្នាំទសវត្សរ៍៨០។ ខ្ញុំគិតថា បុគ្គលមួយចំនួនគិត -- គេលើកឡើងថាឯកសារនេះគេបានទទួលក្នុង៨៤ អ្នកខ្លះថា ៨៥។ ដូច្នេះ ខ្ញុំគិតថា វាជាឯកសារមួយមានយថាភាព។

[១០:០៩:៥៣]

**ស៖** តើចំណុចសំខាន់ណាដែលលោកបានផ្តល់ទៅលើសេចក្តីសម្រេចរបស់គណៈមជ្ឈិមនោះដែលសេចក្តីសម្រេចនេះ គឺជាមធ្យោបាយមួយឱ្យយើងយល់អំពីមនោគមន៍វិជ្ជាបក្សកុម្មុយនីស្តកម្ពុជានៅក្នុងសម័យនោះ?

**ឆ៖** ខ្ញុំព្យាយាមចងចាំ។ ខ្ញុំបានមើល -- គឺសូមឱ្យដាក់ឯកសារនេះនៅលើទូរទស្សន៍ដើម្បីឱ្យខ្ញុំអាចមើលផង។ គឺឯកសារនេះ វាមាននៅក្នុងសៀវភៅរបស់ខ្ញុំ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំត្រូវឱ្យមានអ្វីឯកសារដែលរម្លឹកឱ្យខ្ញុំចាំផង។ ថាតើឯកសារនោះយ៉ាងម៉េច? មានរូបរាងយ៉ាងម៉េច ហើយសរសេរអ្វីខ្លះ?

ដូច្នេះ តើលោកស្រីចៅក្រមអាចបង្ហាញឯកសារសេចក្តីផ្តើម ឬក៏ឯកសារដែលពាក់ព័ន្ធសួរនេះនៅលើអេក្រង់ផងបានដែរឬទេ?

[១០:១០:៥៣]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

តើលោកខាងសហព្រះរាជអាជ្ញាមានឯកសារនេះដែរឬទេ?

**លោក អាប់ឌុលឡាក់ ថារីក៖**

គឺមានឯកសារនេះហើយ រៀបចំនឹងបង្ហាញជូនហើយ។

[១០:១១:១១]

*(ការបង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍)*

[១០:១១:២៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន យើងកំពុងតែរងចាំខាងសោតទស្សន៍ដើម្បីធ្វើការបង្ហាញទៅលើឯកសារនេះ។

**ប្រធានអង្គជំនុំ៖**

ខាងបុគ្គលិកផ្នែកសោតទស្សន៍បង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍ ហើយនិងជំនួយការខាងសហព្រះរាជអាជ្ញា សូមបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ។

*(ការបង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍)*

[១០:១៣:២២]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំបានត្រៀមឆ្លើយទៅនឹងបញ្ហានេះនៅពេលនេះ។ នៅក្នុងជួរទីមួយនៃឯកសារនេះ ត្រង់ទំព័រទីមួយ "សិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ" *ស្មាស់* កម្ទេច នៅក្នុងសម័យខ្មែរក្រហមត្រូវបានគេប្រើពាក្យនេះ ដើម្បីប្រៀបធៀបទៅនឹង ប្រដូចទៅនឹងពាក្យថា សម្លាប់នៅក្នុងជួរនិងក្រៅជួរ។ ក្នុងជួរនិងក្រៅជួរបក្សកុម្មុយនីស្តកម្ពុជា ដូច្នេះឯកសារនេះ គឺដើម្បីបង្ហាញអំពីខ្សែសង្វាក់អំណាចក្នុងការទទួលខុសត្រូវ។ ក្នុងការកម្ទេចខ្មាំងក្នុងជួរនិងក្រៅជួរ។

ដូច្នេះ ចំណុចដែលគេសរសេរនេះ គឺជាសិទ្ធិអំណាចដែលគេផ្តល់នៅក្នុងប្រទេសតាមភូមិភាគ ឬក៏ទៅតាមអំណាចខ្សែបណ្តោយក្នុងបក្សកុម្មុយនីស្តកម្ពុជា ដើម្បីធ្វើយ៉ាងណាពង្រឹងទៅលើប្រជាធិបតេយ្យនៅក្នុងសម័យនោះ។ ហើយការដែលគេសរសេរសម្រេចនេះ ដើម្បីបង្កើតម៉ាស៊ីនមួយក្នុងការចែករំលែកទៅលើសេចក្តីសម្រេចនេះរបស់បក្ស។

[១០:១៥:០០]

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

**ស៖** ឯកសារដដែលនេះគឺតម្រូវឲ្យមានរាយ -- តម្រូវឲ្យមានការរាយការណ៍ជាទៀងទាត់ទៅមន្ទីរ៨៧០។ ហើយនៅក្នុងនោះគឺឲ្យគេគិតអំពីបីគោនក្នុងមួយហិកតា គំរូខាងគោលជំហរសតិអារម្មណ៍។ ហើយគេបាននិយាយអំពីថ្ងៃកំណើតបក្សកម្ពុជានៅក្នុងឆ្នាំ១៩៦០ ជាជាង ៦១។ ហើយក៏គេនិយាយអំពីការបំផ្លិចបំផ្លាញមួយចំនួន និងការរៀបចំទៅលើការបោះឆ្នោត។ នៅក្នុងការស្រាវជ្រាវរបស់លោក តើលោកបានធ្វើការពិនិត្យបង្ហាញថា តើគោលនយោបាយនេះគេសម្រេចតាមរបៀបណានៅក្នុងរយៈកាលដែលយើងចាប់អារម្មណ៍នេះ គឺបានន័យថានៅរហូតដល់ចុងឆ្នាំ១៩៧៦?

**ឆ៖** ខ្ញុំគិតថាឯកសារនេះគឺផ្អែកទៅលើអ្វីដែលលោកចៅក្រមសង្ខេប។ គឺជាឯកសារដែលយើងខ្ញុំបានយកទៅដាក់នៅក្នុងសៀវភៅរបស់ខ្ញុំដែលមានចំណងជើងថា "ប៉ុល ពត រៀបចំផែនការសម្រាប់

អនាគត"។ ដូច្នេះហើយនៅក្នុងប្រទេសនេះ គឺមានការដឹកនាំជាសមូហភាព។ ហើយយើងមិនអាចនិយាយថា វាជាផែនការសមូលហភាពនោះទេ។ ផែនការនេះគឺជាផែនការដែលគេបានដាក់ជូនសម្រាប់អនាគតបានន័យថាកំណត់បីតោនក្នុងមួយហិកតា ហើយយើងឃើញថាវាមានការបំផ្លិចបំផ្លាញនៅក្នុងសម័យនោះ។

[១០:១៦:៥៥]

ក៏ប៉ុន្តែមានគោលនយោបាយផ្សេងមួយទៀត ដែលបានអនុវត្តតាមដីកាដំណោះស្រាយដែលខ្ញុំបានមើល គេមានការរាយការណ៍រៀងរាល់សប្តាហ៍ទៅដល់គណៈមជ្ឈិម។ ហើយខ្ញុំមិនបានឃើញចំណុចនេះនៅក្នុងពេលស្រាវជ្រាវរបស់ខ្ញុំនោះទេ។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយយើងដឹងថា គោលនយោបាយនៅពេលនោះគឺបានអនុវត្តដូចនៅក្នុងដីកាដំណោះស្រាយដែលបានសរសេរ។ ដូច្នេះ ទាំងអស់នេះហើយគឺជាផែនការធំរបស់បក្សនៅក្នុងអំឡុងពេលនោះ គឺយើងឃើញមានការបង្កើតរដ្ឋធម្មនុញ្ញដែលបង្កើតសភាជាតិ ហើយរដ្ឋាភិបាលគឺយើងអាចមើល មិនមាន -- ខាងពិភពលោកខាងក្រៅគឺគេមិនស្គាល់រដ្ឋាភិបាលនេះទេ គេមើលមិនឃើញ វាជាលក្ខណៈអរូប។ ដូច្នេះហើយ ទាំងអស់នោះហើយគឺជានយោបាយ និងផែនការដែលប្រទេសនេះបានដំណើរការទៅ គឺដែលគេបានសរសេរឆ្លុះបញ្ចាំងនៅក្នុងសេចក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។

[១០:១៨:១០]

**សះ** សូមអរគុណ។ តាមការស្រាវជ្រាវរបស់លោក តើលោកអាចជម្រាបជូនអង្គសវនាការដែរឬទេ ថាតើជនជាប់ចោទណាមួយ ឬជនជាប់ចោទទាំងបីស្ថិតនៅក្នុង ជាមេដឹកនាំនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆះ** ខ្ញុំ នៅពេលដែលខ្ញុំពិនិត្យមើលនោះគឺថា នួន ជា និង អៀង សារី គឺជាសមាជិកគណៈអចិន្ត្រៃយ៍។ ខ្ញុំមិនដឹងទេ មិនច្បាស់ទេ មិនដឹងថាលោក ខៀវ សំផន នោះគឺជាសមាជិកនៅគណៈអចិន្ត្រៃយ៍ ឬក៏យ៉ាងណានោះឡើយ។

**សះ** ឯកសារនេះក៏បានលើកឡើងថា រដ្ឋាភិបាលត្រូវតែជាអង្គការសុទ្ធមួយ។ ដូច្នេះថាតើនេះជាអ្វីដែលរដ្ឋាភិបាលហ្នឹងគេដំណើរនោះ ឬយ៉ាងម៉េច? ជាពិសេសគឺថា តើវាមានការបែងចែករវាងការគ្រប់គ្រងប្រទេស និងអំណាចបក្សដែរឬទេ?

[១០:១៩:១៨]

**ឆ៖** ខ្ញុំគិតថា វាមិនមានការបែងចែកពិតប្រាកដនោះទេ។ លេខាបក្សកុម្មុយនីស្តនៅពេលនោះ នៅពេលជាមួយគ្នា ឬក៏គ្រប់ពេលទាំងអស់គឺជារដ្ឋ -- នាយករដ្ឋមន្ត្រីនៅក្នុងប្រទេស ដូច្នេះមិនមានការបែងចែក មិនមានការធ្វើតុល្យភាពរវាងការគ្រប់គ្រងបក្ស និងគ្រប់គ្រងរដ្ឋាភិបាលនោះទេ។ ខ្ញុំគិតថា រដ្ឋាភិបាលពេលនោះគឺជាបក្សកាន់អំណាច។

**ស៖** ដូចដែលបានសរសេរនៅក្នុងការរំឭកថ្ងៃព្រឹត្តិការណ៍បក្ស ឯកសារ និងសម្ភារៈផ្សេងទៀត គឺបានលើកឡើង ហើយបាននិយាយអំពីការបង្កើតអង្គការ ស្ថាប័នមួយចំនួនដូចជាសភាជាតិ។ ដូច្នេះ តើត្រឹមត្រូវដែរឬទេ ថាប្រធានសភានៅពេលនោះ គឺជា នួន ជា? ហើយប្រធានគណៈប្រធានរដ្ឋ គឺ ខៀវ សំផន, អៀង សារី គឺជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការងារបរទេស។ តើទាំងអស់នេះ អ្វីដែលខ្ញុំបញ្ជាក់នេះត្រឹមត្រូវដែរឬទេ?

**ឆ៖** តួនាទីទាំងអស់នោះ គឺអ្នកទាំងអស់នោះមាននៅពេលនោះ ហើយអ្នកទាំងអស់នោះក៏មិនមានការបដិសេធ ថាពួកគាត់មិនស្ថិតនៅក្នុងតួនាទីនេះដែរ។

**ស៖** តាមការស្រាវជ្រាវរបស់លោក ដូច្នេះតួនាទីនេះគឺពួកគាត់កាន់ទាំងអស់ ហើយវាមានការពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យនៅពេលនោះ ហើយក៏ពាក់ព័ន្ធទៅនឹងបក្សផងដែរ។ តើអ៊ីចឹងដែរឬទេ? ខ្ញុំសូមកែតម្រូវបន្តិច គឺរហូត តួនាទីនេះ គឺកាន់រហូតទៅដល់ចុងឆ្នាំ១៩៧៩។ តើអ៊ីចឹងដែរឬទេ?

[១០:២១:៥៤]

**ឆ៖** ខ្ញុំមិនប្រាកដនោះទេ ថាតើប្រធានគណៈប្រធានរដ្ឋនោះ គឺកាន់រហូតទៅដល់ពេលនោះ ឬក៏យ៉ាងនោះទេ។ សភាជួបប្រជុំគ្នាតែម្តងទេ គឺបីថ្ងៃនៅពេលនោះ ដើម្បីអនុម័តទៅលើការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ អៀង សារី គឺកាន់តួនាទី និងមានសកម្មភាពនៅក្នុងការអនុវត្ត ការធ្វើគោល-នយោបាយ កិច្ចការបរទេសនៅក្នុងប្រទេសកម្ពុជា ក្នុងពេញមួយរបបនោះតែម្តង។ តួនាទីរបស់ អៀង សារី មានការផ្សព្វផ្សាយជាលក្ខណៈសាធារណៈ ហើយខាងប្រទេសលោកខាងក្រៅក៏បានដឹងជាទូទៅផងដែរ។ ចំពោះប្រធានគណៈប្រធានរដ្ឋនោះ គឺខ្ញុំក៏នៅមិនច្បាស់លាស់ដែរចំពោះចំណុចនេះ។ នួន ជា ដែលជាប្រធានសភា យើងដឹងថា ប្រធាសភានេះគឺមិនមែនជាតួនាទីចម្បងរបស់គាត់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះទេ។

[១០:២៣:០១]

**សៈ** ខ្ញុំសូមចូលនិយាយអំពីលក្ខន្តិកៈបក្ស គឺឯកសារ E3/130។ ដូច្នេះ ខ្ញុំគិតថាលោកក៏ស្គាល់ដែរទៅលើលក្ខន្តិកៈបក្សនេះ គ្រាន់តែខ្ញុំចង់ឲ្យលោកចងចាំ និងរំឭកឡើងវិញតែប៉ុណ្ណោះ។ តើ -- ខ្ញុំគិតថាលោកប្រាកដជាបានពិនិត្យពិចារណា សិក្សាទៅលើលក្ខន្តិកៈបក្សនេះ កាលពីមុន។ តើមែនដែរឬទេ?

**ផៈ** បាទ ខ្ញុំពិនិត្យ និងសិក្សាទៅលើលក្ខន្តិកៈបក្សនេះ។

**សៈ** នៅក្នុងមាត្រា២៧ និង២៨ លក្ខន្តិកៈបក្សចែងថា "កងទ័ពបដិវត្តន៍កម្ពុជាទាំងបីប្រភេទ ស្រួច តំបន់ ឈ្លប ត្រូវស្ថិតនៅក្រោមការដឹកនាំផ្ដាច់មុខ ដាច់ខាត និងគ្រប់ផ្នែករបស់បក្សកុម្មុយនីស្ដកម្ពុជា។ ក្នុងកងទ័ពបដិវត្តន៍កម្ពុជាមានការចាត់តាំងតាមប្រជាធិបតេយ្យប្រមូលផ្ដុំ គណៈកម្មាធិការមជ្ឈិមបក្សកំណត់ការអនុវត្តប្រជាធិបតេយ្យប្រមូលផ្ដុំនេះ តាមសភាពការណ៍ជាក់ស្ដែង"។ ចប់ការដកស្រង់។ ខ្ញុំចង់សួរថាតើបក្សកុម្មុយនីស្ដកម្ពុជា តាមគណៈមជ្ឈិមបានគ្រប់គ្រងកងទ័ពបដិវត្តន៍កម្ពុជា ដូចដែលមានចែងនៅក្នុងមាត្រាទាំងពីរដែលខ្ញុំបានយោងអម្បាញ់មិញនេះដែរឬទេ?

**ផៈ** តាមអ្វីដែលខ្ញុំដឹងល្អបំផុតនោះ សកម្មភាពនៅតាមព្រំដែន គឺយើងឃើញមានសកម្មភាពធំៗជាច្រើន ហើយស្ថិតនៅក្រោមការគ្រប់គ្រងកងទ័ពបដិវត្តន៍កម្ពុជា ហើយវាមិនមែនថាបក្សនោះមិនបានដឹងទៅលើសកម្មភាពទាំងអស់នោះទេ។

[១០:២៤:៥៥]

**សៈ** នៅក្នុងការសម្ភាសដំបូង មុខចៅក្រមស៊ើបអង្កេត នួន ជា បាននិយាយនៅក្នុងឯកសារ E3/54 ថា "ចំពោះខ្ញុំ ក្រោយពេលរំដោះ ខ្ញុំគឺជា -- កាន់តួនាទីច្បាប់ ហើយខ្ញុំមិនចូលរួមក្នុងការងារប្រតិបត្តិនោះទេ។ នៅក្នុងបក្សគឺមានគណៈកម្មាធិការយោធា ដែលមាន ប៉ុល ពត ជាប្រធាន, សុន សេន, តាម៉ុក អនុប្រធាន, សោ ភឹម និង កែ ពក ជាសមាជិក។ ខ្ញុំមិនស្ថិតនៅក្នុងគណៈកម្មាធិការយោធានោះទេ។ ខ្ញុំជាអនុលេខាបក្ស និងជាប្រធានសភាតែប៉ុណ្ណោះ ក្រៅពីនោះ ខ្ញុំទទួលការងារអប់រំកម្មាភិបាល និងសមាជិកបក្ស។ ដូច្នេះ ខ្ញុំមិនពាក់ព័ន្ធទៅនឹងការងារចោទប្រកាន់ទាំងអស់នេះទេ។ នៅពេលនោះ យោធាគឺជាក្រុមខ្លាំងក្លាបំផុតមួយ ពីព្រោះពួកគេគឺជាក្រុមដែលបានវាយ លន់ នល់ ឲ្យបរាជ័យ។ ចំពោះនយោបាយមិនមានលក្ខណៈរឹងមាំនោះទេ។ ពួកគេទទួលនូវការគោរពតិចតួចតែប៉ុណ្ណោះ"។ នេះបញ្ចប់ការដកស្រង់ទៅលើការផ្ដល់សម្ភាសពេលចូលខ្លួនដំបូង។ តើផ្អែកតាមការស្រាវជ្រាវរបស់លោក តើលោកឯកភាពដែរឬទេថា តួនាទីរបស់ នួន ជា គឺស្ថិតនៅក្នុងតួនាទីទាប ហើយមិនសូវមានអំណាចទេ មិនមានអំណាចដូចនឹងសមាជិកគណៈកម្មាធិការយោធានោះទេ។ តើអ៊ីចឹងដែរឬទេ?

[១០:២៦:៣០]

**ឆ៖** ខ្ញុំដូចជាមិនសូវជឿទេចំណុចនេះ។

**ស៖** ថាតើតួនាទីជាក់លាក់របស់គាត់នេះបានន័យថា គាត់មានការដឹងតិចតួច និងមានឥទ្ធិពលតិចតួចទៅលើសកម្មភាពបក្សកុម្មុយនីស្តកម្ពុជា រួមទាំងយោធា។ បានន័យថា តើគាត់មានការដឹងតិចតួចជាង ប៉ុល ពត ដែរឬទេ ដែលជាមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យនាពេលនោះ? តើគាត់មានអំណាចតិចជា ប៉ុល ពត ឬក៏យ៉ាងម៉េច?

**ឆ៖** គាត់បានលើកឡើងថា ប៉ុល ពត ជាលេខាបក្ស ហើយ ប៉ុល ពត គឺជាអ្នកសម្រេចចុងក្រោយទៅលើគ្រប់សេចក្តីសម្រេច ក៏ប៉ុន្តែតាមការស្រាវជ្រាវ និងឯកសារដែលខ្ញុំពិនិត្យមើលនាពេលថ្មីៗ តាមឯកសារចេញមកពីដីកាដំណោះស្រាយ ខ្ញុំឃើញថា នួន ជា គឺមានតួនាទីថ្នាក់លើផងដែរ ហើយបានចូលរួមនៅក្នុងការធ្វើគោលនយោបាយនៅក្នុងប្រទេសកម្ពុជា ផ្នែកនានានៅក្នុងប្រទេសកម្ពុជា រួមទាំងការងារយោធា និងការងារបរទេស និងការងារផ្សេងទៀតផងដែរ។ ដូច្នេះហើយ នួន ជា នៅពេលដែលយើងៗប្រៀបធៀបទៅនឹងបញ្ហាមូលធន គឺយើងអាចយល់ថា ប៉ុល ពត ជាប្រធាន ហើយ នួន ជា គឺជាប្រធានប្រតិបត្តិ ស៊ី.អ៊ី.អូ។

ដូច្នេះ គឺការងាររបស់គាត់នោះ គឺវាមាននៅក្នុងជួរ ហើយមានការកត់ត្រានៅក្នុងឯកសារជាច្រើន ហើយឃើញថាគាត់មានការ មានសកម្មភាពច្រើនណាស់នៅក្នុងរបបនោះ។

[១០:២៨:៣៧]

**ស៖** តាមការស្រាវជ្រាវរបស់លោក តើលោកអាចនិយាយដែរឬទេ ថាគោលនយោបាយទាំងឡាយ ដែលបានបញ្ជូននោះ បានធ្វើឡើងតាមរយៈគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម តើអ៊ីចឹងដែរឬទេ?

**ឆ៖** តាមការស្រាវជ្រាវរបស់ខ្ញុំ ខ្ញុំមិនបានធ្វើការស្រាវជ្រាវចម្បងទៅលើកម្ពុជាប្រជាធិបតេយ្យនៅក្នុងឆ្នាំ១៩៨០ នោះទេ ទសវត្សរ៍៨០ នៅក្នុងទសវត្សរ៍ឆ្នាំ៨០ ខ្ញុំមិនបានពិនិត្យចម្បងទៅលើបញ្ហា ឌីខេនេះឡើយ។

**ស៖** តើសមាជិករបស់គណៈអចិន្ត្រៃយ៍ ឬគណៈមជ្ឈិមផ្តល់នូវទិដ្ឋភាពរួមអំពីវិសាលភាពនៃសកម្មភាពបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** គឺជាសិទ្ធិរបស់ពួកគេ ពួកគេគឺជាអ្នកគ្រប់គ្រងទៅលើគោលនយោបាយ ការបង្កើត ជាអង្គការបង្កើតគោលនយោបាយ។ ដូច្នេះ ពួកគេបាន អាចធ្វើការពិនិត្យ និងទូទៅ គ្រប់គ្រងទូទៅ ទៅលើ

ប្រទេសនាពេលនោះ ហើយក៏អាចធ្វើទំនាក់ទំនងនៅក្នុងប្រទេសផងដែរ។ ហើយពួកគេគឺមានសិទ្ធិក្នុងការគ្រប់គ្រងទៅលើប្រទេសទាំងមូលនៅពេលនោះ។

[១០:៣០:០០]

**ស៖** ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់លាស់ ថាប្រជាធិបតេយ្យប្រមូលផ្តុំ។ គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម ដែលដំណើរការងាររបស់ទាំងគណៈទាំងពីរនោះ គឺលោកបានរៀបរាប់រួចមកហើយ ហើយគឺការដំណើរការតាមប្រជាធិបតេយ្យប្រមូលផ្តុំ។ ដូច្នេះ ការអនុវត្តទាំងការប្រជាធិបតេយ្យប្រមូលផ្តុំនោះ គឺមានការអនុវត្តជាក់ស្តែងដែរឬទេ?

**ឆ៖** បាទ ខ្ញុំគិតដូច្នោះ។

**ស៖** ឥឡូវនេះ តើលោកអាចបញ្ជាក់ថា តើជនជាប់ចោទទាំងបីនោះ គឺជាសមាជិកនៃគណៈមជ្ឈិម ហើយនិងគណៈអចិន្ត្រៃយ៍ដែរឬទេ? ចម្លើយនោះ គឺថាលោកបានឆ្លើយពីខាងដើម ដោយមានការរក្សាសិន នៅថា ខៀវ សំផន នោះ លោកមិនច្បាស់ ដែលថាលោកមិនច្បាស់ថា ក្លាយជាសមាជិកនៅពេលណាទេ លោក ខៀវ សំផន នោះ?

**ឆ៖** ឯកសារនៅក្នុងសណ្ឋាគាររបស់ខ្ញុំ ប៉ុន្តែខ្ញុំៗមិនចង់ឆ្លើយដោយមិនបានមើលនោះទេ ទាក់ទងទៅនឹងលោក ខៀវ សំផន នេះ ប៉ុន្តែពីរនាក់ទៀត គឺយើងច្បាស់។

**ស៖** តើលោកអាចពន្យល់ខ្ញុំអំពីទំនាក់ទំនងរវាងគណៈអចិន្ត្រៃយ៍ ហើយនិងគណៈមជ្ឈិមបានឬទេ អំពីឋានៈ អំពីទំនាក់ទំនងទៅវិញទៅមក ហើយនិងជាសង្ខេបការងារដែលចាត់តាំងឲ្យគណៈនីមួយៗនោះ ធ្វើការនោះដូចម្តេច?

[១០:៣១:៤៧]

**ឆ៖** ខ្ញុំមិនបានសិក្សាទៅលម្អិតទេ ដូច្នេះ ខ្ញុំមិនចង់ឆ្លើយទេ។ ប៉ុន្តែវាមានការងារត្រួតគ្នារវាងស្ថាប័នទាំងពីរនេះ។ អ្វីដែលធ្វើការបែងចែកនោះ គឺថាខ្ញុំមិនបានត្រៀមឆ្លើយថ្ងៃនេះទេ។ ខ្ញុំអាចឆ្លើយនៅពេលក្រោយ ប៉ុន្តែនៅពេលនេះ ខ្ញុំមិនអាចឆ្លើយបានដោយច្បាស់ទេ។

**ស៖** សូមអរគុណ។ ហើយខ្ញុំចូលទៅដល់ប្រធានបទថ្មីមួយទៀត ខ្ញុំចង់ពិនិត្យមើលលេខ ERN ចំពោះសេចក្តីដកស្រង់ដែលខ្ញុំបានផ្តល់អំពីសម្ភាសបឋមរបស់ នួន ជា ទៅសហចៅក្រមស៊ើបអង្កេតហ្នឹង គឺខ្មែរ ERN នោះ គឺ 00148742 រហូតទៅដល់ 744, អង់គ្លេស ERN 00148817, ហើយបារាំង ERN 00148920 រហូតទៅដល់ 00148921។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ឥឡូវនេះ ខ្ញុំនឹងចូលទៅដល់ប្រធាបទមួយផ្សេងទៀត តើលោកប្រធានចង់សម្រាកពេលព្រឹកនៅពេលនេះដែរឬទេ?

[១០:៣៣:០៧]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ពេលវេលាសមល្មមសម្រាកហើយ ហើយអង្គជំនុំជម្រះ -- អរគុណលោកអ្នកជំនាញ ឥឡូវហ្នឹងដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកសមរម្យដល់អ្នកជំនាញ នៅបន្ទប់រង់ចាំសម្រាប់អ្នកជំនាញសាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មវិញ នៅពេលវេលាដែលបានកំណត់។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១០:៣៣នាទី ដល់ម៉ោង ១០:៥២នាទី)*

[១០:៥២:២៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលស្ដាប់សក្ខីកម្មអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ។ ហើយអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

សូមអញ្ជើញ!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

**ស៖** លោកសាស្ត្រាចារ្យ ឆេនដ៍ល័រ ក្នុងសៀវភៅផែនការអនាគតរបស់ ប៉ុល ពត នៅឯកសារដែលលោកបានបង្ហាញ ហើយនិងបកប្រែឯកសារលេខ៤នោះ ហើយជាឯកសារហ្នឹងបញ្ជាក់យ៉ាងច្បាស់ថា បានដកស្រង់ ឬក៏ឯកសាររបស់ ប៉ុល ពត ខ្លួនឯង។ ចំណងជើងនៃឯកសារនោះ គឺនិយាយថា "សេចក្តីពន្យល់បឋមមុននឹងអានផែនការដោយលេខាបក្ស" ហើយប្រភពនោះគឺថាគណៈមជ្ឈិមនៅថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦។ ទាក់ទងទៅនឹងសៀវភៅនេះ គេនិយាយថា សុន្ទរកថានេះត្រូវបានធ្វើឡើងក្នុងខែសីហា ឆ្នាំ១៩៧៦ នៅគណៈមជ្ឈិម។ ហើយ ERN លេខ 00104057 ក្នុងចន្លោះថ្ងៃទី២១ និង២៣ ខែសីហា ឆ្នាំ១៩៧៦ កិច្ចប្រជុំរបស់គណៈមជ្ឈិមមិនបានបញ្ជាក់ទេ ប៉ុន្តែបានបញ្ជាក់ក្រុមសមាជិកមួយចំនួនរបស់បក្សកុម្មុនីយស្តកម្ពុជាដែលប្រជុំនៅភ្នំពេញ លេខាបក្ស ប៉ុល ពត និយាយយ៉ាងវែងអំពីផែនការបួនឆ្នាំរបស់បក្ស។

[១០:៥៤:៣៣]

នៅក្នុងសុន្ទរកថា នោះ គឺមានប្រវែងដល់ទៅ៦៥ទំព័រ ខ្ញុំមិនចង់ឲ្យលោកចាំទាំងអស់នោះទេ ក៏ប៉ុន្តែនៅក្នុងនោះមានការពិភាក្សាអំពីប្រភពដើមរបស់បដិវត្តន៍កម្ពុជា ហើយល្បឿនដែលគេចង់ពន្លឿនសង្គមនិយមនុំងដោយសារថា ការវាយប្រហារពីខាងកើត និងខាងលិចនោះ គឺបានចប់ហើយ។ ហើយសុន្ទរកថានោះ ក៏បានកំណត់នូវគោលការណ៍ដើម្បីបង្កើនផលិតផលស្រូវឲ្យបានប្រាកដនិយម។ តើលោកនឹកឃើញពីឯកសារនេះដែរឬទេ? ពីខ្លឹមសារទូទៅនោះ?

[១០:៥៥:១៨]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** បាទ ខ្ញុំនៅនឹកឃើញ។

**ស៖** នៅក្នុងការប្រជុំនោះ គឺថាមានសមាជិកបក្សកុម្មុយនីស្តកម្ពុជា ក្រៅពីក្រុមដែលលោកបានយោងទៅថា ក្រុមសមាជិកដែលជ្រើសរើសនោះ ហើយលោកបាននិយាយថាអ្នកនោះខ្លះបានចូលរួមនៅក្នុងការប្រជុំ មិនបានពិភាក្សាផែនការមុនទេ ប៉ុន្តែមួយក្រុមទៀត គឺបានលើការពន្យល់ពីរដងឯណោះ។ ហើយខ្ញុំយល់ថា តើលោកយោងទៅរកក្រុមចុងក្រោយនេះថាជាក្រុមដែល ក្រុមសមាជិកបក្សកុម្មុយនីស្តកម្ពុជាដែលគេជ្រើសរើស ឬក៏ក្រុមណា?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

[១០:៥៦:០៨]

**ស៖** នៅក្នុងក្រុមដែលជ្រើសរើសនេះ ថាតើមានសមាជិកនៃគណៈមជ្ឈិម ឬក៏គណៈអចិន្ត្រៃយ៍ដែរឬទេ?

**ឆ៖** ខ្ញុំគិតថា ខ្ញុំមិនមានភស្តុតាងច្បាស់អំពីរឿងហ្នឹងទេ។ ព្រោះខ្ញុំគិតអ៊ីចឹង។

**ស៖** ឥឡូវនេះ ខ្ញុំនឹងចូលទៅរកអំពីកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ដែលមិនបានដាក់បញ្ចូលទៅក្នុងសៀវភៅដែលនិយាយថា ប៉ុល ពត -- "ផែនការអនាគតរបស់ប៉ុល ពត" គឺឯកសារនោះ គឺ E3/127 គឺថា ERN -- IS ខ្មែរ ERN 0000736 រហូតទៅដល់ 734, អង់គ្លេស ERN 00182635 រហូតទៅដល់ 2637, បារាំង ERN 00334964 រហូតទៅដល់ 4966 ដែលមានចំណងជើងថា "កំណត់ត្រាអង្គប្រជុំនៃគណៈអចិន្ត្រៃយ៍ ថ្ងៃទី១១ មីនា ឆ្នាំ១៩៧៦" ហើយដែលលោក នួន ជា បានចូលរួមជា -- ខៀវ សំផន និងអៀង សារី ក៏បានចូលរួមដែរ។ នៅក្នុងកិច្ចប្រជុំនោះ បញ្ហាជាមួយវៀតណាមនៅភូមិ -- នៅព្រំដែនខាងកើតក៏បានពិភាក្សា គឺមានមតិអង្គការត្រូវបានផ្តល់នោះដែរហើយ។ ហើយគឺមានឯកសារស្រដៀងនោះផងដែរ គឺ E3/229 ហើយនិងកំណត់ត្រានៃកិច្ចប្រជុំអចិន្ត្រៃយ៍ពេលល្ងាចថ្ងៃទី២២ កុម្ភៈ ឆ្នាំ១៩៧៦ ហើយកំណត់ត្រានោះក៏បាននិយាយថា "មានជនជាប់ចោទទាំងបីបានចូលរួមចូលរួមផងដែរ។ ហើយនិយាយអំពីការការពារជាតិ ហើយទទួលការណែនាំ ហើយនិងយោបល់អំពីអង្គការផងដែរ"។

[១០:៥៨:១៩]

ការប្រជុំមួយទៀតនៃគណៈអចិន្ត្រៃយ៍នោះ គឺបានធ្វើឡើងនៅព្រឹកថ្ងៃទី១៤ ឧសភា ឆ្នាំ១៩៧៦ ឯកសារ E3/2221 ហើយក៏បាននិយាយអំពីកត់ត្រាពីវត្តមានរបស់ជនជាប់ចោទផងដែរ។ ហើយនិយាយអំពីព្រំដែនសមុទ្រ ហើយនិងសេចក្តីពន្យល់ និងការណែនាំដោយ ប៉ុល ពត ដោយមានការមតិសង្ខេបដោយ អៀង សារី។ អ៊ីចឹងសេចក្តីសង្ខេបខ្លីអំពីកំណត់ហេតុទាំងបីនេះ អំពីបរិបទនៃប្រជុំនេះ តើពាក្យ "អង្គការ" យោងទៅរកតែ ប៉ុល ពត ឬក៏អាចមានន័យទូលំទូលាយ ហើយអាចដាក់បញ្ចូលទាំងសមាជិកផ្សេងទៀតរបស់បក្សកុម្មុយនីស្តកម្ពុជាផងដែរ?

**ឆ៖** នេះជាសំណួរណាស់ ហើយខ្ញុំមានការល្អណាស់ ខ្ញុំពិបាកឆ្លើយ ប៉ុន្តែសំខាន់នេះជាឯកសារដែល ប៉ុល ពត ហៅខ្លួនឯងថា "អង្គការ"។ ប៉ុន្តែនៅក្នុងគំនិតទីពីរ ខ្ញុំយល់ថា ពាក្យនៅក្នុងបរិបទនេះបញ្ជាក់ថាសេចក្តីសម្រេចធ្វើឡើងនៅក្នុងកិច្ចប្រជុំនោះ គឺធ្វើឡើងដោយសមូហភាព ដោយអង្គការខ្លួន

ឯង មិនមែនថាដោយមនុស្សនៅក្នុងប្រជុំនោះទេ។ នេះគឺ គេហៅ ប៉ុល ពត ថាអង្គការហ្នឹងគឺជា និង ជាគំនិតមួយដែលមិនសមស្រប។ ប៉ុន្តែមិនមានភស្តុតាងជាក់ស្តែងនោះទេ នេះជាសេចក្តីសន្និតរបស់ខ្ញុំ។

[១១:០០:០០]

**ស៖** ឯកសារមួយទៀតដែលខ្ញុំចង់ឲ្យលោកផ្តល់យោបល់ដែរ គឺកំណត់ត្រាកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍នៅថ្ងៃទី២៦ មីនា ឆ្នាំ១៩៧៦។ កំណត់ហេតុនោះនិយាយថា កិច្ចប្រជុំនោះគឺ អធិបតីរបស់ នួន ជា ហើយ ខៀវ សំផន បានចូលរួមផង។ ឯកសារនោះគឺ E3/218។ នៅក្នុងកិច្ចប្រជុំនោះ យ៉ា បាន ផ្តល់របាយការណ៍យ៉ាងលម្អិតអំពីការចរចាជាមួយវៀតណាម ទាក់ទងព្រំដែនខាងកើត។ ហើយក្នុងកំណត់ហេតុនេះ នួន ជា ជាអនុលេខាបានផ្តល់ការណែនាំ និងយោបល់មួយចំនួនស្តីពីការចរចាជាមួយវៀតណាម ដោយរាប់បញ្ចូលទាំងការបញ្ជាឲ្យការប្រើមីន។ នៅក្នុងERN អង់គ្លេសនោះគឺ 00182657 ហើយនិងការលិចនូវកាណូតវៀតណាមមួយចំនួន។

នួន ជា គេបានដកស្រង់នៅក្នុងកំណត់ហេតុនោះថា “ជាមួយវៀតណាម បញ្ហារបស់យើងគឺមិនចេះចប់ទេ យើងត្រូវតែរួមការតស៊ូនយោបាយ និងការទូត ហើយនិងកម្លាំងយោធារួមគ្នា”។ តើកំណត់ត្រានេះ និយាយពីអង្គប្រជុំនេះ គឺស្របទៅនឹងការវាយតម្លៃរបស់ នួន ជា ដោយខ្លួនឯងដែលនិយាយថា អ្នកនយោបាយ ដែលគាត់ជាអ្នកនយោបាយដែរនោះ គឺមានអំណាចនេះខ្ពស់ជាង -- អំណាចតិចជាងខាងយោធាឬ?

[១១:០១:៥៣]

**ឆ៖** នេះគឺវាអាចផ្ទុយទៅនឹងការឆ្លើយ ឬក៏ -- ខាងដើម។

**ស៖** នៅក្នុងដីកាដំណោះស្រាយ ឯកសារ D247, អង់គ្លេស ERN 00604548 ដល់ 49, ខ្មែរ ERN 00605300 រហូតទៅដល់ 5302, ហើយបារាំង ERN 00624175 រហូតទៅដល់ 176។ សហចៅក្រមស៊ើបអង្កេតបានកំណត់នយោបាយប្រាំ ដែលគេយល់ថា ត្រូវបានតាក់តែងឡើង ហើយអនុវត្តដោយជនជាប់ចោទទាំងបី ហើយនិងសមាជិកបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀត។

នយោបាយទាំងប្រាំនោះមាន៖ ទី១) ការផ្លាស់ទីលំនៅដែលធ្វើឡើងច្រើនលើកច្រើនសានៅលើប្រជាជនចេញទៅតំបន់ជនបទ និងពីជនបទមួយទៅជនបទមួយផ្សេងទៀត។ ទី២) ការបង្កើត និងការទាញយកផលប្រយោជន៍ តាមរយៈសហករណ៍ និងតាមការដ្ឋាន។ ៣) ការអប់រំសមាសភាពមិនល្អ និងការកម្ទេចខ្មាំងដែលត្រូវបានរកឃើញក្នុងនិងក្រៅបក្ស។ ៤) ការចេញនូវវិធានការជាពិសេសចំពោះ

ក្រុមមនុស្សជាក់លាក់នានា ដូចជា ជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិកជន និងអតីតអ្នករដ្ឋការនៃសាធារណរដ្ឋខ្មែរ រួមទាំងមន្ត្រីរាជការ អតីតបុគ្គលិកយោធា និងក្រុមគ្រួសាររបស់គេ។ ហើយ និងទី៥) គឺការដាក់បញ្ហាទាក់ទងនឹងការរៀបការដោយបង្ខំ។ តាមអ្វីដែលលោកយល់ តើលោកយល់ថា នេះជា៦នយោបាយសំខាន់ ឬមិនសូវសំខាន់ ដែលត្រូវបានបង្កើត និងអនុវត្តដោយបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

[១១:០៣:៥៣]

**ឆ៖** ខ្ញុំគិតថាវាគឺជាគោលនយោបាយសំខាន់ៗមែន។ ជាពិសេសខ្ញុំគិតថា នៅគោលនយោបាយបីដំបូង វាសំខាន់ណាស់។ ទី៤, ទី៥ នោះគឺមិនសូវសំខាន់ខ្លាំងទេ ក៏ប៉ុន្តែជាគោលនយោបាយសំខាន់ផងដែរ។

**សៈ** តើលោកអាចនិយាយតាមការស្រាវជ្រាវរបស់លោកដែរឬទេ ថាតើអំឡុងពេលណាដែរដែលគេបង្កើតគោលនយោបាយនេះ? ហើយអង្គការណាមួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យជាអ្នកបង្កើត ឬក៏បុគ្គលណាមួយជាអ្នកបង្កើតគោលនយោបាយទាំងនេះ?

**ឆ៖** ខ្ញុំគិតថា យើងប្រាកដជាមិនអាចរកថាបុគ្គលណា ជាអ្នកបង្កើតគោលនយោបាយទាំងនេះទេ វាគឺជាគោលនយោបាយជាតិទាំងមូលនៅក្នុងឆ្នាំ១៩៧៥ នៅទីក្រុង -- ទីរួមខេត្តមួយចំនួនដូចជា ឧដុង្គនិងក្រចេះ។ គោលនយោបាយទាំងអស់នោះត្រូវបានគេយកមកអនុវត្តដូចគ្នា នៅក្នុងការអនុវត្តសហករណ៍នោះឯង។

[១១:០៥:០៤]

ហើយគេយកទៅអនុវត្តនៅក្នុងតំបន់ខាងពាយ័ព្យខាងនិរតីជាតំបន់រំដោះក្នុងឆ្នាំ១៩៧៣។ ហើយការតាមរកសមាសភាពមិនល្អនោះ គឺជាកម្មវិធីរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយគេមិនបានអនុវត្តទេ រហូតដល់ជ័យជម្នះលើក្រុម លន់ នល់ នៅថ្ងៃទី១៧ ខែមេសា ដែលពេលនោះគេចាប់ផ្តើមធ្វើការកំណត់សមាសភាពមិនល្អ លន់ នល់។ ការកំណត់ជនជាតិវៀតណាម ជនជាតិចាមទាំងអស់នោះ ខ្ញុំហាក់ដូចជាមានការវិលវល់ និងច្រឡូកច្រឡំទៅនឹងការកំណត់គោលដៅពុទ្ធសាសនិកជន ដែលក្នុងនោះមានព្រះសង្ឃ និងប្រជាជនជាពុទ្ធសាសនិកជន។ ក៏ប៉ុន្តែជនជាតិចាមត្រូវបានគេកំណត់គោលដៅតាំងពីដំបូង ហើយចំពោះការដាក់បញ្ហាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍នោះគឺខ្ញុំមិនគិតថា គោលនយោបាយនេះអនុវត្តចូលជាធរមាន នៅមុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ នោះទេ។

[១១:០៦:២៦]

គោលនយោបាយពីរដំបូងអនុវត្តនៅក្នុងឆ្នាំ១៩ -- មុនឆ្នាំ១៩៧០ -- ការអនុវត្តគោលនយោបាយពីរដំបូង គឺធ្វើឡើងនៅក្នុងឆ្នាំ១៩៧៥ ហើយក្រោយមកទៀតគោលនយោបាយទាំងបីផ្សេងនោះ គឺធ្វើឡើងក្រោយឆ្នាំ១៩៧៥។

**ស៖** គោលនយោបាយទាំងប្រាំ ដែលខ្ញុំយោងអម្បាញ់មិញនោះ ផ្អែកតាមការស្រាវជ្រាវរបស់លោក ថាតើគោលនយោបាយទាំងអស់នោះ ត្រូវបានគេបោះពុម្ពផ្សាយជាទូទៅ ហើយពន្យល់ជាទូទៅទៅដល់សមាជិកបក្សកុម្មុយនីស្តកម្ពុជាទូទៅ និងប្រជាជនកម្ពុជាទាំងអស់ដែរឬទេ?

**ឆ៖** គឺគេបានពន្យល់ចំពោះប្រជាជនកម្ពុជាទូទៅទាំងអស់នោះ គឺគេត្រូវបានពន្យល់នៅក្នុងពេលប្រជុំដូចជា ប្រជុំក្នុងតំបន់ ក្នុងសហករណ៍ ភូមិភាគជាដើម ហើយចំពោះគោលនយោបាយនៅក្នុងសមាជិកទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជានោះគឺគេស្ថិតនៅតាមឋានៈថ្នាក់របស់គេ។ ដូច្នេះហើយគេទទួលបាននូវការផ្តល់ព័ត៌មានខ្លះៗទៅលើគោលនយោបាយទាំងអស់នេះ។ គោលនយោបាយមួយចំនួនត្រូវបានគេពន្យល់នៅក្នុងទស្សនាវដ្តីរបស់បក្ស ទង់បដិវត្ត។ ដូច្នេះហើយលំហូរនៃព័ត៌មានទាំងអស់នេះត្រូវបានគ្រប់គ្រងដោយរបបនោះ។

ខ្ញុំសូមនិយាយនៅក្នុងន័យម៉្យាងទៀត គឺគេមិនមានការពិភាក្សាគ្នាជាចំហអំពីគោលនយោបាយទាំងអស់នោះទេ លើកលែងតែនៅក្នុងការប្រជុំថ្នាក់ខ្ពស់ ដែលមានឯកសារបង្ហាញថា មានការពិភាក្សាអំពីគោលនយោបាយទាំងអស់នេះ។ ទាំងអស់នេះហើយគឺជាអ្វីដែលខ្ញុំបានស្រាវជ្រាវ ខ្ញុំមិនមានឯកសារថ្នាក់នៅក្នុងកម្រិតថ្នាក់ខ្ពស់ ដែលគេនិយាយអំពីការរៀបអាពាហ៍ពិពាហ៍នោះទេ ក៏ប៉ុន្តែនិយាយជាទូទៅមេដឹកនាំនោះគឺ គាត់ចង់ធ្វើការងារអ្វីដែលគេធ្វើនោះ គឺគេនឹងដាក់ជូន -- គេនឹងដាក់មកដាក់ក្រោមឱ្យថ្នាក់ក្រោមអនុវត្ត។ ហើយទោះបីយ៉ាងណាក៏ដោយ គេក៏មិនមានចែងឱ្យបានច្បាស់លាស់ថា វាជាគោលនយោបាយមួយដែលគេកំណត់យ៉ាងច្បាស់នៅក្នុងការអនុវត្តជីវភាពប្រចាំថ្ងៃនោះទេ។

[១១:០៨:៥៤]

**ស៖** ចំណុចចុងក្រោយ ខ្ញុំចង់ឱ្យលោកធ្វើការពន្យល់លើចម្លើយរបស់លោក ចុងក្រោយអម្បាញ់មិញ ពាក់ព័ន្ធទៅនឹងប្រព័ន្ធទំនាក់ទំនងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ លោកបានលើកឡើងអំពីទស្សនាវដ្តីទង់បដិវត្ត។ តើទស្សនាវដ្តីទង់បដិវត្តនេះ បានផ្សព្វផ្សាយទូទៅដូចនឹងទង់យុវជនបដិវត្តដែរឬទេ?

**ឆ៖** ទស្សនាវដ្ដីទង់បដិវត្ត យុវជនបដិវត្ត គឺកំណត់តែ -- ចែកជូនតែសមាជិកបក្ស ហើយខ្ញុំគិតថា -- មិនគិតថា គ្រប់សមាជិកទាំងអស់នោះទទួលបានឯកសារនេះ មួយច្បាប់ៗម្នាក់នោះទេ ហើយចំពោះអ្នកនៅខាងក្រៅទៀតនោះ គឺគេមិនបានទទួលទស្សនាវដ្ដីទង់បដិវត្តនេះនោះឡើយ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរសួរលោក ដេវីដ ឆេនដ៍ល័រ ហើយ។

[១១:០៩:៥០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីចៅក្រម។ ហើយជាកិច្ចបន្ត ដោយអនុវត្តតាមវិធាន៩០ នៃវិធាន -- និងវិធាន៩១ នៃវិធានផ្ទៃក្នុង អ.វ.ត.ក និងសេចក្ដីសម្រេចលើការចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១២ របស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E215 អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ មុនភាគីដទៃទៀត។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១១:១០:៣២]

**លោក ច័ន្ទ តារាវស្នី៖**

បាទ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមគោរពអស់លោក លោកស្រីដែលមានវត្តមាននៅក្នុងសវនាការនាពេលនេះទាំងអស់។ ជម្រាបសួរលោក *ប្រូហ្វេសស៊័រ* ដេវីដ ឆេនដ៍ល័រ។ ខ្ញុំបានឈ្មោះ ច័ន្ទ តារាវស្នី ជាសហព្រះរាជអាជ្ញារងជាតិនៃអង្គជំនុំជម្រះនៅក្នុងសាលាក្ដីខ្មែរក្រហមនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ច័ន្ទ តារាវស្នី៖**

**ស៖** ខ្ញុំសូមអនុញ្ញាតសួរលោកអ្នកជំនាញ ទាក់ទិននឹងសំណួរមួយចំនួន។ ពិតមែនតែសំណួរខ្លះត្រូវបានលោក លោកស្រីចៅក្រម លោកប្រធានបានសួររួចហើយ ប៉ុន្តែខ្ញុំសូមអនុញ្ញាតសួរបន្ថែមទៀត ដើម្បីឲ្យលោកបញ្ជាក់កាន់តែច្បាស់ទៅលើចំណុចទាំងឡាយ ដែលខ្ញុំមានបំណងសួរលម្អិតទាក់ទងទៅនឹងអ្វីដែលខ្ញុំចង់សួរនៅពេលនេះបាទ។

ជាដំបូងខ្ញុំសូមសួរទាក់ទងទៅនឹងកម្រិតនៃការសិក្សារបស់លោក នៅក្នុងសាកលវិទ្យាល័យ។ តាមឯកសារបានបង្ហាញថា លោកធ្លាប់បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រភាសាអង់គ្លេសពីសាកលវិទ្យាល័យហាវើដ នៅឆ្នាំ១៩៥៤។ តើពិតប្រាកដដែរឬទេបាទ?

[១១:១១:៣៧]

**លោក ឆេវីដ ឆេនឌ័ល័រ៖**

**ឆ៖** ពិតដូច្នេះមែន។

**ស៖** អរគុណ។ បន្ទាប់មកលោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជាបន្តទៀតមែនទេបាទ?

**ឆ៖** ខ្ញុំបានសិក្សាផ្នែកការសិក្សាអំពីតំបន់អាស៊ីអាគ្នេយ៍នៅសាកលវិទ្យាយ៉ែល។

**ស៖** សូមអរគុណ។ ខ្ញុំសូមបញ្ជាក់លោកអំពីពាក់ព័ន្ធនឹងបញ្ហាមួយចំនួន ដែលលោកទៅសិក្សាស្រាវជ្រាវនៅក្នុងសាកស -- នៅក្នុងសាកលវិទ្យាល័យម៉ូណាស នៅប្រទេសអូស្ត្រាលី នៅក្នុងឆ្នាំ២០០៤ ដល់ឆ្នាំ២០១១។ តើការស្រាវជ្រាវរបស់លោកហ្នឹង គឺផ្ដោតទៅលើប្រធានបទអ្វីបាទ?

[១១:១២:៣៣]

**ឆ៖** មិនមានការស្រាវជ្រាវជាក់លាក់នោះទេ គឺជាការស្រាវជ្រាវកិត្តិយស គឺគ្រាន់តែខ្ញុំធ្វើការគ្រប់គ្រងទៅលើការងារសិស្ស និស្សិតដែលចូលរួមនៅក្នុងវគ្គសិក្ខាសាលា និងការបង្រៀនមួយចំនួន ហើយគឺមានការស្រាវជ្រាវមួយចំនួន ដែលខ្ញុំចាប់អារម្មណ៍។ ក៏ប៉ុន្តែគឺមិនមានបុគ្គលណាមួយ សមាជិកណាមួយបង្គាប់បញ្ជាឲ្យខ្ញុំធ្វើការស្រាវជ្រាវជាក់លាក់ទៅលើប្រធានបទអ្វីនោះឡើយ។

**ស៖** សូមអរគុណ។ ខ្ញុំបានស្ដាប់ឮលោកស្រីចៅក្រម បានសួរបញ្ជាក់អំពីស្នាដៃរបស់លោកដែលបាន -- លោកប្រធានបានសួរទាក់ទងទៅនឹងស្នាដៃរបស់លោកដែលបានបោះពុម្ពផ្សាយ សៀវភៅសំខាន់ៗ ចំនួន៥។ តើសៀវភៅទាំងអស់នោះ លោកបានសិក្សាស្រាវជ្រាវផ្អែកទៅលើឯកសារ ឬក៏ប្រភពណាខ្លះ? បាទសូមអរគុណ។

[១១:១៣:៣៨]

**ឆ៖** សូមអរគុណ។ ជាការពិតប្រភពលាយឡំនៃឯកសារទាំងឡាយ ដែលខ្ញុំបានបង្ហាញនៅក្នុងតុលាការនេះមានលក្ខណៈខុសគ្នា។ សៀវភៅវា -- សៀវភៅទាំងឡាយនោះមិនបានសរសេរនៅក្នុងសៀវភៅ “ប្រវត្តិសាស្ត្រកម្ពុជា” របស់ខ្ញុំ ដែលបានបោះពុម្ពនៅក្នុងឆ្នាំ១៩៨៣នោះទេ គឺខ្ញុំបានមើលនៅ

ក្នុងបណ្ណសារបារាំង អាមេរិក បារាំង។ សៀវភៅទីពីរ “ប៉ុល ពត រៀបចំផែនការអនាគត” គឺយើងសរសេរផ្អែកទៅលើឯកសារដោយផ្ទាល់ ទៅតាមឯកសារដែលយើងស្រាវជ្រាវតាមដែលអាចធ្វើទៅបាន។ សៀវភៅ “បងធំទី១” សូមអធ្យាស្រ័យ “សោកនាដកម្មកម្ពុជា” សៀវភៅទីបីនេះ គឺជាសៀវភៅដែលទាមទារឲ្យមានប្រភពឯកសារជាច្រើន យកមកពីបណ្ណសារបរទេស បារាំង អាមេរិក អូស្ត្រាលី អង់គ្លេស និងកិច្ចសម្ភាសន៍ជាច្រើនទៀត និងស្នាដៃបន្ទាប់បន្សំ រួមទាំងសារព័ត៌មានផងដែរ។ ហើយក្នុងនោះគឺខ្ញុំមានមើលលិខិតឆ្លើយឆ្លងទូតអាមេរិក និងកិច្ចសម្ភាសន៍រាប់រយទៀតចំពោះបុគ្គលដែលបានចូលរួមសិក្សាពិភាក្សាទៅលើប្រវត្តិសាស្ត្រកម្ពុជានៅក្នុងឆ្នាំ១៩៤៥ ទៅដល់ឆ្នាំ៧៩។

[១១:១៥:២០]

សៀវភៅវែង ដែលវែងមួយរបស់ខ្ញុំនោះ គឺមានប្រភពច្រើនណាស់ ហើយសៀវភៅ “បងធំទីមួយ” នេះ គឺវាមានឯកសារប្រភពជាន់គ្នាទៅនឹងសៀវភៅមុនៗ ក៏ប៉ុន្តែវាមានកិច្ចសម្ភាសន៍មួយចំនួនផ្សេងចេញមកពីបុគ្គល ដែលគាត់ជាអ្នកដឹងដោយផ្ទាល់ទៅលើប្រវត្តិរបស់ ប៉ុល ពត។ ហើយយើងមានឃើញប្រភពមួយចំនួនផ្សេងពីសៀវភៅមុនៗ។ ចំពោះសៀវភៅ “សំឡេងពីមន្ទីរ ស-២១” ប្រភពចម្បងដែលឯកសារដែលខ្ញុំផ្អែកនោះ គឺចេញមកពីមន្ទីរ ស-២១ ហើយនិងក្នុងនោះ ក៏មានកិច្ចសម្ភាសន៍ -- ឯកសារសម្ភាសជាមួយនឹងអ្នករស់រានមានជីវិត និងបុគ្គលិកនៅ ស-២១ ហើយនិងកិច្ចសម្ភាសន៍ជាមួយបុគ្គលមួយចំនួនទៀតដែលពាក់ព័ន្ធធ្វើការងារនៅក្នុងមន្ទីរ ស-២១។

[១១:១៦:២៤]

ខុសពីសៀវភៅផ្សេងៗទៀត សៀវភៅនេះគឺខ្ញុំបានព្យាយាមបង្កើតការប្រៀបធៀបរវាងការសិក្សាមន្ទីរ ស-២១ ទៅនឹងឯកសារបន្ទាប់បន្សំផ្សេងទៀត។ ជាពិសេសទៅលើឯកសារ ហាយនភាព និងកំណែទម្រង់របស់ស្តាលីន នៅអ៊ុយក្រែន និងបញ្ហាទ្រឹស្តីស្តាលីន នៅរុស្ស៊ី នៅសហភាពសូវៀតជាដើម។ ឯកសារមួយចំនួន គឺខ្ញុំផ្អែកទៅលើឯកសារមកពីរបបនៃនៅក្នុងប្រទេសអាហ្សង់ទីនផងដែរ។ ដូច្នេះ គឺឯកសារមួយចំនួននោះ ខ្ញុំបានអនុវត្តទៅតាមលក្ខខណ្ឌតេស្តដែលខ្ញុំមិនធ្លាប់ធ្វើពីមុនមក ហើយយើងឃើញមានប្រភពថ្មីៗជាច្រើននៅក្នុងនោះ។ សៀវភៅចុងក្រោយរបស់ខ្ញុំនោះ គឺផ្អែកទៅលើឯកសារចម្បងៗជាច្រើន។

**សះ** អរគុណលោកសាស្ត្រាចារ្យ។ ខ្ញុំសូមបញ្ជាក់បន្ថែមត្រង់ចំណុចនេះទៀតថាតើក្នុងចំណោមសៀវភៅដែលលោកបានសរសេរទាំងអស់នុ៎ង តើលោកមានបានធ្វើសម្ភាសជាមួយនឹងជនភៀសខ្លួនខ្មែរ

នៅជំរំខាវអ៊ីដាង នៅព្រំដែនកម្ពុជា-ថៃ ដែរឬទេបាទ?

[១១:១៧:៥៤]

**ឆ៖** បាន ខ្ញុំបានសម្ភាស ខ្ញុំត្រូវបានអញ្ជើញដោយ យូ.អ៊ិន.អេច.ស៊ី.អ័រ នៅឆ្នាំ១៩៩៤ ដែលគេអញ្ជើញខ្ញុំឱ្យទៅសម្ភាសអ្នកជាជនភៀសខ្លួន ដែលបានជ្រើសរើសដោយបុគ្គលមកពីសហរដ្ឋអាមេរិក។ ហើយនិងសម្ភាសសមាជិកខ្មែរក្រហមមួយចំនួន ដែលត្រូវបានគេបញ្ជូនទៅប្រទេសទីបី។ ខ្ញុំបានធ្វើកិច្ចសម្ភាសន៍៣០០ ប្រហែលជា៣០០នៅពេលនោះ។ ដែលអ្នកជនភៀសខ្លួនព្យាយាមបង្ហាញអំពីប្រវត្តិរបស់គេ និងស្ថានភាពរបស់គេ។ ដូច្នេះគឺខ្ញុំគិតថា វាជាចំណុចមួយចាប់អារម្មណ៍ទៅលើការសម្ភាសទាំងអស់នោះ ហើយជាការមួយល្អដែលខ្ញុំបាននិយាយភាសាខ្មែរ និយាយជាមួយនឹងបុគ្គលមួយចំនួននៅពេលនោះ។

**ស៖** អរគុណលោកសាស្ត្រាចារ្យ។ សំណួរមួយទៀត គឺខ្ញុំសូម--

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក គង់ សំអុន៖**

សូមអធ្យាស្រ័យលោកប្រធាន ខ្ញុំបាទសូមសហព្រះរាជអាជ្ញាបញ្ជាក់សាជាថ្មីចំពោះចម្លើយអំមិញ ខ្ញុំបាទស្តាប់ឮថា គាត់សម្ភាសឆ្នាំ៩៤ អ៊ីចឹងសូមបញ្ជាក់ថា តើឆ្នាំហ្នឹងពិតប្រាកដ ឬមួយមានការបកប្រែច្រឡំបាទ សូមអធ្យាស្រ័យ។

[១១:១៩:២៦]

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញា បញ្ជាក់ពីកាលបរិច្ឆេទ!

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមជម្រាបលោកប្រធាន សូមជម្រាបគូភាគីនៃរឿងក្តី គឺថាខ្ញុំបានសួរសំណួរនេះ គឺទាក់ទិនទៅនឹងព្រឹត្តិហេតុដែលកើតឡើងនៅក្នុងឆ្នាំ១៩៨៤ គឺថាតើលោក ដេវីដ ឆេនដ៍ល័រ បានសម្ភាសជនភៀសខ្មែរនៅជំរំខាវអ៊ីដាង ដែរឬទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបន្ត គ្រាន់តែបញ្ជាក់ពីកាលបរិច្ឆេទ ព្រោះមានការមិនច្បាស់ ព្រោះ៩៤ ហ្នឹងគឺ

ត្រូវបានធ្វើមាតុភូមិនិវត្តន៍អស់ហើយ មិនមានជំរំនៅតាមព្រំដែនទៀតទេ។ អ៊ីចឹងហើយបានជាមានការបញ្ជាក់បញ្ហានេះ។

សូមអញ្ជើញតាំងសំណួរបន្ត!

**លោក ច័ន្ទ តារាវស្នី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតបន្តសួរទៅលោក ដេវីដ ឆេនដ៍ល័រ។

**សួរដោយលោក ច័ន្ទ តារាវស្នី៖**

**ស៖** លោកដេវីដ ឆេនដ៍ល័រលោកអាចបញ្ជាក់បានទេថា តើក្នុងអំឡុងពេលនៃការសិក្សាស្រាវជ្រាវអំពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា និងសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យបានដែរឬទេ? ថាតើលោកប្រើរយៈពេលនៃការសិក្សាហ្នឹង ទាក់ទិននឹងប្រធានបទហ្នឹង តើលោកសិក្សាស្រាវជ្រាវទៅលើអ្វីជាសំខាន់បាទ?

[១១:២០:៤៥]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំដូចជាមិនច្បាស់ទេ ក្នុងនាមជាប្រវត្តិវិទូ។ ខ្ញុំមិនដឹង-- ខ្ញុំមាននិក្ខេបបទចម្បងមួយ ដែលខ្ញុំត្រូវស្រាវជ្រាវឲ្យបានត្រឹមត្រូវ ជាពិសេសទៅលើការរៀបរាប់ក្នុងឆ្នាំដែលខ្មែរក្រហមកាន់កាប់អំណាច។ និក្ខេបបទរបស់ខ្ញុំគឺៗវាមានលក្ខណៈចំហជាភស្តុតាង តាមដែលអាចខ្ញុំធ្វើទៅបាន។ ហើយខ្ញុំធ្វើការប្រឹក្សាយោបល់ និងពិភាគ-- ពិនិត្យមើលទៅលើឯកសារជាច្រើន ដើម្បីឲ្យខ្ញុំយល់បញ្ជាក់បំភ្លឺទៅលើប្រវត្តិសាស្ត្រទាំងអស់នោះ។ នៅក្នុងលេខទំព័រ-- លេខជើងទំព័ររបស់ខ្ញុំ ខ្ញុំបានបញ្ជាក់ឆ្នាំដែលខ្ញុំសរសេរគឺក្នុងឆ្នាំមួយពាន់ប្រាំបួនរយ-- ទសវត្សរ៍ឆ្នាំ១៩៨០ ហើយខ្ញុំបានមើលឯកសារជាច្រើន ដែលចេញមកពីដីកាដំណោះស្រាយ វាជាការល្អ ដែលខ្ញុំគួរតែយកចំណុចទាំងអស់នោះបញ្ចូលទៅក្នុងឯកសារស្រាវជ្រាវរបស់ខ្ញុំ។ យើងឃើញមានករណីសៀវភៅពាក់ព័ន្ធទៅនឹង ប៉ុល ពត សៀវភៅពាក់ព័ន្ធនឹង ស-២១ វាមិនមែនជាប្រវត្តិសាស្ត្រទាំងមូលនោះទេ គ្រាន់តែខ្ញុំព្យាយាមវិភាគទៅលើប្រតិបត្តិការនៃមន្ទីរនោះ ដែលវាជាចំណុចមួយថ្មីនៅក្នុងការសរសេរសៀវភៅរបស់ខ្ញុំ។ វាមិនមែនជាការរៀបរាប់លម្អិតនោះទេនៅក្នុងសៀវភៅចុងក្រោយ។ និក្ខេបបទទ្រឹស្តីនៅក្នុងសៀវភៅទាំងអស់នោះ គឺដើម្បីបង្ហាញឲ្យបានច្បាស់លាស់ថា មានអ្វីកើតឡើងនៅក្នុងរយៈកាលប្រវត្តិសាស្ត្រនោះ ជាពិសេសនៅក្នុងប្រតិបត្តិការនៃមន្ទីរ ឬស្ថាប័នមួយនេះ។

[១១:២២:៤៣]

**ស៖** អរគុណលោកសាស្ត្រាចារ្យ។ ចំពោះសំណួរបន្តទៀត ថាតើលោកបានសិក្សាអំពីខ្មែរក្រហម និងបក្សកុម្មុយនីស្តកម្ពុជាចាប់តាំងពីពេលណាមក? ការសិក្សាទាក់ទងទៅនឹងខ្មែរក្រហម ហើយនិងបក្សកុម្មុយនីស្តកម្ពុជាហ្នឹង លោកបានសិក្សាចាប់តាំងពីពេលណាមក? ហើយលោកផ្តោតជាសំខាន់ទៅលើចំណុចណាខ្លះដែលជាចំណុចសំខាន់នៅក្នុងការសិក្សាស្រាវជ្រាវរបស់លោក?

**ឆ៖** ខ្ញុំគិតថា ឆ្នាំ១៩៧៥, ៧៦ ខ្ញុំមានការឆ្ងល់ថាមានការកើតឡើងអ្វីនៅក្នុងប្រទេសកម្ពុជា ជាពិសេសចំពោះប្រជាជននៅក្នុង និងក្រៅប្រទេស។ ខ្ញុំមានការងឿងឆ្ងល់ថាតើមានអ្វីកើតឡើង។ ខ្ញុំបានធ្វើការសម្ភាសជាមួយនឹងជនភៀសខ្លួន ដែលបានទៅប្រទេសអូស្ត្រាលី ហើយគេអាចប្រាប់ខ្ញុំបន្តិចបន្តួចអំពីរបបសម័យនោះ។ ខ្ញុំបានសរសេរអត្ថបទព្រាងមួយ ដែលបង្ហាញថាតើមានស្ថានភាពអ្វីកើតឡើងនៅប្រទេសកម្ពុជា។ នៅក្នុងឆ្នាំ១៩៧៦, ៧៧ ឯកសារជាច្រើនបង្ហាញកាន់តែច្បាស់។ ខ្ញុំមិនបានសរសេរច្រើនទៅលើបញ្ហាខ្មែរក្រហមនោះទេ។ ខ្ញុំគួរតែសរសេរឲ្យបានច្រើននៅពេលនោះ ក៏ប៉ុន្តែវាមិនច្បាស់លាស់ចំពោះខ្ញុំថាមានស្ថានភាពអ្វីកើតឡើងនៅពេលនោះ។ មានសន្និសីទមួយបានរៀបចំជាលើកដំបូង ហើយខ្ញុំបានគិតទៅលើឯកសារពាក់ព័ន្ធទាំងអស់នេះ។ ហើយខ្ញុំបានធ្វើការពិចារណាពិភាក្សាៗជាមួយនឹង ប៉ែន យៀរនិន ដែលជាអ្នកត្រួតពិនិត្យផ្ទាល់ទៅលើការសិក្សារបស់ខ្ញុំនៅប្រទេសថៃក្នុងឆ្នាំ១៩៩១។ ហើយមានសៀវភៅមួយពាក់ព័ន្ធទៅនឹងបដិវត្តន៍ក្រោយពីគ្រោះថ្នាក់នៅក្នុងប្រទេសកម្ពុជា ហើយនៅក្នុងសៀវភៅនោះនិយាយអំពីស្ថានភាពប្រជាជននៅក្នុងប្រទេសកម្ពុជា។

[១១:២៤:៥២]

ចាប់ពីពេលនោះមក ពីឆ្នាំ១៩៨១ មក ខ្ញុំបានផ្អែកការស្រាវជ្រាវរបស់ខ្ញុំទៅលើរយៈកាលខ្មែរក្រហម ដោយបានបន្ថែមជំពូកមួយនៅក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់ខ្ញុំ ដែលជំពូកនោះ និយាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ ខ្ញុំគិតថា យើងអាចលើកឡើងថា ការចាប់អារម្មណ៍របស់ខ្ញុំទៅលើរបប សរសេររបបនោះ គឺចាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយមានការស្រាវជ្រាវម៉ត់ចត់នូវ--ធ្វើឡើងនៅក្នុងដើមទសវត្សរ៍ឆ្នាំ១៩៨០។

**ស៖** អរគុណ សាស្ត្រាចារ្យ។ សំណួរបន្តទៀត ខ្ញុំសូមសួរលោកថា ក្នុងការសិក្សាស្រាវជ្រាវអំពីខ្មែរក្រហម តើលោកបានចំណាយពេលសរុបប៉ុន្មានឆ្នាំ នៅក្នុងការសិក្សាស្រាវជ្រាវនេះ ទាក់ទិនទៅនឹងរបបខ្មែរក្រហមនៅកម្ពុជានេះ បាទ?

**ឆ៖** ដូចដែលខ្ញុំបានលើកឡើង ខ្ញុំចាប់អារម្មណ៍របបនេះ តាំងពីពេលដែលខ្មែរក្រហមកាន់កាប់អំណាច។ ខ្ញុំចាប់ផ្តើមសរសេរអំពីរបបនេះ គឺចាប់ពីឆ្នាំ១៩៧៦, ៧៧ ប៉ុន្តែមិនលម្អិតទេ ក៏ប៉ុន្តែចាប់ពីឆ្នាំ១៩៨១ មក ការស្រាវជ្រាវរបស់ខ្ញុំ កាន់តែផ្តោតខ្លាំងឡើងទៅលើរបបខ្មែរក្រហម។

[១១:២៦:២៩]

**ស៖** អរគុណ សាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ។ ជាបន្តនេះ ខ្ញុំសូមឆ្លងចូលទៅក្នុងប្រធានបទមួយ គឺទាក់ទិនទៅនឹងបក្សកុម្មុយនីស្តកម្ពុជា -- លក្ខន្តិកៈស្តីពីបក្សកុម្មុយនីស្តកម្ពុជា។ ខ្ញុំសូមជម្រាបសួរលោក ទាក់ទិននឹងសំណួរមួយចំនួន ពាក់ព័ន្ធនឹងការលម្អិត បើផ្អែកទៅតាមការយល់ដឹង និងចងចាំរបស់លោក។

**លោក ច័ន្ទ តារាស្នើ៖**

ហើយខ្ញុំក៏សូមអនុញ្ញាតពីលោកប្រធានផងដែរ នៅក្នុងការសួរសំណួររបស់ខ្ញុំទាក់ទងនឹងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជានេះ។ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញឯកសារមួយចំនួននៅលើអេក្រង់កុំព្យូទ័រ ដើម្បីជាការងាយស្រួល និងជាការជួយរំឭកដល់ការចង់ចាំរបស់លោក ដេវីដ ឆេនដ៍ល័រផងដែរបាទ។ ជាសំណួរជាបន្តនេះ ខ្ញុំសូមឱ្យលោកមេត្តារំឭកនូវការចងចាំទាក់ទងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា។ ហើយខ្ញុំសូមខាង អាយ.ធី ខាងជួយបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ។ សូមអនុញ្ញាតពីលោកប្រធាន បើសិនជាលោកប្រធានអនុញ្ញាត?

[១១:២៧:១៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

*(ការបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ)*

[១១:២៧:៣៣]

**សួរដោយលោក ច័ន្ទ តារាស្នើ៖**

**ស៖** នេះគឺជាឯកសារដែលទាក់ទងនឹងលក្ខន្តិកៈ ដែលផ្អែកលើឯកសារ E3/130ៗ បាទ។ ហើយសូមលោក ដេវីដ ឆេនដ៍ល័រ មេត្តាអានឯកសារនេះ ហើយខ្ញុំនឹងសួរសំណួរជាបន្តបន្ទាប់ ដូចតទៅនេះបាទ។ តើលោកស្គាល់ ឬក៏ធ្លាប់បានអានឯកសារនេះ ដែរឬទេ?

[១១:២៨:៤៧]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំដូចជាមិនប្រាកដទេ នៅពេលដែលខ្ញុំមើលឯកសារហ្នឹងឡើងវិញ ប្រហែលជាខ្ញុំហ្នឹងធ្លាប់អានឯកសារនេះ នៅពេលណាមួយ។ ខ្ញុំបានមើលទៅលើលក្ខន្តិកៈបក្ស ក៏ប៉ុន្តែមិនអាមួយ ដែលខ្ញុំកំពុងតែពិនិត្យមើលនេះទេ ហើយតាមអ្វីដែលខ្ញុំចាំនោះ។

**ស៖** បាទ លោក ដេវីដ ឆេនដ៍ល័រ ឯកសារនេះ គឺជាឯកសារដែលលោកមាននៅក្នុងដៃនេះ គឺជាភាសាអង់គ្លេស ហើយឯកសារនេះ គឺមានបកប្រែជាបីភាសា គឺខ្មែរ "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" នេះ គឺជាឯកសារដើម ហើយជាភាសាអង់គ្លេង និងជាភាសាបារាំង។ អ៊ីចឹងសូមលោកមេត្តាអានឯកសារនេះបន្តិច ហើយលោកសូមមេត្តាឆ្លើយនឹងសំណួររបស់ខ្ញុំជាបន្តទៅនេះបាទ។

[១១:២៩:៥២]

**ឆ៖** បាទ អត់អីទេ អ៊ីចឹងខ្ញុំនឹងពិនិត្យមើល។ សូមអរគុណ។

**ស៖** តើខ្ញុំអាចចាប់ផ្តើមសួរលោកបានទេបាទ?

**ឆ៖** បាទ លោកអាចសួរខ្ញុំបាន។

**ស៖** អរគុណលោក ដេវីដ ឆេនដ៍ល័រ។ សំណួរបន្តនេះ គឺខ្ញុំសូមសួរលោកថា តើតាមការយល់ដឹងរបស់លោក តើលក្ខន្តិកៈនេះគេបង្កើតឡើងក្នុងគោលបំណងអ្វី? បើតាមការយល់ដឹងរបស់លោក តើលក្ខន្តិកៈហ្នឹងបង្កើតឡើងក្នុងគោលបំណងអ្វី?

**ឆ៖** លក្ខន្តិកៈនេះ គឺដើម្បីថែងឲ្យបានច្បាស់លាស់ទៅលើទម្រង់ការងារមួយចំនួន។ លក្ខន្តិកៈនេះតែងតែធ្វើវិសោធនកម្មនៅពេលដែលគិតអំពីអំណាចរបស់គេ។ លក្ខន្តិកៈនេះថែងអំពីអង្គការ គោលបំណង និងគំនិតទស្សនៈពាក់ព័ន្ធទៅនឹងកម្ពុជាប្រជាធិបតេយ្យដែលបក្សកុម្មុយនីស្តកម្ពុជា គឺជាបក្សគ្រប់គ្រងមួយ ហើយវាក៏ជាឧបករណ៍ -- ឯកសារជាឧបករណ៍ធ្វើការពិចារណាទៅលើបដិវត្តន៍កម្ពុជា។

[១១:៣១:១៦]

**ស៖** អរគុណលោក ដេវីដ ឆេនដ៍ល័រ។ តាមការស្រាវជ្រាវរបស់លោក តើលោកអាចបញ្ជាក់បានអំពីការពិតបានដែរឬទេ ថាតើលក្ខន្តិកៈនេះបានធ្វើសេចក្តីព្រាងជាលើកដំបូងនៅពេលណា? ហើយអត្ថបទនេះគឺនិពន្ធឡើងដោយយ៉ាងដូចម្តេចដែរ?

**ឆ៖** ខ្ញុំមិនអាចទេ។ តាមឯកសារដែលខ្ញុំមើលនេះ ខ្ញុំត្រូវតែពិនិត្យមើលឯកសារដែលខ្ញុំធ្លាប់

អាចយកមកអាននិងពិនិត្យមើលពីមុនទើបអាចបញ្ជាក់បាន។ ពេលនេះ ខ្ញុំគិតថាប្រហែលជាបង្កើតឡើងក្នុងឆ្នាំ១៩៧៦ ទោះបីយ៉ាងណាក៏ដោយខ្ញុំមិនអាចបញ្ជាក់ឲ្យបានច្បាស់លាស់ទៅលើអ្វីដែលលោកសួរនេះឡើយ។

[១១:៣២:១០]

**ស៖** អរគុណលោក ដេវីដ ឆេនដ៍ល័រ។

**លោក ច័ន្ទ តារាស្មី៖**

ខ្ញុំសូមលោកប្រធានអនុញ្ញាតឆ្លងទៅកថាខណ្ឌទី២ នៃលក្ខន្តិកៈនេះបាទ ដែលមាន ERN ខ្មែរ 00442253, ERN ជាភាសាអង់គ្លេស 00184024, ERN ជាភាសាបារាំង 00292916។ បាទ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញឯកសារនេះ។ ហើយខាងជំនួយការជួយបង្ហាញឯកសារលើអេក្រង់កុំព្យូទ័រ។ បើសិនជាលោកប្រធានអនុញ្ញាត។

[១១:៣២:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ប៉ុន្តែកែសម្រួលពីការដាក់បង្ហាញឯកសារជាភាសាអង់គ្លេសនៅលើអេក្រង់កុំព្យូទ័រ និងទូរទស្សន៍ សូមឲ្យដាក់ជាភាសាខ្មែរ ដោយឡែកឯកសារនេះជាក្រដាសបានដាក់ជូនលោកអ្នកជំនាញហើយ។ ហើយប្រភេទឯកសារតទៅមុខទៀត ប្រសិនបើមានឯកសារប្រភេទបែបនេះត្រូវដាក់បង្ហាញនៅលើអេក្រង់កុំព្យូទ័រ និងទូរទស្សន៍ហ្នឹង សូមដាក់ជាភាសាខ្មែរ ហើយភាគីដែលពាក់ព័ន្ធសូមត្រៀមឯកសារជាភាសាអង់គ្លេស ដាក់ជូនលោកអ្នកជំនាញដើម្បីពិនិត្យ និងមានលទ្ធភាពក្នុងការឆ្លើយតបទៅនឹងសំណួរ។

**លោក ច័ន្ទ តារាស្មី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតដកស្រង់នូវខ្លឹមសារដែលទាក់ទិនទៅនឹងកថាខណ្ឌទី២នេះ។ ហើយដើម្បីឲ្យជាការរំឭកជូនដល់លោក ដេវីដ ឆេនដ៍ល័រ ដើម្បីឆ្លើយនឹងសំណួររបស់ខ្ញុំបាទ។

[១១:៣៣:៥៣]

នៅក្នុងកថាខណ្ឌទី២ នៃឯកសារជាភាសាខ្មែរហ្នឹង គឺបាននិយាយថា "បក្សកុម្មុយនីស្តកម្ពុជាជាបក្សរបស់វណ្ណៈកម្មករ ក្រោយពីបក្សដឹកនាំសម្រេចបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យបានទាំងស្រុង និងជាស្ថាពរ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥មក បក្សបន្តដឹកនាំបដិវត្តន៍សង្គមនិយម និង

កសាងសង្គមនិយមតទៅទៀត ដោយផ្ដាច់មុខ ដាច់ខាត និងគ្រប់ផ្នែក។ បក្សមានធាតុពិតជាអង្គការខ្ពស់បំផុតរបស់វណ្ណៈកម្មករកម្ពុជា ជាកងទ័ពស្រួចមោះមុត អង់អាចបំផុត ជាអង្គបញ្ញាការគ្រប់គ្រង និងចាត់ចែងការងារបដិវត្តន៍ទាំងអស់ ហើយជាប់ជិតស្និទ្ធ និងមហាជន”។ បញ្ចប់ការដកស្រង់។ នេះគឺជាអត្ថបទដែលខ្ញុំដកស្រង់ចេញពីលក្ខន្តិកៈក្នុងកថាខណ្ឌទី២។

[១១:៣៥:០៦]

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** ហើយសូមអនុញ្ញាតសួរលោក ដេវីដ ឆេនដ៍ល័រ នូវសំណួរជាបន្តទៅនេះ។ តើលោកបានអានលក្ខន្តិកៈនេះហើយនៅ? កថាខណ្ឌទី២នេះ?

**ប្រធានអង្គជំនុំ៖**

សូមឆ្លើយសិនទៅលោក ដេវីដ ឆេនដ៍ល័រ តើលោកបានអានហើយឬនៅ? ព្រោះសំណួរអម្បាញ់មិញនោះ ពីមុននោះដូចជាមានបញ្ហាលទ្ធភាពនៅក្នុងការអានរបស់លោកនៅចំពោះមុខសវនាការនាពេលនេះ ដោយសារមានការខុសប្លែកគ្នារវាងអត្ថបទដែលលោកធ្លាប់បានអានពីមុន ហើយនិងអត្ថបទថ្មីដែលនៅក្នុងសំណុំរឿង។ នេះជាការបង្ហាញរបស់លោកមុននឹងស្ដាប់សំណួរចុងក្រោយរបស់តំណាងសហព្រះរាជអាជ្ញា។ អ៊ីចឹងហើយបានជាលោកតំណាងសហព្រះរាជអាជ្ញាជាតិហ្នឹង បានសួរលោកអំពីថាតើលោកបានអានហើយឬនៅ? តាមយើងមើល ឃើញថាភ្លាមៗនេះ លោកមិនមានលទ្ធភាព និងពេលវេលាសមស្របក្នុងការអាននូវឯកសារនេះទេ។ ប៉ុន្តែដើម្បីឆ្លើយតបទៅនឹងសំណួរដែលសួរ សូមលោកឆ្លើយតបទៅនឹងតំណាងសហព្រះរាជអាជ្ញាសួរលោកអម្បាញ់មិញ អំពីថាតើលោកបានអានចប់ហើយឬនៅលើឯកសារដែលបានដាក់ជូនលោកពិនិត្យ ដើម្បីសួរដេញដោលនាពេលនេះ។

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** បាទ ខ្ញុំបានអានឯកសារនេះហើយ។

[១១:៣៦:៤៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិការពារក្ដីលោក អៀង សារី!

**លោក អាង ឧត្ដម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ សួស្ដីសហព្រះរាជអាជ្ញា

សហភាតា អស់លោកអ្នកទាំងអស់។ ហើយខ្ញុំបានស្តាប់ចម្លើយលោកសាក្សីលើសំណួរពីរ ហើយបើខ្ញុំស្តាប់ច្រឡំ សូមអភ័យទោស។ ចម្លើយទីមួយគាត់ថា "មិនធ្លាប់ដែលបានអានឯកសារនេះពីមុនទេ" ហើយឆ្លើយនឹងសំណួរទីពីរ គាត់ថា "ទាក់ទងនឹងឯកសារនេះ គាត់មិនអាចអត្ថាធិប្បាយ ឬពន្យល់ទៅលើឯកសារនេះទេ"។ បើដូច្នេះមែន ឬមួយបើខ្ញុំមិនស្តាប់ច្រឡំទេ តើយើងគួរអនុវត្ត *រូបលើង* វិធានដែលហើយបញ្ញត្តិដែលបានដាក់ពីមុនទាក់ទងនឹងករណីថា សាក្សីមិនដែលបានឃើញឯកសារណាមួយនោះតើត្រូវ យើងត្រូវដកឯកសារនោះមកវិញ ឬយ៉ាងម៉េច? សូមអរគុណ។

[១១:៣៧:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការកត់សម្គាល់នេះ។ ប៉ុន្តែទំនងលោកមេធាវីមានការភន្តច្រឡំ។ លោកអ្នកជំនាញបានឆ្លើយច្បាស់លាស់ណាស់ លោកធ្លាប់បានអាននូវលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា។ ប៉ុន្តែការអានអត្ថបទ ការគាត់អានហ្នឹងមិនមែនអត្ថបទ ដូចគ្នានឹងអត្ថបទដែលបានដាក់នៅចំពោះមុខនាពេលនេះទេ។ បានន័យថា មានការបកប្រែខុសគ្នាទៅតាមដំណាក់កាលនៃដំណើរការនីតិវិធីប៉ុណ្ណឹងទេ។ ហើយចំណែកឯខ្លឹមសារ គាត់ប្រាកដជា គាត់បានឆ្លើយបញ្ជាក់ហើយថា គាត់បានអានមែនលើលក្ខន្តិកៈបក្ស។ អ៊ីចឹងហើយបានជា អម្បាញ់មិញនេះគឺតាំងសំណួរចុងក្រោយ ថាតើគាត់បានអានបន្ថែមទៀតទេលើឯកសារនៅចំពោះមុខនេះ។ អានហ្នឹង អានលើឯកសារថ្មី ឯកសារដដែលហ្នឹង គ្រាន់តែមានការទម្រង់របៀបបកប្រែហ្នឹងខុសគ្នាតែប៉ុណ្ណឹងទេ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ!

[១១:៣៨:៤៨]

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ហើយជាបន្តនេះ ឯកសារនឹងបង្ហាញជាភាសាខ្មែរតាមកញ្ចក់ទូរទស្សន៍ កញ្ចក់អេក្រង់កុំព្យូទ័រ ហើយខ្ញុំជូនឯកសារជាភាសាអង់គ្លេសទៅលោក ដេវីដ ឆេនដ័ល័រ តាមការអនុញ្ញាតពីលោកប្រធាន ហើយនិងការណែនាំរបស់លោកប្រធាន។

ហើយជាបន្តនេះ ខ្ញុំសូមសួរទៅលោក ដេវីដ ឆេនដ័ល័រ ដោយហេតុថា គាត់បានឆ្លើយជាមួយនឹងអង្គសវនាការនៅទីនេះថា គាត់បានអានអត្ថបទនេះហើយ ហើយគាត់បានដឹងឮអត្ថបទនេះហើយ។ អ៊ីចឹងខ្ញុំសូមអនុញ្ញាតសួរបន្តទៅទៀត។ បើសិនជាអត្ថបទណា ដែលគាត់មិនបានឃើញ មិនបានអានទេ

ខ្ញុំព្យាយាមមិនសួរសំណួរហ្នឹងទេបាទ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក ដេវីដ ឆេនដ៍ល័រ ខ្ញុំសូមសួរសំណួរទាក់ទងទៅនឹងលក្ខន្តិកៈនេះក្នុងន័យលម្អិតជាបន្តបន្ទាប់ដូចតទៅ។ លោក ដេវីដ ឆេនដ៍ល័រ នៅក្នុងពាក្យនៃកថាខណ្ឌទី២នេះ ខ្ញុំសង្កេតឃើញមានពាក្យដែលប្រើនៅក្នុងទីនេះ គឺ "បក្សបន្តដឹកនាំបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមតទៅទៀត ដោយផ្ដាច់មុខ ដាច់ខាត និងថា បក្សកុម្មុយនីស្ដជាអង្គការខ្ពស់បំផុតរបស់វណ្ណៈកម្មករកម្ពុជា និងជាអគ្គបញ្ជាការគ្រប់គ្រង និងចាត់ចែងការងារបដិវត្តន៍ទាំងអស់"។ ត្រង់ចំណុចនេះ តើលោកអាចបញ្ជាក់បានទេអំពីអត្ថន័យ ខ្លឹមសារ ដែលទាក់ទងទៅនឹងកថាខណ្ឌនេះ ថាតើគេចង់និយាយរឿងអី បើតាមការចងចាំរបស់លោកបាន ឬក៏ការយល់ដឹងរបស់លោកបាទ?

[១១:៤០:២៩]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** វាមានលក្ខណៈត្រង់ៗ តាមអ្វីដែលខ្ញុំ -- គឺថាសេចក្ដីថ្លែងការណ៍នេះ បញ្ជាក់ពីអំណាចគឺបក្សកុម្មុយនីស្ដកម្ពុជា គឺសម្រេចថា ជាអ្នកគ្រប់គ្រងកម្ពុជា ហើយគឺសម្រេចនូវអ្វីដែលគេប៉ុនប៉ងនោះឯង។ ជាសេចក្ដីថ្លែងការណ៍ គឺថាអំណាចនៅក្នុងប្រទេសកម្ពុជា គឺពីពេលនេះតទៅចាប់តាំងពីអនុវត្តលក្ខន្តិកៈបក្សនេះ គឺសមាជិកបក្សហ្នឹង ចាប់ពីពេលនេះទៅគឺ បក្សគឺថា មានភាពផ្ដាច់មុខទៅលើអំពីការកសាង ឬក៏គ្រប់វិស័យទាំងអស់នៅក្នុងប្រទេស។ នេះជាសេចក្ដីថ្លែងការណ៍ច្បាស់អំពី -- នៃការអះអាងរបស់បក្សនោះ អំពីអំណាចរបស់ខ្លួនគឺថា អំណាចរបស់បក្សនោះ គឺមិនស្របច្បាប់ទេ ក៏ប៉ុន្តែជាអំណាចដែលផ្ដាច់មុខដាច់ខាត ដែលបក្សគេអនុញ្ញាតឲ្យមាននៅក្នុងរបបនោះនៅកម្ពុជា។

**ស៖** បាទ សូមអរគុណលោក ដេវីដ ឆេនដ៍ល័រ។ ខ្ញុំសូមចង់ឲ្យលោកបញ្ជាក់បន្ថែម បើសិនជាលោកអាចបញ្ជាក់បាន ទាក់ទងទៅនឹងអ្វីដែលជាការយល់ដឹងរបស់លោក តាមការស្រាវជ្រាវរបស់លោក។ ពាក្យដែលប្រើនៅក្នុងកថាខណ្ឌនេះ គឺមានពាក្យសំខាន់ៗមួយចំនួន ដូចជា "ផ្ដាច់មុខ" "ដាច់ខាត"។ ពាក្យហ្នឹងមានន័យយ៉ាងដូចម្ដេចបាទ? អត្ថន័យយ៉ាងស៊ីជម្រៅនៅក្នុងគោលបំណង នៃការបង្កើតកថាខណ្ឌនេះឡើង គឺក្នុងបំណងអ្វីជាសំខាន់បាទ?

[១១:៤២:៣៥]

**ឆ៖** គឺជាមូលដ្ឋាន ជាសេចក្ដីថ្លែងការណ៍ ដែលត្រូវតែមានលក្ខណៈច្បាស់ គឺថាវាចែងច្បាស់

ដោយខ្លួនឯងហើយ ជាលក្ខន្តិកៈនេះគឺមិនអនុញ្ញាតឲ្យមានការជំទាស់ ឬក៏ការកែប្រែ ឬក៏មតិអ្វីប្រឆាំងនឹងលក្ខន្តិកៈបក្សនេះទេ ដែលគេប្រើពាក្យថា ផ្តាច់មុខ ឬក៏ដាច់ខាត គឺអំណាចរបស់បក្សនោះគឺ ផ្តាច់មុខគឺថា គឺជាព័ត៌មាន ឬក៏អំណាចអ្វីមិនឲ្យមានអ្នកណាជំទាស់ទេ។ ពាក្យនេះជា ពាក្យទូលំទូលាយ គឺមិនអនុញ្ញាតឲ្យអ្វីទម្រង់ នៃអំណាចណាផ្សេងទៀត ខុសពីអំណាចរបស់បក្សទេ ទូទាំងប្រទេស។ ដូចជាគំនិតមួយថា បក្សកុម្មុយនីស្តកម្ពុជា ពីពេលនេះតទៅគឺជា បក្សដែលរបស់ប្រជាជនទាំងអស់ មិនឲ្យគោរពបក្សណាមួយផ្សេងទៀត ដែលប៉ះពាល់ដល់ជីវភាពប្រជាជននោះទេ។

[១១:៤៣:៤០]

**សៈ** បាទ អរគុណលោក ដេវីដ ឆេនដ័ល័រ។ ចំពោះពាក្យដែលថា “អង្គការខ្ពស់បំផុត” ដែលសរសេរនៅក្នុងកថាខណ្ឌនេះ តើសំដៅមានន័យយ៉ាងដូចម្តេច? ហើយអង្គការខ្ពស់បំផុតហ្នឹង អ្នកណាខ្លះជាសមាជិកបាទ?

**ឆៈ** ដូចគ្នាដែរ នេះជាការអះអាងដោយគោលបំណងមួយគឺថា គេជាអ្នកទទួលខុសត្រូវ គេជាអង្គការខ្ពស់បំផុតរបស់បក្ស។ ហើយតាមពិតគឺ មិនមានអ្នកណាខ្ពស់ជាងគេទេ គឺថាមានគណៈអចិន្ត្រៃយ៍ គណៈមជ្ឈិម គឺថាមានលេខា និងអនុលេខាបក្ស គឺថាមិនបានបញ្ជាក់ដោយឈ្មោះទេ ដោយមុខងារទេ ប៉ុន្តែជាអង្គការខ្ពស់បំផុត គឺត្រូវតែមានអំណាចក្នុងការអនុវត្តនូវសកម្មភាពរបស់បក្ស នៅក្នុងកម្ពុជា។ នោះមានន័យអ៊ីចឹង។

**សៈ** បាទ សូមអរគុណលោក ដេវីដ ឆេនដ័ល័រ។ ចំពោះសំណួរបន្តទៀត ថាតើលោកអាចបញ្ជាក់អំពីតួនាទីរបស់បក្សកុម្មុយនីស្ត នៅក្នុងកម្ពុជាប្រជាធិបតេយ្យបានដែរឬទេ?

[១១:៤៥:០១]

**ឆៈ** ខ្ញុំអាចជម្រាបបាន បក្សនោះចាត់ទុកខ្លួនឯងថាជា គំនិតដែលអ្នកសរសេរនោះគឺថានេះគឺជាបក្សមួយដែលថាច្បាស់លាស់ ខ្ពស់បំផុត គឺថាអាចប្រាប់ដល់សមាជិកទាំងអស់ឲ្យគេយល់បែបនេះទូទាំងប្រទេសហ្នឹង គឺថាប្រទេស គឺជាប្រទេស ជាឯកសារមិនអាចតវ៉ាបានដែលត្រូវតែអនុវត្តក្រោមមាគ៌ាបក្ស ហើយការដឹកនាំរបស់បក្ស។ ហើយតាមពិតថាតើគេអនុវត្តដោយរបៀបណានោះ? គឺយើងប្រើពាក្យឃ្លានេះគឺយើងនឹងចូលទៅដល់ការជាក់ស្តែងនោះ គឺមិនទាក់ទងទៅនឹងការអះអាងរបស់បក្សអំពីអំណាចនោះទេ គឺថាស្ថាប័ននយោបាយគឺថាអាចនឹងអនុវត្ត គឺអំណាចដែលដាច់ខាតទាំងស្រុងគឺមិនអាចតវ៉ាបាននៅក្នុងកថាខណ្ឌដែលយើងនិយាយនេះ គឺនិយាយច្បាស់អ៊ីចឹង។ គឺតាមពិត គឺថាជា

ឯកសារដែលមិនទទួលស្គាល់នូវខ្លឹមសារ ឬក៏ឱកាសណាមួយដែលថាឯកសារនេះ ការកំណត់នូវអំណាចផ្តាច់ការ ឬក៏អំណាចទាំងស្រុងនេះគឺអាចនឹងត្រូវបាន -- អ្វីនឹងកើតមានឡើងនៅក្នុងភាពជាក់ស្តែងនោះទេ ដែលថាអាចអ្វីនៅក្នុងលក្ខន្តិកៈនោះវាអ្វីដែលកើតមានឡើង គឺថាមិនអាចមានអ្វីខុសពីហ្នឹងទេ។ អ៊ីចឹងគឺថាដំណើរការដែលអនុវត្តទៅគឺថាបញ្ហាវិញ ទាក់ទងទៅនឹងសភាពជាក់ស្តែងនៃប្រវត្តិសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យ ជាបាតុភូតមួយដែលមានការវិវត្តន៍ ដែលថាខ្លួនមានអំណាចទាំងស្រុង ក៏ប៉ុន្តែគំនិតនោះគឺថាមនុស្សភាគច្រើនក៏សិក្សាលម្អិតទៅ គឺថាយើងមិនយល់ច្បាស់ថាវាពិតជាអ៊ីចឹងដូចការអះអាងនោះទេ។

[១១:៤៧:១៣]

**ស៖** សូមអរគុណ។

**លោក ច័ន្ទ តារាស្នើ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបន្តទៅអត្ថបទកថាខណ្ឌទីប្រាំមួយដដែល ប៉ុន្តែស្រង់យក ERN លេខជាភាសាខ្មែរ 00442255, ERN ជាភាសាអង់គ្លេស 00184025, ERN ជាភាសាបារាំង 00292917។ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន បើសិនជាលោកប្រធានមិនយល់ទាស់ទេ ខ្ញុំសូមបង្ហាញឯកសារនេះនៅលើអេក្រង់កុំព្យូទ័របាទ ដើម្បីសួរសំណួរទៅលើ ដេវីដ ឆេនដ័ល័រ ជាបន្តទៀតបាទ។

[១១:៤៧:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានអនុញ្ញាតរួចហើយ ឯកសារ លក្ខន្តិកៈទាំងមូល មិនមែនឯក -- អនុញ្ញាតដោយតាមទំព័រទេ។ លោកបន្តធ្វើកិច្ចការរបស់លោក ព្រោះលោកស្នើសុំដាក់ឯកសារលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាបញ្ជាក់លេខច្បាស់លាស់ណាស់។ អ៊ីចឹងតាំងសំណួររហូតដល់ចប់ទៅ។

**លោក ច័ន្ទ តារាស្នើ៖**

អរគុណលោកប្រធាន។

**សួរដោយលោក ច័ន្ទ តារាស្នើ៖**

**ស៖** លោក ដេវីដ ឆេនដ័ល័រ ខ្ញុំសូមសួរសំណួរបន្តទៀត។ នៅក្នុងកថាខណ្ឌទីប្រាំមួយនេះ កថាខណ្ឌប្រាំមួយនេះគឺមានពាក្យដែលប្រើ "ប្រជាធិបតេយ្យប្រមូលផ្តុំ"។ លោកបានអានទេ បានឃើញពាក្យនេះបាទ ពាក្យថា "ប្រជាធិបតេយ្យប្រមូលផ្តុំ"។ តើពាក្យនេះ លោកយល់ថាតាមការបក -- តាម

ការចងចាំ ឬក៏តាមការស្រាវជម្រាវរបស់លោកៗអាចបង្ហាញជូនអង្គសវនាការជ្រាបបានទេ អំពីពាក្យថា "ប្រជាធិបតេយ្យប្រមូលផ្តុំ" នេះសំដៅលើអត្ថន័យយ៉ាងដូចម្តេច?

[១១:៤៩:00]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំគិតថា ជាពាក្យទូទៅមួយដែលថា អំពីប្រជាធិបតេយ្យប្រមូលផ្តុំនេះ ខ្ញុំគិតថាបក្សកុម្មុយនីស្តផ្សេងៗទៀតនៅក្នុងពិភពលោក គឺគេប្រកាន់ជំហរបែបនេះ គេចាត់ទុកខ្លួនឯងថាជាស្ថាប័នរបស់នៃឆន្ទៈមហាជនទូទៅ។ គេយល់ថាប្រជាជនគឺជាកម្លាំង គឺថាគេជាតំណាងរបស់កម្លាំងប្រជាជនដោយអំណាចមួយដែលប្រមូលផ្តុំ។ នេះហើយគឺជាទស្សនៈដែលគេថាអំណាចប្រមូលផ្តុំ។ វាមិនមែនជាអ្វីដែលថា មានន័យច្បាស់លាស់ត្រឹមត្រូវនោះទេ ពីព្រោះថាបើគេនិយាយថា អនុលោមទៅតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំនោះ គឺថារបបនោះ វាជាផ្តាច់ការ។ ប៉ុន្តែគេមិនចាត់ទុកខ្លួនឯងជាផ្តាច់ការនោះទេ។ គេចាត់ទុកថា ជាមេដឹកនាំសមូហភាព ធ្វើការដើម្បីផលប្រយោជន៍របស់កម្មករ ពលករដើម្បីប្រយោជន៍សង្គម។ គំនិតបដិវត្តន៍នៅក្នុងន័យនេះ គឺមិនបានបញ្ជាក់នៅក្នុងទំព័រនេះទេ។ នេះហើយជាការអះអាងអំពីប្រជាធិបតេយ្យជាអំណាចរបស់ប្រជាជន ប៉ុន្តែជាអំណាចប្រមូលផ្តុំ។ នេះជាពាក្យលំបាកណាស់ ហើយជាពាក្យមួយដែលស្មុគស្មាញជាជាងដែលខ្ញុំបានឃើញវិភាគពីដើមមកនោះ។

[១១:៥១:0២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ម៉ែខល កាណាវាស!

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ថា អ្វីដែលយើងសួរអ្នកជំនាញ និងប្រវត្តិសាស្ត្រហើយសំណួរខ្លះគឺថាឃ្លាមួយចំនួន អាចនឹងផ្តល់ឲ្យសាក្សីនូវការសន្និដ្ឋានផ្លូវច្បាប់ ដែលថាអ្នកជំនាញណាក៏ដោយនៅតុលាការ គឺគាត់មិនបានដឹងអំពីសិទ្ធិ ហើយគាត់មិនមានសិទ្ធិធ្វើបែបនោះទេ ហើយមេធាវី--សហព្រះរាជអាជ្ញា គប្បីផ្តល់ជូនគាត់នូវភស្តុតាង ថាតើគាត់យល់ឯកសារនេះ ផ្អែកទៅលើការសិក្សារបស់គាត់ គឺថាអាចសំណួរហ្នឹង វាមានលក្ខណៈរឹងមាំជាង គឺមានអត្ថប្រយោជន៍ដើម្បីផ្ទុះបញ្ចាំងពីគំនិតនោះ បើមិនដូច្នោះទេ គាត់នឹងសន្និដ្ឋានផ្អែកតាមចំណេះដឹងរបស់គាត់ ចំពោះអ្នកជំនាញរូបនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន លោក ម៉ៃខល កាណាវាស នូវការកត់សម្គាល់របស់លោក។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនទៅមេធាវី-- អ៊ំ លោកតំណែងសហព្រះរាជអាជ្ញាជាតិ ថាសូមលោកកែសម្រួលនៅលើខ្លឹមសារនៃការតាំងសំណួររបស់លោក មិនគប្បីអញ្ជើញលោកសាស្ត្រាចារ្យ អ្នកជំនាញប្រវត្តិ-សាស្ត្រ ឬប្រវត្តិវិទូសាកលលោក មកតាំងសំណួរឲ្យគាត់ពន្យល់នូវខ្លឹមសារ នៃពាក្យដែលលោកគិតថាបើយល់គ្រប់ពាក្យនោះ ប្រហែលជាទំនងមិនអាចចប់ទេ គួរតែត្រូវបានសួរតាំងសំណួរដោយខ្លឹមសារអត្ថន័យជ្រាលជ្រៅ ហើយជាទូទៅ នៅក្នុងកិច្ចដំណើរការនេះ ទាំងអង្គហេតុនៅក្នុង ស-២១ ក៏ដោយពីព្រោះការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ មិនអនុញ្ញាតសួរឲ្យមានលក្ខណៈលម្អិត ដូចកាលពីធ្វើសវនាការសំណុំរឿង០០១ នោះទេ។ អង្គជំនុំជម្រះបានជម្រាបជូនតាមអនុស្សរណៈរបស់ខ្លួនរួចហើយ។

[១១:៥៣:០១]

ដូច្នេះ សូមរៀបចំការតាំងសំណួរដេញដោលឲ្យមានខ្លឹមសារអត្ថន័យជ្រាលជ្រៅ ហើយនិងសមស្របទៅនឹងលទ្ធភាពនឹងការចង់បានរបស់អង្គជំនុំជម្រះ គឺរួមវិភាគទានយ៉ាងសំខាន់នៅក្នុងការស្វែងរកការពិតនៅក្នុងរឿងក្តីនេះ ដោយការសិក្សាស្រាវជ្រាវរបស់អ្នកជំនាញជាន់ខ្ពស់ ដែលកម្រិតទៅជាថ្នាក់បណ្ឌិត ឬក៏វិទូខាងប្រវត្តិសាស្ត្រនេះ។

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមអរគុណលោកប្រធាន។ សហព្រះរាជអាជ្ញា តំណាងសហព្រះរាជអាជ្ញា ក៏សូមជម្រាបជូនទៅខាងភាគីលោកមេធាវី កាណាវាស ដែរថា អ្វីដែលខ្ញុំសួរ--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចរួចហើយ លោកត្រូវតាមរៀបចំកែសម្រួលខ្លួនឯងឲ្យសមស្របទៅនឹងស្ថានភាពនៃសារៈសំខាន់ចំណេះដឹងជ្រៅជ្រះរបស់អ្នកជំនាញ ចៀសវាងអញ្ជើញអ្នកជំនាញមកពន្យល់ពាក្យ។

**លោក ច័ន្ទ តារាស្មី៖**

អរគុណលោកប្រធាន។ ខ្ញុំសូមបន្តទៅសំណួរផ្សេង។

[១១:៥៤:១១]

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក ដេវីដ ឆេនដ៍ល័រ ខ្ញុំសូមសួរទៅសំណួរមួយទៀត ទាក់ទងនឹងត្រង់មាត្រា៣ ដែលមានលេខ ERN ខ្មែរ ERN 00442262, ERN ជាភាសាអង់គ្លេស 00184032, ERN ជាភាសាបារាំង 00292922។ សូមលោក ដេវីដ មេត្តាអត្ថបទនេះ ត្រង់ចំណុចមាត្រា៣ នេះ។ ហើយខ្ញុំនឹងសួរលោកទាក់ទងនឹងចំណុចនេះ។ តើលោកបានអានទេបាទ?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** នេះនៅក្នុងឯកសារនោះ គឺនៅកថាខណ្ឌ១, ២, ៣ រហូតដល់៤ ហើយលោកនិយាយថាកថាខណ្ឌ៣ តើនៅទំព័រ -- តើលោកនិយាយអង់គ្លេសទំព័រទីប៉ុន្មានដែលលោកនិយាយនោះលោកសហព្រះរាជអាជ្ញា?

**ស៖** បាទ ខ្ញុំសូមបញ្ជាក់ជូនជាថ្មីម្តងទៀត គឺ ERN ជាភាសាអង់គ្លេស 00184032 ហើយទំព័រ គឺទំព័រ១៣ ជាភាសាអង់គ្លេស ទំព័រ១១ បាទ លោកមើលឃើញទំព័រ១១ បាទ។ ទំព័រ១១។ តើខ្ញុំអាចចាប់ផ្តើមសួរលោកបានទេបាទ?

លោក ដេវីដ ឆេនដ៍ល័រ ខ្ញុំសូមសួរលោក សូមលោកជួយបញ្ជាក់ ឬក៏បំភ្លឺតាមការយល់ដឹងរបស់លោកទាក់ទងទៅនឹងសិទ្ធិរបស់បក្ខជននៅក្នុងបក្សកុម្មុយនីស្តបាទ? នៅក្នុងហ្នឹងគេមាននិយាយអំពីប្រជាធិបតេយ្យប្រមូលផ្តុំ។ អ៊ីចឹងការសម្រេចសិទ្ធិរបស់បក្ខជននៅក្នុងសម្រេចតើមានរួមចំណែកយ៉ាងដូចម្តេចនៅក្នុងការសម្រេចបែបគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ?

[១១:៥៧:២៤]

**ឆ៖** តាមពិតដែលខ្ញុំមិនបានសង្កេតផ្ទាល់ទេ ខ្ញុំមិនច្បាស់ទេ។ ប៉ុន្តែឃ្លានេះ គឺថាត្រូវធ្វើសេចក្តីសម្រេចដោយមានការពិចារណាពិភាក្សាគ្នា នេះគឺអាចសមស្រប ប៉ុន្តែខ្ញុំគិតថានេះជាតម្រុយទេ។ នៅក្នុងកថាខណ្ឌនេះ ខ្ញុំដែលថា មេធាវីការពារបានលើកឡើងហើយ ខ្ញុំមិនមានជាអ្នកជំនាញខាងនយោបាយខាងលក្ខន្តិកៈនេះទេ។ ប៉ុន្តែអ្វីដែលយើងឃើញនៅពេលសរសេរនោះ គឺថាជាកិច្ចការរបស់បក្សនោះ គឺមិនស្ថិតនៅក្នុងដៃរបស់សមាជិកទាំងអស់ទេ។ ប៉ុន្តែបញ្ហារបស់បក្សក៏ត្រូវពិភាក្សាក្នុងចំណោមសមាជិក។ អនុលោមទៅតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ ហើយគឺថាគឺត្រូវតែពិភាក្សាពីលើមកក្រោម ដើម្បីសម្រេច។ នេះជាការបកស្រាយរបស់ខ្ញុំទេ ប៉ុន្តែខ្ញុំមិនគិតថា នេះជាគំនិតដែលថាដាច់ណាត់នោះទេ។ ឲ្យច្បាស់លាស់ទេ នៅក្នុងកថាខណ្ឌ ប៉ុន្តែកថាខណ្ឌនេះគឺថា សមាជិក

សាមញ្ញហ្នឹងគឺមិនអាចតវ៉ាទៅលើចំណាត់ការនោះទេ។

[១១:៥៨:៤០]

ប៉ុន្តែមានតែសមាជិកបក្សទេ ជាអ្នកចាប់ផ្តើមដែលគេអាចនិយាយពីកិច្ចការបក្ស រីឯសមាជិកផ្សេងទៀត គឺមិនដឹងថា កិច្ចការបក្សអ្វីខ្លះទេ។ នោះ គឺថាវាមានការពិភាក្សាកម្រិតមួយ ហើយការពិភាក្សានោះ គឺថាបញ្ជូនទៅលំដាប់មួយទៀត ហើយការរកឃើញអ្វីនៅថ្នាក់ក្រោម គឺគេពិភាក្សាអាហ្នឹងអាចការពិភាក្សានេះឡើងទៅតាមពីលំដាប់ទៅ-- ពីក្រោមទៅលើ គឺថាអាចនឹងតាមឃ្លាគឺថាប្រជាធិបតេយ្យប្រមូលផ្តុំ គឺថាសេចក្តីសម្រេចហ្នឹងគឺថា ពីក្រោមទៅដល់លើ ទៅថ្នាក់លើជាអ្នកសម្រេច។ អ៊ីចឹងហើយគឺថា បើសិនជាមានការកែប្រែនៅថ្នាក់លើ គឺថាគេអាចកែប្រែសេចក្តីសម្រេចពីក្រោម គឺថា -- ហ្នឹងហើយបើការពិភាក្សាថ្នាក់ក្រោម ពេលខ្លះគេច្រានចោល គឺគេយកសេចក្តីសម្រេចរបស់ថ្នាក់លើគឺយកជាផ្លូវការ អាហ្នឹងគឺតាមន័យហ្នឹង។

[១១:៥៩:៤៤]

ប៉ុន្តែឃ្លានេះ គឺមានការពិបាកពិភាក្សា គឺថាអាចនៅក្នុងឆ្នាំ១៩៧០នោះគឺថា គឺចាត់ទុកថាឪពុកមួយជាប្រជាធិបតេយ្យប្រមូលផ្តុំ គឺថានៅពេលដែលលោកទៅដល់ចំណុចមួយ ហើយនៅឈរនោះ *(ឮមិនច្បាស់)* ហើយមើលតាមបង្អួចទៅ កូនក៏នឹងមើលឃើញថាតើអ្វី? ឥឡូវនេះ គឺថាយើងស្ពោះទឹកមាត់ទៅ។ នេះហើយគឺជាកំប្លែងមួយដែលនិយាយអំពីថា អ្វីដែលសមាជិកឃើញនេះ អាចមើលឃើញតែពីខាងក្រៅទេ មិនអាចសម្រេចអ្វីចូលទៅក្នុងថ្នាក់លើនោះបានទេ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន បាទ ឥឡូវនេះ គឺអ្នកជំនាញគាត់មិនមានសេចក្តីច្បាស់លាស់ក្នុងការពិភាក្សាទេ។ ដូច្នេះ ការតាំងសំណួរនោះគឺថាសហព្រះរាជអាជ្ញាគួរតែប្តូរសំណួរ ពីព្រោះសំណួរគាត់សុំឱ្យអ្នកជំនាញធ្វើការបកស្រាយ ហើយបើយើង -- ចំណុចមួយ គឺថាគាត់បានធ្វើការសន្និដ្ឋានច្រើនណាស់។ គាត់ជាអ្នកប្រវត្តិសាស្ត្រ គាត់បានអានឯកសារ គាត់អាចអត្ថាធិប្បាយ គាត់ជឿថាអ្វីអាចកើតមានឡើងទៅតាមហេតុការណ៍ដែលបានកើតឡើងនៅលើឯកសារសរសេរ។ ហើយគាត់មិនមែនជាអ្នកជំនាញខាងរដ្ឋធម្មនុញ្ញដើម្បីឱ្យបកស្រាយថា តើមានន័យដូចម្តេចទេ? ប្រសិនបើអាច ជាករណីដែលអាចជួយបាននោះ គឺប្រសិនបើសហព្រះរាជអាជ្ញាចង់បាន ថាតើអ្វីជាភស្តុតាងតាមអង្គហេតុនោះ ថាតើលក្ខន្តិកៈហ្នឹងគេអនុវត្តដូចម្តេចហ្នឹង? អាហ្នឹង គឺថាខ្ញុំមិនឡើងជំទាស់ទេ ប៉ុន្តែបើសិនជាលោកសួរបែបនេះ គឺថាសួរ

ឲ្យបកស្រាយឯកសារបែបនេះ គឺដូចជាយើងសួរគាត់ឲ្យផ្តល់យោបល់ក្នុងឋានៈជាអ្នកជំនាញ គឺគាត់នឹងធ្វើការសន្និដ្ឋានជាច្រើន ថាតើអ្វីវាបានជាអត្ថប្រយោជន៍ គឺថាវាមិនមានជាអត្ថប្រយោជន៍ទេ គឺថា -- ហើយខ្ញុំមិនយកចិត្តទុកដាក់អំពីរបបនោះដំណើរការនោះដូចម្តេចទេ។ ប៉ុន្តែគាត់ផ្តោតអារម្មណ៍ទៅលើតែប្រទេសមួយនេះនៅក្នុងរយៈកាលដែលមានកំណត់តែប៉ុណ្ណោះ។ សូមអរគុណ។

[១២:០២:១៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក អាប់ឌុលឡាក់ ថារីក៖**

បញ្ហានេះអាចនឹងកើតមានឡើង ហើយជាបន្តបន្ទាប់នៅពេលដែលយើងអនុវត្តទៅនឹងការសួរទៅលោកអ្នកជំនាញនោះ។ ប៉ុន្តែខ្ញុំគិតថា សហព្រះរាជអាជ្ញា លោកបានឆ្លើយរៀបរាប់បំភ្លឺអំពីតម្លៃភស្តុតាងអ្វីដែលគាត់បានដឹង។ គាត់មិនមែនសន្និដ្ឋាននោះទេ អំពីគោលការណ៍នេះ ត្រូវបានអនុវត្តនៅក្នុងការជាក់ស្តែង។ គាត់បាននិយាយអំពីការពិភាក្សាព័ត៌មានដែលហូរពីក្រោមទៅលើ ហើយបន្ទាប់មកគណៈមជ្ឈិមពិនិត្យមើលអ្វីទាំងអស់នោះ ហើយសម្រេច ហើយចេញមកជាច្បាប់។

[១២:០៣:០៤]

ហើយសហព្រះរាជអាជ្ញាបានពិភាក្សា -- អ្នកជំនាញបានពិភាក្សាសិក្សាអំពីរបបហ្នឹងមែន ហើយយើងគិតថា នេះជាជំនាញរបស់គាត់។ គឺយើងអាចសួរសំណួរបែបនេះទៅគាត់បាន មិនមែនសួរឲ្យគាត់ធ្វើការបកស្រាយបែបសន្និដ្ឋាននោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះបានប្រកាសទទួលស្គាល់នូវការកត់សម្គាល់របស់មេធាវី ម៉ៃខល កាណាវាស ដែលបានធ្វើលើកមុនថាជាមូលហេតុសមស្រប ហើយបានពន្យល់ ជម្រាបជូនទៅតំណាងសហព្រះរាជអាជ្ញាជាតិ កែសម្រួលនូវការតាំងសំណួររបស់ខ្លួនឲ្យសក្តិសមនឹងការតាំងសំណួរចំពោះសាស្ត្រាចារ្យប្រវត្តិសាស្ត្ររូបនេះ ទៅតាមអង្គហេតុនៃការចោទប្រកាន់ដ៏ទូលំទូលាយនៅក្នុងវិសាលភាពសំណុំរឿង០០២/០១ ចៀសវាងត្រឹមតែតាំងសំណួរឲ្យលោកសាស្ត្រាចារ្យពន្យល់ពាក្យ។ យើងបានជម្រាបរំឭករួចហើយ។ ដោយឡែកសេចក្តីជំទាស់របស់លោកមេធាវីការពារក្តី លោក ម៉ៃខល

កាណាវាស អម្បាញ់មិញនេះ។ ខ្ញុំគិតថាប្រហែលជាមិនទំនងទេ ដោយសារមូលហេតុសេចក្ដីជំទាស់ត្រូវធ្វើមុនពេលសាក្សី ឬអ្នកជំនាញផ្ដល់សក្ខីកម្ម។ មិនមែនចាំដល់តែឆ្លើយពាក់ -- ផ្ដល់ចម្លើយជិតចប់ ឬពាក់កណ្ដាលទី ទើបធ្វើការជំទាស់នោះទេ។ សូមឲ្យពិនិត្យ ពិចារណា និងអនុវត្តនូវវិធានទាំងឡាយដែលចែងពាក់ព័ន្ធនឹងការស្ដាប់សក្ខីកម្មភាគី សាក្សី អ្នកជំនាញ ដែលភាគីមានសិទ្ធិនៅក្នុងការជំទាស់ទៅនឹងការស្ដាប់ដែលកំពុងដំណើរការ ប្រសិនខ្លួនយល់ឃើញថា ចម្លើយនោះមិនសម្ដែងឲ្យឃើញការពិត។ នៅក្នុងករណីនេះប្រធានសាលាដំបូងត្រូវសម្រេចថា តើត្រូវស្ដាប់ ឬមិនចាំបាច់ត្រូវស្ដាប់នូវសក្ខីកម្ម ឬក៏ចម្លើយនោះ។ នេះជានីតិវិធីដែលយើងបានអនុវត្តរួចហើយ។ អង្គជំនុំជម្រះសង្ឃឹមថា ភាគីដែលពាក់ព័ន្ធនៅក្នុងរឿងក្ដីនេះ ដែលរង់ចាំស្ដាប់ការសួរដេញដោល គឺនឹងអនុវត្តឲ្យបានល្អតាមវិធាន និងច្បាប់ក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរ ដែលចែងពាក់ព័ន្ធនឹងនីតិវិធីនៃការជំទាស់ទៅនឹងការតាំងសំណួរដេញដោលផ្សេងៗ។ ជាការពិតណាស់ អង្គជំនុំជម្រះក៏ជាមានឆន្ទានុសិទ្ធិក្នុងនៅក្នុងការសម្រេចលើបញ្ហានេះដែរ ប៉ុន្តែការសម្រេចពាក់ព័ន្ធនឹងរឿងក្ដីដ៏ធំធេងរបៀបនេះ គឺមានការលំបាកខ្លះដែរក្នុងការសម្រេច ថាតើសម្រេចយ៉ាងដូចម្ដេច? ដូច្នេះអង្គជំនុំជម្រះក៏រង់ចាំនូវមតិយោបល់របស់គូភាគីដែរ ប៉ុន្តែមិនរង់ចាំរហូតដល់ឆ្លើយពាក់កណ្ដាលទី ឬក៏ឆ្លើយចប់ទើបជំទាស់នោះទេ។

[១២:០៦:០៧]

បាទ ឥឡូវនេះសូមអរគុណលោកតំណាង -- អំ លោកអ្នកជំនាញ។ ឥឡូវនេះដល់ពេលសម្រាកដើម្បីពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ ចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ អញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកសមរម្យនៅក្នុងរយៈពេលសម្រាកពិសាថ្ងៃត្រង់ ដល់អ្នកជំនាញ។ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះ នៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះនៅវេលាម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា!

**លោក ហ្សាស្តើ ប៉ោះ**

សូមអរគុណលោកប្រធាន។ កូនក្ដីរបស់ខ្ញុំ នួន ជា សូមអនុញ្ញាតទៅតាមដានសវនាការនៅបន្ទប់ខាងក្រោមនេះ ហើយខ្ញុំនឹងរៀបចំលិខិតបោះបង់សិទ្ធិរបស់គាត់តាមនីតិវិធីជូនតុលាការ បាទ។

[១២:០៧:១៧]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអាចពន្យល់ពីហេតុផលបានទេ ដូចជាសុំហ្វឹងងាយពេក ដូចអត់មានឃើញបង្ហាញហេតុផលសោះ។ មូលហេតុអីទៅក្នុងការលះបង់សិទ្ធិមិនចូលរួមសវនាការនៅរសៀលនេះរបស់កូនក្តីរបស់លោក?

**លោក ហ្សាស្តើ ប៉ោ៖**

លោកប្រធាន ដូចដែលបាន ករណីដែលបានលើកឡើងខាងដើម ថាលោក នួន ជា មានការលំបាកក្នុងការតាមដានផ្តង់អារម្មណ៍ទៅនីតិវិធី ហើយគាត់មានសុខភាពមិនសូវល្អទេ នៅពេលល្ងាចនឹងនឿយហត់ខ្លាំង ហើយនិងគាត់ចង់ទៅតាមដាននីតិវិធីនៅខាងក្រោម ហើយដើម្បីកំណត់ត្រា គឺថាតាមពិត នៅពេលគាត់នៅខាងក្រោមនោះ គាត់មិនអាចតាមដានទាំងស្រុងទេ នៅពេលខ្លះយើងខ្ញុំនឹងជម្រាបៗជូន។ ប៉ុន្តែដើម្បីកំណត់ត្រាលោក នួន ជា មិនតែងតែតាមដានសកម្មរហូតនោះទេ នៅក្នុងដំណើរការនីតិវិធី។ នៅពេលដែលមានមូលហេតុខាងសុខភាព ចំពោះសំណើរបស់គាត់នេះ គឺថាដូចតែមានខាងដើម គឺថាអលទ្ធភាពក្នុងការតាមដានទាំងស្រុង។ ហើយដូច្នេះគាត់មានសិទ្ធិ មិនអាចអង្គុយបានយូរ គាត់អាចទម្រេតនៅក្នុងកៅអី ដើម្បីតាមដានបាននៅបន្ទប់ខាងក្រោមនោះ។

[១២:០៨:៤៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០៩:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់លោកជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់។ ស្នើសុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈសោតទស្សន៍ដោយលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយមូលហេតុមានការនឿយហត់ និងលំបាកនៅក្នុងការតាមដានកិច្ចដំណើរសវនាការដោយផ្ទាល់។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

[១២:១០:៤៨]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ត្រូវប្រគល់ជូនមកអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការនៅរសៀលនេះ។

ហើយអង្គជំនុំជម្រះក៏សូមធ្វើការកត់សម្គាល់ និងជម្រាបជូនទៅមេធាវីការពារក្តីលោក នួន ជា ផងដែរ។ នៅពេលនេះអង្គជំនុំជម្រះបានសម្រេចតាមសំណើសុំមែន ប៉ុន្តែធ្វើការកត់សម្គាល់ថា សំណើរបស់លោក គឺត្រូវតែពិគ្រោះយោបល់ជាមួយនឹងកូនក្តីរបស់លោកជាក់ច្បាស់ ហើយនិងបង្ហាញអំពីមូលហេតុជាក់ច្បាស់។ ហើយមូលហេតុហ្នឹងមិនមែនរឿងដដែលនោះទេ ត្រូវតែមានមូលហេតុសមរម្យដែលឲ្យអង្គជំនុំជម្រះមានមូលដ្ឋានក្នុងការពិចារណា សម្រេចអំពីបញ្ហានេះ។ បើពុំដូច្នោះទេ គឺអង្គជំនុំជម្រះនឹងពិចារណាទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន នៅក្នុងករណីដែលមិនមានមូលហេតុ ឬក៏មូលហេតុដដែលៗ ដែលគ្មានភស្តុតាងបញ្ជាក់។

[១២:១២:០៣]

ហើយចុងក្រោយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។ ដោយរសៀលនេះទុកឲ្យលោក នួន ជា ស្ថិតនៅក្នុងបន្ទប់ដែលរៀបចំទុកសម្រាប់ -- នូវ -- ជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួមកិច្ចដំណើរការសវនាការពីចម្ងាយ។ ហើយដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយសាមសិបនាទីរសៀលនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១២ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចនីតិវិធីសវនាការ។ ហើយជាបន្ត អង្គជំនុំជម្រះនឹងប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

សូមអញ្ជើញ!

**លោក ច័ន្ទ តារាវស្នើ៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក ច័ន្ទ តារាវស្នើ៖**

**ស៖** ជាបន្តនេះ ខ្ញុំសូមសួរសំណួរទៅលោក ដេវីដ ឆេនដ៍ល័រ ជាថ្មីម្តងទៀតទាក់ទិនទៅនឹងខ្លឹមសារនៅក្នុងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្ត។ ហើយខ្ញុំសូមយោងទៅលើមាត្រា៣ មាត្រា៦។ បាទ សូមបង្ហាញអត្ថបទនេះនៅក្នុងអេក្រង់កុំព្យូទ័រ។ ចំពោះមាត្រា៣ បានមើលព្រឹកមិញហើយគឺ ERN 00 -- ខ្មែរ ERN 00442262, ERN ជាភាសាអង់គ្លេស 00184032 ហើយជាភាសាបារាំងគឺ ERN 00292922 បាទ ខ្ញុំសូមភ្ជាប់អត្ថបទនេះគឺជាមួយនឹងមាត្រា៦។ បាទ សូមបង្ហាញមាត្រា៦ គឺ ERN ជាភាសាខ្មែរ 00442268, ERN ជាភាសាអង់គ្លេស 00184037, ERN ជាភាសា--

[១៣:៣២:៣៧]

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យលោកព្រះរាជអាជ្ញាអាន ERN ម្តងទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមតំណាងសហព្រះរាជអាជ្ញាជាតិអានលេខ ERN ម្តងទៀត លេខហ្នឹងគួរតែត្រូវបានអានយ៉ាងយឺតបំផុត ដើម្បីឲ្យការស្តាប់ និងការកត់ត្រាប្រតិចារឹកហ្នឹងគឺបានត្រឹមត្រូវ។ ជាពិសេស គឺអ្នកបកប្រែភាសា។

**លោក ច័ន្ទ តារាវស្នើ៖**

បាទ សូមអរគុណ។ ខ្ញុំសូមអានមាត្រា៦ ជាថ្មីម្តងទៀត។ ERN ខ្មែរលេខ 00442268, ERN ជាភាសាអង់គ្លេស 00184037, ERN ជាភាសាបារាំង 00292926 បាទ។

[១៣:៣៣:៤២]

**សួរដោយលោក ច័ន្ទ តារាវស្នឹះ**

**ស៖** លោក ដេវីដ ឆេនដ៍ល័រ សូមលោកអាន មេត្តាអានអត្ថបទនេះ។ ហើយខ្ញុំសូមសួរសំណួរទៅលោក។ ខ្ញុំអានអត្ថបទនេះដកស្រង់ជាភាសាខ្មែរ ជូនអង្គសវនាការជ្រាបអំពីខ្លឹមសារនៅក្នុងមាត្រា៣ និងមាត្រា៦ ហ្នឹងបាទ។ ក្នុងមាត្រា៣ គឺមាននិយាយអំពីសិទ្ធិរបស់បក្ខជន។ បក្ខជនពេញសិទ្ធិគ្រប់រូប សុទ្ធតែមានសិទ្ធិដូចតទៅ៖ ក) ពិគ្រោះពិភាក្សា និងរួមមតិសម្រេចកិច្ចការទាំងអស់របស់បក្សកុម្មុយនីស្ត ដោយធ្វើទៅតាមលាក់ការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ។

ហើយចំពោះមាត្រា៦ ខ្ញុំសូមដកស្រង់មាត្រា៦។ សូមអានដូចតទៅ៖ បក្សកុម្មុយនីស្តកម្ពុជា ប្រកាន់យកគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ ធ្វើជាមូលដ្ឋានចាត់តាំងរបស់ខ្លួនគឺ៖ ១) គ្រប់ៗអង្គការដឹកនាំរបស់បក្សកុម្មុយនីស្តៗ ត្រូវអនុវត្តរបបដឹកនាំសមូហភាព ហើយមានបុគ្គលទទួលខុសត្រូវដោយឡែក។ ចំណុចទី២) គ្រប់ការសម្រេចផ្សេងៗរបស់បក្សកុម្មុយនីស្ត ត្រូវធ្វើឡើងដោយសមូហភាពបាទ។

[១៣:៣៥:១១]

ចំពោះចំណុចទីបួន ខ្ញុំសូមដកស្រង់ចំណុចទីបួន នៅក្នុងមាត្រា៦នេះ៖ "ភាគតិចគោរពភាគច្រើន ថ្នាក់ក្រោមគោរពថ្នាក់លើ បុគ្គលគោរពសមូហភាព ឯកជនគោរពអង្គការ អង្គការថ្នាក់ផ្សេងៗគោរពអង្គការមជ្ឈិម"។ បាទ នេះគឺជាខ្លឹមសារដែលខ្ញុំបានដកស្រង់នៅក្នុងមាត្រា៦ នៅក្នុងលក្ខន្តិកៈ។ ហើយខ្ញុំសូមសួរទៅលោក ដេវីដ ឆេនដ៍ល័រ ទាក់ទងទៅនឹងខ្លឹមសារមាត្រា៣ និងមាត្រា៦ នេះ តើលោកបានអានហើយឬនៅបាទ? បាទ លោកបានអានហើយ ខ្ញុំសូមសួរសំណួរ។

ផ្អែកលើការស្រាវជ្រាវរបស់លោក ៗកន្លងមក តើការអនុវត្តគោលការណ៍ទាំងអស់នេះ ដូចគ្នានឹងអ្វីដែលបានចែងនៅក្នុងគោលការណ៍នេះ ឬក៏មានការខុសគ្នាយ៉ាងដូចម្តេចនៅក្នុងសម័យកាលនោះបាទ?

[១៣:៣៦:១៩]

**ប្រធានអង្គជំនុំ៖**

លោកអ្នកជំនាញកុំអាលទាន់ឆ្លើយតប ចាំស្តាប់ការមតិជំទាស់ពីមេធាវីអន្តរជាតិការពារក្តីលោក អៀង សារី ជាមុនសិន។ សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ សូមជម្រាបសួរលោក លោកស្រីទាំងអស់។ លោកសហព្រះរាជអាជ្ញាអានមាត្រាជាច្រើននៅក្នុងលក្ខន្តិកៈ ហើយសុំឱ្យអ្នកជំនាញឆ្លើយថាមែនឬទេ។ សូមឱ្យសហព្រះរាជអាជ្ញា ទៅជំហានម្តងៗ ទើបបានល្អ។ កាលណាលោកសួរសរុបឱ្យបញ្ជាក់អ្វីៗទាំងអស់បែបនេះ ដូចជា មិនសមស្របទេ គប្បីមួយមាត្រាម្តង មួយខ្លឹមសារម្តង ទើបអាចទៅរួចបាទ។

**លោក ច័ន្ទ តាវារស្មី៖**

សូមជម្រាបលោកប្រធាន ក៏ដូចជា លោកមេធាវី កាណាវាស។ ខ្ញុំ -- អត្ថបទនេះ គឺខ្ញុំបាទសួរលោក ដេវីដ ឆេនដ៍ល័រ ហើយ គាត់ថា គាត់បានអាន គាត់បានដឹងហើយ អ៊ីចឹងបានខ្ញុំចាប់ផ្តើមសួរសំណួរនេះ។ ហើយចំពោះមាត្រា៣ ហ្នឹងគឺបន្តពីព្រឹកមិញហើយទេ ហើយគ្រាន់តែខ្ញុំភ្ជាប់មាត្រា៣នេះភ្ជាប់មកជាមួយមាត្រា៦ ប៉ុន្តែខ្លឹមសារ ដែលខ្ញុំចង់សួរសង្កត់ធ្ងន់នេះគឺ ចង់ដឹងអំពីការអនុវត្តជាក់ស្តែងឆ្លងតាមការស្រាវជ្រាវរបស់លោក ដេវីដ ឆេនដ៍ល័រ ហ្នឹង តើការអនុវត្តជាក់ស្តែង ដូចគ្នានឹងអ្វីដែលបានចែងនៅក្នុងលក្ខន្តិកៈ មាត្រា៦ ដែលខ្ញុំបានស្រង់នេះដែរឬទេ។

[១៣:៣៧:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់លោកមេធាវីអន្តរជាតិការពារក្តីលោក អៀង សារី គ្មានប្រសិទ្ធភាព។ សាក្សី លោក ដេវីដ ឆេនដ៍ល័រ ប្រសិនបើលោកអាចឆ្លើយនឹងសំណួរបាន សូម -- និយាយបាន សូមលោកឆ្លើយ ហើយសូមជម្រាបលោកផងដែរថា នៅក្នុងកិច្ចដំណើរការយើងនេះ គឺយើងប្រើបីភាសា ហើយតាមសំណើសុំរបស់ខាងអ្នកបកប្រែភាសា សូមឱ្យលោកអ្នកជំនាញនិយាយឱ្យបានយឺតបន្តិចពីព្រោះបកប្រែអត់ទាន់។ អ៊ីចឹងវាបាត់នូវខ្លឹមសារខ្លះនៅក្នុងការដំណើរការសវនាការនេះ។

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** សូមជម្រាប នេះសំណួរល្អណាស់ ហើយខ្ញុំឃើញថា នេះជាគំនិតដឹកនាំទាំងមូល នៅក្នុងប្រយោគដែលលោកបានលើកឡើងនេះក្នុងឯកសារនេះ។ គឺគំនិតមួយគឺថា ផ្ទុះបញ្ចាំងទៅនឹងការអនុវត្តនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ បើសំណួរសួរបែបនេះ ខ្ញុំមិនអាចឆ្លើយបានទេ។ ហើយគឺថានៅក្នុងគ្រប់លំដាប់ថ្នាក់ នៅក្នុងតំបន់ភូមិភាគជាដើមហ្នឹងគឺថា អនុលោមទៅតាមគោលការណ៍របស់

របបនោះគឺថា មនុស្សនៅថ្នាក់ក្រោមគឺថា មិនគោរពវិធាននេះទេពេលខ្លះ។ នៅពេលដែលអ្នកណាមិនគោរព គេនឹងយកមកធ្វើការអប់រំ ដើម្បីជាការដាក់ពិន័យ។ ជួនកាលវិធានទាំងអស់នេះ គេមិនគោរព ជួនកាលគេគោរព ពេលខ្លះគេគោរព ប៉ុន្តែមិនអាចឆ្លើយជាប្រព័ន្ធបានទេ។ គឺចំណុចសំខាន់នៅក្នុងផ្នែកនេះ គឺជាវិធីដែលគេសរសេរ អំពីគំនិតគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ ដែលៗក្បាលម៉ាស៊ីន ក្រុមក្បាលម៉ាស៊ីននោះគឺថា កំណត់ពាក្យអ្វីៗទាំងអស់ ជាក្រុមមេដឹកនាំសមូហភាពនៅកំពូល។ ហើយពាក្យហ្នឹងគឺថា ផ្ទុះបញ្ចាំងនៅក្នុងឯកសារនេះឯង ពាក្យរបស់ពួកគាត់។ បើចង់និយាយថា ផ្ទុះបញ្ចាំងនៅក្នុងការអនុវត្តនោះ ខ្ញុំមិនអាចឆ្លើយលោកព្រះរាជអាជ្ញាបានទេ។

[១៣:៤០:១០]

**ស៖** អរគុណលោក ដេវីដ ឆេនដ័ល័រ។ ខ្ញុំសូមសួរបន្តទៀត បើផ្អែកលើការសិក្សាស្រាវជ្រាវរបស់លោក អំពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាជាពិសេសផ្អែកលើការសិក្សារបស់ដោយផ្តោតជាសំខាន់ទៅលើលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តនេះ តើលោកអាចបញ្ជាក់បានទេ ឬក៏លោកធ្លាប់បានឃើញ បានស្រាវជ្រាវឃើញដែរឬទេ អំពីថាតើថ្នាក់ណាជាថ្នាក់លើ? ហើយថ្នាក់ណាជាថ្នាក់ក្រោម? នៅក្នុងកថាខណ្ឌនៃមាត្រា៦ ហ្នឹង គឺកថាខណ្ឌទី៤ មាននិយាយអំពីថ្នាក់លើ និងថ្នាក់ក្រោម។ អ៊ីចឹង ខ្ញុំចង់ដឹងអំពីបទពិសោធន៍នៃការស្រាវជ្រាវរបស់លោក តើលោកបានឃើញអត្ថបទ ឬឯកសារណាបញ្ជាក់ច្បាស់អំពីតើថ្នាក់លើគឺជានរណា? ហើយថ្នាក់ក្រោមគឺជានរណា?

[១៣:៤១:១៧]

**ឆ៖** ខ្ញុំមិនច្បាស់ទេ នៅក្នុងថ្នាក់មួយៗ ដែលមានក្រុមធំ យោងទៅរកក្រុមមួយតូចទៀត បន្ទាប់មកក្រុមមួយទៀតតូចជាងក្រុមមួយទៀត។ វាមានលក្ខណៈជាពីរ៉ាមីត គឺថាក្រុមមួយៗយោងទៅថ្នាក់លើ ហើយក្នុងថ្នាក់លើហ្នឹងកាន់តែតូច កំពូល។ នោះហើយគឺជាៗកម្លាំងធំបំផុតរបស់អង្គការរបស់គេនោះ។ ដូចដែលខ្ញុំ គឺថាសំណើគឺមិនជាទូទៅ មិនពីក្រោមទៅលើទេ គឺភាគច្រើនពីលើមកក្រោម។ បាទ គឺមិនអនុញ្ញាតឲ្យមានមតិយោបល់ទៅនឹងសេចក្តីសម្រេចពីថ្នាក់លើនោះទេ គឺពីលើមកក្រោម។

ខ្ញុំមានការពិបាកក្នុងការបញ្ជាក់ថាតើមានទំហំថ្នាក់ក្រោមប៉ុនណា ថ្នាក់លើប៉ុនណា នៅថ្នាក់តំបន់ ឬភូមិភាគ ឬក៏នៅក្នុងតំបន់ណាមួយនោះ។ គឺថាជាទូទៅ គឺថាផ្នែក ឬក៏តំបន់ ឬក៏កន្លែងមួយវាតែងតែមានថ្នាក់លើរបស់គេ ហើយគេតែងតែរាប់ថាទៅថ្នាក់លើបន្ត ហើយនៅនៅខាងលើហ្នឹង គឺមានចំនួនកាន់តិចទៅ។ បាទ ដែលហៅថាក្បាលម៉ាស៊ីនហ្នឹង គឺៗជាគ្រឿងក្បាលម៉ាស៊ីនរបស់បក្ស

នោះ គឺមានទំហំតូច។

**ស៖** បាទ សូមអរគុណ។ តែលោកអត់អាចបញ្ជាក់បានទេថា លក្ខណៈសម្បត្តិរបស់ថ្នាក់លើហ្នឹងមានលក្ខណៈសម្បត្តិបែបណា ដើម្បីឲ្យបក្ខជន ឬក៏មនុស្សណាដែលចូលថ្នាក់លើ ឬចូលថ្នាក់ក្រោម តើមានលក្ខណៈសម្បត្តិបែបណាដើម្បីបញ្ចូលសមាជិកចូលក្នុងថ្នាក់លើ ឬថ្នាក់ក្រោមក្នុងការសម្រេចកិច្ចការអ្វីមួយនោះ? តើលោកធ្លាប់បានស្រាវជ្រាវឃើញអំពីលក្ខណៈសម្បត្តិរបស់ថ្នាក់លើ ឬថ្នាក់ក្រោមនុ៎ងដែរឬទេ នៃមនុស្សដែលត្រូវបញ្ចូលទៅក្នុងហ្នឹង ហើយមានសិទ្ធិអំណាចសម្រេចអ្វីខ្លះនោះ?

[១៣:៤៣:១៨]

**ឆ៖** ខ្ញុំមិនបានធ្វើការសិក្សាលើប្រធានបទនោះទេ។ នេះជាប្រធានបទគួរឲ្យចាប់អារម្មណ៍ ប៉ុន្តែខ្ញុំមិនបានពិនិត្យរកលទ្ធផលនេះទេ។

**ស៖** អរគុណលោក ដេវីដ ឆេនដ័ល័រ។ សំណួរបន្តទៅទៀត ទាក់ទងនឹងបញ្ហា ខ្ញុំសូមឆ្លងចូលប្រធានបទអំពីសមាជិកភាពរបស់បក្សកុម្មុយនីស្តកម្ពុជា។ ផ្អែកតាមលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តនេះ គឺឃើញមានចំណុច១០យ៉ាង មានលក្ខណៈសម្បត្តិ១០យ៉ាងស្តីអំពីសមាជិកភាព។ ខ្ញុំសូមឲ្យលោកមេត្តាអានពិនិត្យឯកសារ ហើយខ្ញុំសូមជូនឯកសារតាមមាត្រា៥។ សូមបង្ហាញមាត្រា៥ គឺផ្អែកលើចំណុច១, ៣, ៥, ៧ និង ៨។ ខ្ញុំស្រង់ ដកស្រង់លើខ្លឹមសារមាត្រា៥ ត្រង់ចំណុច ១, ៣, ៥, ៧ និង ៨។ ហើយសូមជូនជា ERNៗ ជាភាសាអង់គ្លេស លេខ 00184034 ដល់ 36, ERN ជាភាសាបារាំង 00292923 ដល់ 25, ERN ជាភាសាខ្មែរលេខ 00442264 ដល់ 66។

បាទ ខ្ញុំសូមបង្ហាញឯកសារនេះលើអេក្រង់ ហើយសូមឲ្យលោក ដេវីដ ឆេនដ័ល័រ មេត្តាពិនិត្យលើទៅឯកសារនេះ ហើយខ្ញុំនឹងសួរសំណួរលោកបន្តិចទៀតនេះបាទ។

[១៣:៤៥:២៧]

ទំព័រទី១៣ បាទ នៅក្នុង -- លោកៗសូមអញ្ជើញលោកអានជាភាសាអង់គ្លេសទំព័រទី១៣ បាទ ទំព័រទី១៣។ ត្រង់ចំណុចទី១, ទី៣, ទី៥, ទី៧ និងទី៨។ បាទ ទី១, ទី៣, ទី៥, ទី៧ និងទី៨ លោកបានអានទេបាទ? ខ្ញុំអាចសួរលោកបានទេបាទ?

**ឆ៖** បាទ លោកអាចសួរបាន។

**ស៖** ខ្ញុំសូមសួរសំណួរនេះ។ នៅក្នុងមាត្រា៥ នេះ ផ្អែកលើចំណុច ១, ៣, ៥, ៧, និង៨ នេះ សូមឲ្យលោកមេត្តាបញ្ជាក់ថា តើតាមការសិក្សាស្រាវជ្រាវរបស់លោក ផ្អែកលើលក្ខន្តិកៈហ្នឹង តើលក្ខខណ្ឌតម្រូវទាំងអស់នេះ លោកបានសិក្សាស្រាវជ្រាវឃើញ វាបានឆ្លុះបញ្ចាំងអំពីអ្វីខ្លះបាទ? នៅក្នុងការអនុវត្តជាក់ស្តែង តើមាត្រា៥ ខ្លឹមសារ ១, ៣, ៥, ៧, និង៨ តើឆ្លុះបញ្ចាំងអំពីអ្វីនៅក្នុងសម័យនោះ?

[១៣:៤៧:១០]

**ឆ៖** ជាលក្ខណៈវិនិច្ឆ័យដែលបង្ហាញនេះ ភាគី បក្សគឺថាបានដាក់លក្ខណៈវិនិច្ឆ័យគឺចង់សមាជិកទាំងអស់ បំពេញតាមលក្ខខណ្ឌហ្នឹង គឺជាបញ្ជីនៃលក្ខណៈវិនិច្ឆ័យដែលថាសមាជិកត្រូវតែបំពេញតាមដើម្បីចូលជាសមាជិក។ ខ្ញុំគិតថា ប្រសិនបើលោកពិនិត្យមើលដកនោះ គឺថា ពិនិត្យផ្ទៀងផ្ទាត់អ្វីដែលគេនិយាយនេះ យើងអាចនឹងឃើញថា គេបានៗធ្វើខុស ឬក៏ផ្ទុយពីមាគ៌ាបក្ស ត្រង់ចំណុចលេខ១ជាដើម ឬក៏គេបានដាកចេញអំពីសាមគ្គីភាព ឬក៏ឯកភាព ដូចជាត្រង់ចំណុច៣, ៥ ដែលថាអាចផ្ទុយទៅនឹងគោលនយោបាយពីការរក្សាការសម្ងាត់ ដូចជាប្រាំពីរ ចំណុច៧ ជាដើមហ្នឹង។ គេត្រូវតែធ្វើការពិនិត្យប្រវត្តិរូបផ្ទាល់ខ្លួន ហើយនិងរបស់អ្នកដទៃ ដើម្បីធ្វើឲ្យដឹងថា អ្នកហ្នឹងពិតជាបដិវត្តដែរឬអត់ មានជំហររឹងមាំលើវណ្ណៈដែរឬអត់ ហើយបាទ គេត្រូវបំពេញទៅតាមនិយមន័យ ហើយនិងជនបដិវត្តន៍ ហើយនិងលក្ខណៈវិនិច្ឆ័យទាំងអស់ដែលគេកំណត់ហ្នឹងដែរឬអត់? នេះគឺជាលក្ខខណ្ឌខាងមនោគមន៍វិជ្ជា។

ខ្ញុំយល់ថា គឺថាវាមិនមានលក្ខណៈច្បាស់លាស់ទេ ពាក្យពេចន៍នេះ គឺថាវាជាការងាយស្រួលដើម្បីឲ្យគេនឹងដក ឬក៏មិនផ្តល់សមាជិកភាព។ យើងមិនដឹងថា តើគោលជំហររបស់អ្នកណាហ្នឹងគឺថារឹងមាំប៉ុនណា? ពាក្យថា "រឹងមាំ" នេះគឺថាជាពាក្យរបស់អ្នកសម្រេចទេ ពីព្រោះថាគួរឲ្យអស់សំណើច យើងគិតថា យើងមើលបញ្ហាហ្នឹង គឺថាដើម្បីយើងពិនិត្យមើលថាតើខ្លាំង ឬខ្សោយ គោលជំហរហ្នឹង គឺថយើងពិបាកនឹងកំណត់ណាស់ មានតែថ្នាក់លើគេអ្នកនិយាយ។

[១៣:៤៩:២១]

ជាថ្មីម្តងទៀត នេះគឺជាលក្ខណៈវិនិច្ឆ័យខាងមនោគមន៍វិជ្ជា ដើម្បីតម្រូវឲ្យភាគីគោរពតាម។ ប៉ុន្តែមិនប្រាកដថា សមាជិកទាំងអស់ហ្នឹង បំពេញតាមហ្នឹងដែរឬអត់ទេ គ្រាន់តែជាគំនិតតែប៉ុណ្ណឹងទេបញ្ហានេះ។ ប៉ុន្តែការសម្រេចនេះគឺមិនៗធ្វើការវិនិច្ឆ័យដោយខ្លួនឯងនោះទេ គឺថាវាត្រូវផ្អែកលើថ្នាក់ផ្សេងៗទៀត នៃសមាជិកថ្នាក់ដឹកនាំរបស់ថ្នាក់មួយៗ។ បើនិយាយពីជំហររឹងមាំនេះ គឺថាពិបាកនិយាយ។ នេះដូចថា បើយើងថា បើពាក់អាវខៀវ យើងឃើញថាអ្នកហ្នឹងអាវខៀវហើយ ប៉ុន្តែបើថា

ជំហររឹងមាំវាពិបាកនឹងធ្វើការវិនិច្ឆ័យណាស់។ អានេះជាលក្ខណៈវិនិច្ឆ័យដែលអាចនឹងបត់បែនបាន ថា តើអាចបត់បែនបានឬអត់ ដើម្បីឲ្យគេធ្វើវិនិច្ឆ័យម៉េច ប្រសិនបើគេមិនគោរពតាមលក្ខណៈវិនិច្ឆ័យនេះនោះ។ នេះជាចំណុចពិបាកណាស់ ពីព្រោះថាខ្ញុំមិនបានចូលរួមក្នុងការពិភាក្សានោះទេ ខ្ញុំបានអានតែប្រតិចារឹកនិងកំណត់ត្រាតែប៉ុណ្ណឹង។ គឺថាអាចនឹងឃើញថា វាមានការបត់បែនបានខ្លះ។ ប៉ុន្តែការវិនិច្ឆ័យនោះ ដូចវាមានលក្ខណៈតឹងរ៉ឹង បើសិនជាគំនិតមួយដែលយើងឃើញថា ពេលខ្លះគេធ្វើស្វ័យទិតៀន និងទិតៀនអ៊ីចឹង ពេលខ្លះគេកែតម្រូវគ្នាទៅវិញទៅមកអ៊ីចឹងដែរ។

[១៣:៥១:០៥]

**ស៖** អរគុណលោក ដេវីដ ឆេនដ័ល័រ។ ខ្ញុំសូមសួរមួយសំណួរទៀត ដែលពាក់ព័ន្ធនឹងបញ្ហានេះជាចំណុចសំខាន់ថែមទៀត។ ផ្អែកតាមការសិក្សាស្រាវជ្រាវរបស់លោកលើប្រវត្តិនៃបក្សកុម្មុយនីស្តកម្ពុជា ជាពិសេសលើលក្ខន្តិកៈនេះ តើលោកធ្លាប់បានសិក្សាស្រាវជ្រាវឃើញ ឬក៏រកឃើញអត្ថបទណាដែលបានបញ្ជាក់ច្បាស់អំពីមូលហេតុអ្វីបានជាបក្សកុម្មុយនីស្តកម្ពុជាជ្រើសរើសយកពាក្យដូចជា "ជំហរបដិវត្តន៍រឹងប៉ឹងខាងការធ្វើ និងត្រួតពិនិត្យប្រវត្តិរូប ជំហរបដិវត្តន៍រឹងប៉ឹងខាងវណ្ណភាព" មកសរសេរក្នុងមាត្រា៥នេះ។ ហើយចាត់ទុកថា ជំហរទាំងអស់នេះពិតជាមានសារៈសំខាន់សម្រាប់បក្សកុម្មុយនីស្តកម្ពុជានាសម័យកាលនោះ? អ៊ីចឹងសូមលោកមេត្តាបញ្ជាក់ បើសិនលោកអាចបញ្ជាក់បានអំពីចំណុចនេះ។

[១៣:៥២:១៨]

**ឆ៖** នេះជាសំណួរល្អ ខ្ញុំពិបាកនឹងឆ្លើយណាស់។ ខ្ញុំគិតថា អ្នកដែលចូលទៅក្នុងបក្សជួនកាលអ្នកខ្លះប្រញាប់ចូលជាសមាជិក ដោយហេតុថាវាមានចន្លោះប្រហោងដែលគេអាចចូលបាន ប៉ុន្តែគេបានដាក់ឲ្យនៅត្រៀម ដើម្បីពិនិត្យ ដើម្បីបំពេញទៅតាមលក្ខខណ្ឌដែលថា ត្រឹមត្រូវដើម្បីឲ្យឃើញថាខ្លួនឯងខ្លាំង ស្មោះត្រង់ជាដើម ដើម្បីចូលជាសមាជិក។ ហើយការវិនិច្ឆ័យផ្អែកទៅលើលក្ខណៈពិសេសទាំងនោះ ហើយយើងឃើញថា នៅក្នុងប្រវត្តិជីវិតរបស់អ្នកឃាមនៅទួលស្លែង ថាតើនៅក្នុងផ្ទះមួយ តើមានដំបូលដូចម្ដេច បើសិនយើងកើតក្នុងគ្រួសារដែលមានដំបូលស្បូវ ឬដំបូលក្បឿង។ អាហ្នឹងគេវិនិច្ឆ័យទៅតាមហ្នឹង។ ថាតើជាកសិករកណ្ដាលថ្នាក់ក្រោម ថ្នាក់លើ ឬក៏កសិករបែបម៉េច។ ដើម្បីនិយាយ គឺគេនិយាយពីដំបូលផ្ទះរបស់អ្នកហ្នឹងទៅវិញ អាហ្នឹង។ ឧទាហរណ៍ថា យើងអាចមានបងប្អូនជីដូនមួយនៅរបប លន់ នល់ យើងមិនដែលបានជួប ប៉ុន្តែបើមានបងប្អូនជីដូនមួយបែបនេះ គឺថាគេមិនបំពេញ

លក្ខខណ្ឌទេ យើងមិនអាចចូលបក្សបានទេ។ មិនអាចជាបុគ្គលត្រៀមទេ ព្រោះយើងមានខ្សែ ហើយខ្សែរបស់យើងមិនខ្លាំង មិនស្មោះត្រង់បាទ។ អាហ្នឹងគឺគេ -- ទៅតាមគំនិតគឺថា បែបបត់នេះគឺតម្រូវគំនិតមួយ គឺថា ឌី.ខេ -- កម្ពុជាប្រជាធិបតេយ្យនេះមានរយៈពេលខ្លី ប៉ុន្តែគេត្រូវចំណាយពេលយូរដើម្បីក្លាយទៅជាសមាជិក ប៉ុន្តែត្រូវឆ្លងលក្ខណៈវិនិច្ឆ័យនីមួយៗ។ ប៉ុន្តែលក្ខណៈវិនិច្ឆ័យទាំងអស់នេះ គឺថាពេលខ្លះគេយកអ្នកណាម្នាក់ គេចាត់ទុកថាជាកសិករក្រ បានស្តាយកាំភ្លើងពីរឆ្នាំ ឬក៏ជាយុទ្ធជនល្អ អាចនឹងគ្រប់គ្រាន់។

[១៣:៥៤:២៤]

បាទ ពេលខ្លះគេមិនត្រូវពិនិត្យគ្រប់ទាំង១០ នោះទេ ប៉ុន្តែគេពិនិត្យមើលទៅតាមលក្ខណៈពិសេសនីមួយៗ។ អ្នកខ្លះគឺគេមើលតែពីរបីលក្ខណៈវិនិច្ឆ័យ អ្នកខ្លះគេមើលទាំងអស់។ បាទ ហ្នឹងហើយគឺថាពិបាកណាស់ក្នុងការឆ្លើយសំណួររបស់លោក គឺថានេះជាសំណួរល្អ ប៉ុន្តែគឺថាយើងត្រូវសិក្សាលម្អិតលើកលែងតែយើងចូលរួមប្រជុំក្នុងការពិភាក្សាពីលក្ខណៈវិនិច្ឆ័យលម្អិតហ្នឹងទើបបានយើងដឹង។

**ស៖** អរគុណលោក ដេវីដ ឆេនដ៍ល័រ។ ខ្ញុំសូមឆ្លងទៅប្រធានបទតូចមួយទៀត គឺទាក់ទិនទៅនឹងមហាសន្និបាតរបស់បក្សកុម្មុយនីស្ត។ ខ្ញុំសូមឲ្យលោកមើលឯកសារ ក្នុងមាត្រា៧ នៃលក្ខន្តិកៈនេះ។ មាត្រា៧ កថាខណ្ឌ១។ ខ្ញុំសូមអានលេខ ERN។ ERN ជាភាសាអង់គ្លេសលេខ 00184038, ERN ជាភាសាបារាំងលេខ 00292926 ដល់ 27 និងERN ជាភាសាខ្មែរលេខ 00442269។ នៅក្នុងមាត្រា៧នេះ គឺនិយាយអំពីខ្សែចាត់តាំងរបស់បក្សកុម្មុយនីស្ត។ ខ្ញុំសូមដកស្រង់នូវខ្លឹមសារមាត្រា៧នេះ ជូនអង្គសវនាការជ្រាបដូចតទៅ៖ "១) អង្គការរបស់បក្សកុម្មុយនីស្តមានសិទ្ធអំណាចធំជាងគេបំផុត សម្រាប់ទូទាំងប្រទេស គឺមហាសន្និបាតតំណាងទូទាំងប្រទេស។ ក្នុងរយៈពេលពីមហាសន្និបាតមួយទៅមួយទៀត មានអង្គការប្រតិបត្តិខ្ពស់ជាងគេបំផុត គឺសម្រាប់ទូទាំងប្រទេស គឺគណៈកម្មាធិការមជ្ឈិម"។

អ៊ីចឹង ខ្ញុំសូមឲ្យលោកអានមាត្រា៧នេះ ត្រង់ទំព័រ១៧ៗ ជាភាសាអង់គ្លេស។ បាទ ហើយខ្ញុំសូមសួរលោកបើសិនជាលោកអានហើយ។ ទំព័រ១៧ បាទទំព័រ១៧ បាទ។

**ឆ៖** បាទ ខ្ញុំបានអានបន្ទាត់នេះហើយ។

[១៣:៥៧:១២]

**ស៖** បាទ តើនៅក្នុងការអនុវត្តជាក់ស្តែង លោកបានស្រាវជ្រាវឃើញដែរឬទេ? តើសិទ្ធិអំណាចរបស់អង្គការដ៏ធំនេះ គឺមហាសន្និបាតតំណាងទូទាំងប្រទេសនេះ បានអនុវត្តដូចអ្វីដែលបាន

ចែងក្នុងមាត្រា៧នេះដែរឬទេ? ហើយអនុវត្តយ៉ាងដូចម្តេច? នេះបើផ្អែកតាមការសិក្សាស្រាវជ្រាវរបស់លោក។ សូមអញ្ជើញលោកបកស្រាយ សូមអញ្ជើញបាទ។

**ឆ៖** ខ្ញុំត្រូវតែរំឭកការចងចាំរបស់ខ្ញុំវិញ ថាតើវាមានមហាសន្និបាតទូទៅ ដើម្បីសម្រេចអ្វី គឺថាមិនប្រាកដថាមានទេ បើថាបើសិនជាមាន តើវាឆ្លុះបញ្ចាំងទៅសេចក្តីសម្រេចមកពីថ្នាក់មជ្ឈិមដែរឬទេ? អ៊ីចឹងគឺថាសេចក្តីសម្រេចរបស់ថ្នាក់មជ្ឈិមតែងតែយកមកប្រកាសផ្សាយ ហើយដើម្បីឲ្យសម្រេចដើម្បីអនុវត្ត ប៉ុន្តែវាអាចមាន។ ប៉ុន្តែខ្ញុំមិនច្បាស់ទេ ប្រសិនបើមានមែន វាមិនមែនជាកន្លែងដែលថាលើកបញ្ហាពិភាក្សាដោយចំហនោះទេ។ វាជាកន្លែងមហាសន្និបាតហ្នឹង ដើម្បីយកសេចក្តីសម្រេចមកពីថ្នាក់មជ្ឈិមយកមកប្រកាសវិញទេ។

[១៣:៥៨:៥២]

បាទ តាមពិតនិយាយតាមបច្ចេកទេស គឺយើងត្រូវដាក់នៅកថាខណ្ឌទី២ គឺយកមកដាក់ទី១វិញ គណៈអចិន្ត្រៃយ៍ជាអ្នកសម្រេចលើអ្វីៗ ទាក់ទង -- រួមទាំងមហាសន្និបាតផងដែរ។ អាហ្នឹងគួរតែដាក់អ៊ីចឹង បើក្នុងការអនុវត្ត។

**ស៖** បាទ អរគុណ។ ផ្អែកលើការស្រាវជ្រាវរបស់លោកបន្ថែម ថាតើ ខ្ញុំចង់ដឹងបន្ថែម ថាតើមហាសន្និបាតហ្នឹង ការអនុវត្តជាក់ស្តែងហ្នឹង គឺមានសិទ្ធិអំណាច និងមានការទទួលខុសត្រូវទៅលើកិច្ចការអ្វីខ្លះដែរទៅ? តើលោកធ្លាប់បានសិក្សាស្រាវជ្រាវឃើញអំពីសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់មហាសន្និបាតនៅក្នុងការអនុវត្តជាក់ស្តែង។ ហើយបើប្រៀបធៀបជាមួយនឹងការចែងក្នុងមាត្រាហ្នឹង តើវាមានការខុសគ្នាយ៉ាងដូចម្តេចខ្លះ?

[១៣:៥៩:៤៩]

**ឆ៖** ខ្ញុំមិនគិតថា ខ្ញុំមិនអាចឆ្លើយសំណួរលោកបានទេ។ គឺខ្ញុំមិនគិតថា ខ្ញុំមានការភ្ញាក់ផ្អើល ប្រសិនបើលោករកឃើញថា មហាសន្និបាតបានសម្រេច ហើយអនុវត្តធ្វើអ្វីមួយនោះ។ តាមពិតមហាសន្និបាត ខ្ញុំមិនប្រាកដថាមានទេ វាអាចថានៅក្នុងករណីកម្ពុជា គឺថាមហាសន្និបាតនោះ គឺថាសភាកម្ពុជាប្រជាធិបតេយ្យប្រជុំបីថ្ងៃ។ ខ្ញុំមិនដឹងថាច្បាស់ថា គេហៅថា មហាសន្និបាត ឬក៏ប្រជុំសភាទេអង្គាល់នោះ។ បាទ ប៉ុន្តែមហាសន្និបាត គឺថាគេប្រើពាក្យនៅកន្លែងផ្សេងទៀត ខ្ញុំមិនប្រាកដថាណាមួយទេ។

ខ្ញុំអាចពិនិត្យមើលកំណត់ហេតុរបស់ខ្ញុំឡើងវិញ ហើយខ្ញុំអាចឆ្លើយនៅថ្ងៃស្អែក លោកចាប់

អារម្មណ៍ នៅតែចង់បានចម្លើយនោះ បាទ។

[១៤:០០:៥៧]

**ស៖** បាទ អរគុណ ខ្ញុំសង្ឃឹមថាលោកនឹងឆ្លើយបន្ថែមនៅថ្ងៃស្អែក ប្រសិនបើលោកបានស្រាវជ្រាវឃើញនូវអ្វីដែលលោកបានសន្យាអម្បាញ់មិញនេះបាទ។ ជាបន្តទៅទៀត ខ្ញុំសូមសួរលោកថា តើមហាសន្និបាតដែលបានកំណត់នៅក្នុងមាត្រា៥ នេះ -- មាត្រា៧ នេះ បាទមាត្រា៧នេះ តើមានបានកោះហៅឲ្យមានការប្រជុំហ្នឹងប្រព្រឹត្តទៅយ៉ាងដូចម្ដេច? ហើយរបៀបវារៈនៃការប្រជុំហ្នឹងជាទូទៅ លោកបានស្រាវជ្រាវឃើញថា ផ្អែកទៅលើអ្វីដែលជាកម្មវត្ថុនៃកោះប្រជុំនៅក្នុងមហាសន្និបាតនោះ។

**ឆ៖** ខ្ញុំមិនអាចឆ្លើយចំណុចនេះក្នុងពេលនេះទេ ខ្ញុំអាចបញ្ជាក់បំភ្លឺនៅថ្ងៃស្អែកបាន។

**ស៖** សូមអរគុណ ខ្ញុំសង្ឃឹមនឹងបានទទួលចម្លើយពីលោកនៅថ្ងៃស្អែក។ ជាបន្តទៀត សូមសួរលោកថា តាមការសិក្សាស្រាវជ្រាវរបស់លោក មហាសន្និបាតដែលបានកោះប្រជុំហ្នឹង ជាទូទៅប្រព្រឹត្តយ៉ាងទៀងទាត់ ឬក៏មានរបៀបកំណត់យ៉ាងដូចម្ដេច? មានការកំណត់ទៀងទាត់ ឬក៏ការកោះប្រជុំហ្នឹងប្រព្រឹត្តទៅយ៉ាងដូចម្ដេចដែរ មហាសន្និបាតហ្នឹង? ហើយតាំងពីកើត បង្កើតលក្ខន្តិកៈនៃមហាសន្និបាតហ្នឹង បានប្រព្រឹត្តទៅប៉ុន្មានដង ហើយនៅពេលណាដែរបាទ?

[១៤:០២:៣១]

**ឆ៖** ខ្ញុំនឹងឆ្លើយចំណុចនេះ នៅពេលក្រោយ ហើយខ្ញុំៗមិនដែលឮថាមានការប្រជុំការមហាសន្និបាតច្រើនពីរបីនោះទេ ហើយសូម្បីតែមួយក៏ខ្ញុំមិនដែលឮនោះទេ។ ដូច្នេះហើយខ្ញុំនឹងជូនចម្លើយទៅលោកនៅថ្ងៃស្អែកចំពោះមហាសន្និបាតនេះ។

**ស៖** អរគុណច្រើនលោក ដេវីដ ឆេនដ័ល័រ ខ្ញុំសង្ឃឹមថានឹងបានទទួលបន្ថែមពីលោកនៅថ្ងៃស្អែកទាក់ទិននឹងមហាសន្និបាត នូវអ្វីដែលខ្ញុំបានសួរអម្បាញ់មិញ។ ជាបន្តនេះខ្ញុំសូមឆ្លងចូលប្រធានបទមួយទៀត គឺជាប្រធានបទដែលទាក់ទិនទៅនឹងគណៈកម្មាធិការមជ្ឈិម។ សូមលោកមេត្តាអានអត្ថបទមាត្រា៧ កថាខណ្ឌ១ៗ ហើយខ្ញុំសូមជូនលេខ ERN។ ERN ភាសាខ្មែរលេខ 00442269, ERN ជាភាសាអង់គ្លេស 00184038, ERN ជាភាសាបារាំង 00292926 ដល់ 27 បាទ។ នៅក្នុងអត្ថបទមាត្រា៧ ដដែលនេះ សូមលោកមេត្តាអាន ហើយខ្ញុំច្បិចយកនូវខ្លឹមសារសំខាន់។ ខ្ញុំសូមដកស្រង់នូវខ្លឹមសារនេះជូនអង្គសវនាការជ្រាបនៅពេលនេះ៖ “មាត្រា៧ ខ្សែចាត់តាំងរបស់បក្សកុម្មុយនីស្តមានដូចតទៅ៖ អង្គការរបស់បក្សកុម្មុយនីស្តមានសិទ្ធិអំណាចធំជាងគេបំផុត សម្រាប់ទូទាំងប្រទេស គឺមហាសន្និបាត

តំណាងទូទាំងប្រទេស។ ក្នុងរយៈពេលពីមហាសន្និបាតមួយទៅមួយទៀត មានអង្គការប្រតិបត្តិខ្ពស់ជាងគេបំផុតសម្រាប់ទូទាំងប្រទេស គឺគណៈកម្មាធិការមជ្ឈិម"។ តើលោកបានរកឃើញអត្ថបទហ្នឹងនៅ ហើយបានអាននៅបាទ?

[១៤:០៥:០០]

អ៊ីចឹងខ្ញុំសូមសួរលោកបន្តទៅទៀត។ បាទអរគុណ។ ផ្អែកតាមមាត្រា៧ នេះ និងផ្អែកតាមការសិក្សាស្រាវជ្រាវរបស់លោកជាក់ស្តែង តើលោកបានឃើញថា ធ្លាប់បានឃើញ ធ្លាប់បានជួបប្រទះអំពីតួនាទី និងការអនុវត្តសិទ្ធិអំណាចរបស់គណៈកម្មាធិការមជ្ឈិមនៅក្នុងសម័យកាលនោះ ប្រៀបធៀបជាមួយនឹងអត្ថបទ ដែលខ្ញុំបានដកស្រង់អម្បាញ់មិញនេះ តើមានលក្ខណៈដូចគ្នា ឬខុសគ្នាយ៉ាងដូចម្តេច?

**ឆ៖** ប្រសិនបើយើងមើលមហាសន្និបាតទូទៅ យើងដឹងហើយថា គណៈមជ្ឈិមគឺជាអ្នកធ្វើសេចក្តីសម្រេចថ្នាក់លើ។ នៅពេលប្រជុំគណៈអចិន្ត្រៃយ៍ យើងខ្ញុំមិនដឹងថា តើវាមានកំណត់ហេតុរៀងៗខ្លួន ឬក៏យ៉ាងណានោះទេ។ ហើយដូច្នេះហើយ យើងគិតថា គណៈមជ្ឈិមគឺវាមានអំណាចខ្ពស់ជាងគេបំផុតនៅក្នុងប្រទេស ឬក៏យ៉ាងណានោះទេ។ ក៏ប៉ុន្តែ តាមអ្វីដែលចែងគឺវាដូច្នោះមែន។ ដូច្នេះអ្វីដែលចែងគឺគេចង់ឲ្យដូច្នោះ។

[១៤:០៦:៣៧]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមបង្ហាញមាត្រាមួយទៀត គឺអត្ថបទមាត្រា២៣ នៅក្នុងលក្ខន្តិកៈដដែលនេះ។ ខ្ញុំសូមអានលេខERN។ ERN ជាភាសាខ្មែរលេខ 00442277, ERN ជាភាសាអង់គ្លេសលេខ 00184045, ERN ជាភាសាបារាំងលេខ 00292932។ បាទ សូមបង្ហាញអត្ថបទនេះលើអេក្រង់ ហើយសូមលោក ដេវីដ ឆេនដ័ល័រ មេត្តាអានអត្ថបទនេះ មាត្រា២៣ នេះបាទ។ ទំព័រលេខ ត្រង់ទំព័រ ៥២ បាទ ទំព័រ៥២។

**ឆ៖** បាទ ខ្ញុំកំពុងតែអាន។

**ស៖** ខ្ញុំសូម -- ឆ្លៀតពេលនេះ ខ្ញុំសូមអានដកស្រង់អត្ថបទមាត្រា២៣ នេះ ជូនអង្គសវនាការជ្រាបអំពីខ្លឹមសារជាភាសាខ្មែរ។ ខ្ញុំសូមដកស្រង់ដូចតទៅ៖

"មាត្រា២៣ ភារកិច្ចរបស់គណៈកម្មាធិការមជ្ឈិម។ ភារកិច្ចរបស់គណៈកម្មាធិការមជ្ឈិមគឺ ១) អនុវត្តមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្ត និងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្ត នៅក្នុងបក្សកុម្មុយនីស្តទាំងមូល។ ២) ណែនាំអង្គការភូមិភាគ តំបន់ ក្រុងទាំងអស់ និងអង្គការបក្សកុម្មុយនីស្តទទួលខុសត្រូវ

ផ្នែកផ្សេងៗទូទាំងប្រទេស ធ្វើសកម្មភាពតាមមាគ៌ានយោបាយ គោលជំហរសតិអារម្មណ៍ និងមាគ៌ាចាត់តាំងតាមភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ និងតាមទិសបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់បក្សកុម្មុយនីស្ត"។ បាទនេះគឺបញ្ចប់ការដកស្រង់ ដែលខ្ញុំបានដកស្រង់ចេញពីមាត្រា២៣ នៃលក្ខន្តិកៈរបស់បក្សកុម្មុយនីស្ត។ ប្រសិនបើលោក ដេវីដ ឆេនដ័ល័រ អានចប់ហើយ ខ្ញុំនឹងបន្តសំណួរនេះបាទ។

[១៤:០៩:១៤]

*យេស អូខេ*។ ខ្ញុំសូមសួរសំណួរទៅលោក។ នៅក្នុងចំណុចទាំងឡាយដែលខ្ញុំដកស្រង់អម្បាញ់មិញនេះ ជាពិសេសចំណុចទីមួយនិងទីពីរ ដែលមានគូស*ហៃឡៃ* ពណ៌នេះបាទ។ ថាតើការអនុវត្តជាក់ស្តែងតាមការស្រាវជ្រាវ សិក្សាស្រាវជ្រាវរបស់លោកកន្លងមក លោកឃើញថា ការអនុវត្តជាក់ស្តែងរបស់បក្សកុម្មុយនីស្តហ្នឹង មានលក្ខណៈដូចគ្នាទៅនឹងអ្វីដែលបានចែងនៅក្នុងមាត្រា២៣ នេះ ដែរឬទេ? បើខុស ខុសត្រង់កន្លែងណា? ហើយបើដូចគ្នា ដូចត្រង់កន្លែងណាបាទ?

**ឆ៖** ខ្ញុំគិតថា ខ្ញុំមិនអាចឆ្លើយតបលឿនទៅនឹងសំណួរហ្នឹងទេ វាជាសំណួរមួយល្អ ហើយខ្ញុំនឹងសិក្សាលម្អិត។ ខ្ញុំគិតថាវិធានក្រឹត្យក្រមទាំងអស់នោះគឺគេអនុវត្តតាម ក៏ប៉ុន្តែអង្គការអនុវត្តនោះគឺយើងឃើញមានចែងនៅក្នុងដីកាដំណោះស្រាយដូចដែលគេបានរៀបរាប់។ អង្គការទាំងឡាយគឺគេបានរៀបចំយ៉ាងល្អ ហើយមាត្រានេះគឺគេចែងដើម្បីធ្វើការ -- ប្រព័ន្ធធ្វើទំនាក់ទំនងទៅដល់បុគ្គលថ្នាក់ក្រោមទៀត។ ដូច្នេះពាក់ព័ន្ធទៅនឹងការអនុវត្ត ខ្ញុំមិនមានការយល់ដឹងលម្អិតទៅលើការងារប្រចាំថ្ងៃនៅក្នុងចំណោមកម្មាភិបាលខ្មែរក្រហមនៅក្នុងសម័យនោះទេ។ វាជាសំណួរមួយល្អ ក៏ប៉ុន្តែខ្ញុំមិនអាចឆ្លើយតបទៅនឹងសំណួរនេះនៅពេលនេះឡើយ។

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណ។ នៅពេលនេះ ការសង្កេតរបស់ខ្ញុំគឺវាពាក់ព័ន្ធទៅនឹងចម្លើយ។ សាក្សីបានឆ្លើយថាគាត់មិនមានជឿជាក់ -- គ្មានជំនឿជាក់ក្នុងការឆ្លើយទៅនឹងសំណួរនេះទេ ដូច្នេះប្រសិនអ៊ីចឹង បើសិនជាគាត់ថាមិនមានជំនឿជឿជាក់ឆ្លើយទៅនឹងសំណួរនេះទេ គឺគាត់ឈប់ត្រឹមហ្នឹងទៅមិនបាច់ធ្វើការសន្និដ្ឋានបន្ថែមទៀតទេ។ ហើយយើងក៏ចាំបាច់ដឹងអំពី -- ចង់ដឹងអំពីភាព -- ការប្រៀបធៀបគ្នារវាងចំណុចទាំងពីរនោះឡើយ។ ដើម្បីឲ្យយើងសន្សំពេលវេលារបស់យើងបាន។ ដូច្នេះហើយ ប្រសិនបើអ្នកជំនាញ គាត់ថាគាត់មិនដឹងហើយ គាត់មិនអាចឆ្លើយតបនោះបានទេ គឺឲ្យគាត់ចប់ត្រឹមហ្នឹងតែម្តង កុំឲ្យគាត់បន្តធ្វើ

ការទាយស្មាន ធ្វើការសន្មតទៅលើអ្វីដែលគាត់ឆ្លើយ។ សូមអរគុណលោកប្រធាន។

[១៤:១២:០២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការកត់សម្គាល់របស់លោកមេធាវី។ ហើយសូមរំឭកលោកអ្នកជំនាញថា ប្រសិនបើមានសំណួរឯណាលោកទំនងជាមិនបានដឹង មិនមានការស្រាវជ្រាវ ឬមិនមានការចងចាំទេ លោកអាចឆ្លើយតែប៉ុណ្ណឹងបានហើយ។ ហើយមិនបាច់ឆ្លើយតបនឹងសំណួរនោះទេ។ ហើយការសន្មាងណាខ្លះ ទំនងជាមិនអាចធ្វើទៅបានទេ ប្រសិនបើភាគីនីមួយដែលនឹងតាំងសំណួរដេញដោលចំពោះលោកហ្នឹងគ្មានពេល។ គាត់អាចអស់ពេលនៅពេលណាមួយក្នុងអំឡុងនៃដំណើរការសួរដេញដោលនេះ ពីព្រោះអង្គជំនុំជម្រះមិនបណ្តោយឲ្យគាត់ចំណាយពេលវេលាច្រើនទេ អញ្ជើញលោកអ្នកជំនាញមកធ្វើការសវនាការទំនងតែប្រាំថ្ងៃ ជាពេលវេលាអតិបរមា។ អ៊ីចឹងភាគីដែលពាក់ព័ន្ធគួរតែពិចារណានៅពេលវេលានេះ មិនមែនប្រាំថ្ងៃសម្រាប់តែភាគីខ្លួនឯងមួយទេ គឺភាគីដែលពាក់ព័ន្ធដទៃទៀតត្រូវលៃលកឲ្យមានភាពសមាមាត្រសមរម្យ ហើយគួរតែជ្រើសរើសយកសំណួរណាដែលមានប្រយោជន៍ដើម្បីឲ្យអង្គជំនុំជម្រះហ្នឹងមានមូលដ្ឋានក្នុងការត្រិះរិះពិចារណាស្វែងរកការពិតនៅក្នុងរឿងក្តីនេះដែលបានអ្នកជំនាញមកជួយបង្ហាញអំពីចំណេះដឹងរបស់គាត់ពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រកម្ពុជា ជាពិសេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ។

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

[១៤:១៣:៣៨]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ដូចដែលលោកជ្រាបស្រាប់ហើយ អង្គជំនុំជម្រះសាលាដំបូងឯកភាពជាមួយនឹងការជំទាស់របស់ភាគី។ លោក ឆេនដ័ល័រ ខ្ញុំគ្រាន់តែចង់ស្នើជូនដល់លោកថា ប្រសិនបើលោកមិនអាចមានលទ្ធភាពឆ្លើយទៅនឹងសំណួរណាមួយនោះ គឺលោកគួរតែបញ្ជាក់ថា ខ្ញុំមិនអាចឆ្លើយបានទេ។ លោកមិនអាចបន្តនិយាយពិភាក្សាលើកឡើងអំពីអ្វីដែលលោកមិនអាចឆ្លើយតបនោះឡើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា! សូមពិនិត្យលទ្ធភាពក្នុងការរៀបចំនូវសំណួរ។ សំណួរ

ដែលទំនងជាឥតប្រយោជន៍ ដែលលទ្ធភាពរបស់អ្នកជំនាញមិនអាចឆ្លើយតបបានទេ គួរតែចៀសវាង ឬក៏កែសម្រួលនូវសំណួរ ធ្វើយ៉ាងណាឲ្យរំលេចថា អ្នកជំនាញហ្នឹងគឺមានឱកាសមកឆ្លើយហ្នឹងគឺមានពេលវេលាតិចតួចណាស់។ អ៊ីចឹងឲ្យការចំណាយពេលវេលាការដេញដោលនេះមានប្រយោជន៍។

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមអរគុណលោកប្រធាន។

[១៤:១៤:៥៥]

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** ខ្ញុំសូមឆ្លងពីប្រធានបទអម្បាញ់មិញ ចូលទៅប្រធានបទមួយទៀត ដោយសារពេលវេលាមានកម្រិត។ ទាក់ទងនឹងបញ្ហាប្រធានបទថ្មីនេះ ខ្ញុំសូមសួរលោក ដេវីដ ឆេនដ័ល័រ ទាក់ទងនឹងគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលជាស្ថាប័នមួយសំខាន់ដែរ ដែលមិនបានលើកឡើងនៅក្នុងលក្ខន្តិកៈរបស់បក្ស។ អ៊ីចឹង ខ្ញុំសូមឲ្យលោក -- ទាក់ទងនឹងបញ្ហានេះ តើនៅក្នុងការសិក្សាស្រាវជ្រាវរបស់លោកកន្លងមកនេះ លោកធ្លាប់បានឃើញ សិក្សាអត្ថបទដែលមាននិយាយអំពីគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** ឯកសារដែលបាននិយាយនៅ -- លើកឡើងនៅក្នុងថ្ងៃនេះគឺ កំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ដែលវាជាភស្តុតាងមួយ។ ដូច្នេះហើយ វាជាភស្តុតាងបង្ហាញអំពីគណៈអចិន្ត្រៃយ៍ គណៈអចិន្ត្រៃយ៍គឺជាអង្គការមួយដែលគេបានស្គាល់យ៉ាងច្បាស់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។

[១៤:១៦:១៧]

**ស៖** អរគុណ។ តើគណៈកម្មការអចិន្ត្រៃយ៍នេះ បើផ្អែកតាមការសិក្សាស្រាវជ្រាវរបស់លោកគឺលោកបានឃើញថា ការអនុវត្តហ្នឹង គឺគណៈកម្មការហ្នឹង គឺមានសិទ្ធិអំណាចធ្វើអ្វីខ្លះដែរបាទ?

**ឆ៖** ចំណុចមួយចំនួនដែលបានលើកឡើង ខ្ញុំមិនប្រាកដទេថា មានអំណាចណាមួយគេប្រគល់ពីគណៈមជ្ឈិមទៅឲ្យគណៈអចិន្ត្រៃយ៍នោះ។ គណៈអចិន្ត្រៃយ៍យ៉ាងណាក៏ដោយ ជួបញឹកញយជាងគណៈមជ្ឈិម។ ហើយនៅក្នុងសមាជិករបស់គណៈអចិន្ត្រៃយ៍នោះ ក៏ជាសមាជិករបស់គណៈអចិន្ត្រៃយ៍ដែរ ដែលសមាជិកនេះជាន់គ្នា។

**ស៖** អរគុណ ខ្ញុំសូមសួរបន្តទៀត។ តើតាមការសិក្សាស្រាវជ្រាវរបស់លោកហ្នឹង លោកបានសិក្សា ឬកត់សម្គាល់ឃើញអំពីអត្ថបទណាដែលមាននិយាយអំពីបញ្ហាជាគន្លឹះ ដែលគណៈកម្មការអចិន្ត្រៃយ៍នេះទទួលខុសត្រូវដោយឡែក។ តើលោកបានធ្លាប់ឃើញអត្ថបទណាដែលមាននិយាយអំពីបញ្ហានេះទេបាទ? ហើយការទទួលខុសត្រូវដោយឡែកហ្នឹង គឺទទួលខុសត្រូវទៅលើអ្វីខ្លះ?

[១៤:១៨:០១]

**ឆ៖** គឺចំណុចនេះ ត្រូវតែខ្ញុំធ្វើការសិក្សាជាថ្មបង។

**ស៖** សូមអរគុណលោក ដេវីដ ឆេនដ៍ល័រ។ មួយចំណុចទៀត ដែលខ្ញុំចង់ដឹងដែរថា ផ្អែកលើការសិក្សាស្រាវជ្រាវរបស់លោក តើលោកមានឃើញអង្គការណា ឬក៏ថ្នាក់ណាជាអ្នកសម្រេចគោលនយោបាយដែលទាក់ទិនទៅនឹងសន្តិសុខក្នុងនិងក្រៅប្រទេស គោលនយោបាយទាក់ទងនឹងកិច្ចការបរទេស កិច្ចការក្នុងវិស័យហិរញ្ញវត្ថុ កិច្ចការវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សុខាភិបាល សង្គមកិច្ច ឃោសនាការ និងការអប់រំកែប្រែ ជាដើម។ល។ ដែរឬទេ?

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធានសូមអធ្យាស្រ័យ។ នៅចំណុចនេះខ្ញុំសូមជំទាស់ទៅលើបញ្ហាបច្ចេកទេស។ សំណួរនោះ គឺហាក់ដូចជាសន្មតថា គណៈកម្មាធិការនោះមានអត្ថិភាព ហើយសួរទៅកាន់សាក្សី។ សំណួរនេះគួរតែរៀបចំឃ្លោងឃ្លាឡើងវិញ។ សំណួរដែលបានលើកឡើងសួរអំមិញនោះ គឺសន្មតថា គណៈកម្មាធិការនោះ គេរៀបចំបង្កើតឡើងដើម្បីគោលបំណង ដូចដែលបានចោទសួរ។ ដូច្នេះ ហើយ ខ្ញុំសូមស្នើឱ្យសហព្រះរាជអាជ្ញា សួរសំណួរដែលមានលក្ខណៈទូទៅ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាជាតិ!

[១៤:១៩:៤៦]

**លោក ច័ន្ទ តារាស្មី៖**

បាទ ខ្ញុំសូមៗធ្វើការបកស្រាយជូនលោកមេធាវី កាណាវាស។ អ្វីដែលខ្ញុំលើកឡើងនេះ គឺមិនមែនមានគំនិតសន្មតទុកជាមុន សំដៅទៅលើគណៈកម្មការអចិន្ត្រៃយ៍នោះទេ។ ប្រហែលជាមានមកពីការបកប្រែ ឬក៏លោកស្ដាប់មិនច្បាស់ក៏មិនដឹង។ គំនិតដែលខ្ញុំចង់និយាយសំណួរខ្ញុំ គឺចង់និយាយថា តើតាមការសិក្សាស្រាវជ្រាវរបស់លោក លោកបានធ្លាប់ឃើញអត្ថបទ ឬក៏ថ្នាក់ណា ឬក៏មានអត្ថបទណា

ដែលបញ្ជាក់ ដែលសរសេរបញ្ជាក់ថា គោលនយោបាយនេះ! ការធ្វើសេចក្ដីសម្រេចទាក់ទងគោលនយោបាយទាំងឡាយដែលខ្ញុំបាននិយាយអម្បាញ់មិញនេះ! ថ្នាក់ណាជាអ្នកសម្រេច? ខ្ញុំចង់ដឹងថា ថ្នាក់ណាជាអ្នកសម្រេច? ព្រោះសំណួរនេះមានប្រយោជន៍ ដែលខ្ញុំសួរ និងសហការីខ្ញុំសួរនៅពេលបន្តិចទៀតនេះបាទ។

អ៊ីចឹងគំនិងខ្ញុំគឺមិនមែនជាការសន្និតទៅលើគណៈអចិន្ត្រៃយ៍ ដូចដែលលោកបានមានប្រសាសន៍នោះទេ។ អ៊ីចឹង ខ្ញុំសូមបកស្រាយប៉ុណ្ណេះ ជាខុសពីឆន្ទៈពិតដែលខ្ញុំចង់និយាយជម្រាបជូនអង្គសវនាការនៅពេលនេះ។

[១៤:២០:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២៣:២២]

**ប្រធានអង្គជំនុំ៖**

សំណួរអម្បាញ់មិញនេះគឺលោកអ្នកជំនាញមិនបាច់ឆ្លើយតបទេ ដោយសារមូលហេតុសំណួរហ្នឹងមិនច្បាស់លាស់ទេ ហើយមានការបកស្រាយក៏មិនមានមូលដ្ឋានអីឲ្យបានជាក់ច្បាស់ដែរ ហើយអង្គជំនុំជម្រះសូមជម្រាបថា លោកតំណាងសហព្រះរាជអាជ្ញាជាតិអាចបន្តទៅសំណួរផ្សេងទៀត ហើយនិងជម្រាបផងដែរ រំឭកឡើងវិញថាពេលវេលាពិភាក្សាដេញដោលសាក្សីអ្នកជំនាញ ប្រវត្តិវិទូរូបនេះគឺមានពេលវេលាខ្លីទេ ក្នុងការមកបង្ហាញនូវការសម្ថភាពជំនាញរបស់ខ្លួនពីប្រវត្តិកម្ពុជាប្រជាធិបតេយ្យពាក់ព័ន្ធនឹងរឿងក្ដី ហើយសូមឲ្យលោកតំណាងសហព្រះរាជអាជ្ញា និងភាគីពាក់ព័ន្ធចូលរួមនៅកិច្ចដំណើរការនីតិវិធីប្រើប្រាស់ពេលវេលាដែលមានក្នុងរយៈពេលប្រាំថ្ងៃនេះឲ្យមានប្រសិទ្ធភាព បានន័យថាភាគីនីមួយៗមិនមានពេលវេលាច្រើនប៉ុន្មានទេ។ គប្បីប្រើប្រាស់ពេលវេលាដែលមានឲ្យមានប្រសិទ្ធភាព។

សូមបន្តទៅសំណួរថ្មីទៀត ប្រសិនបើមាន!

[១៤:២៤:៤០]

**លោក ច័ន្ទ តាភារស្មី៖**

អរគុណលោកប្រធាន។

**សួរដោយលោក ច័ន្ទ តាភារស្មី៖**

**ស៖** ខ្ញុំសូមបន្តទៅប្រធានបទផ្សេងមួយទៀត។ តើ -- ប្រធានបទ ដែលខ្ញុំចង់ជម្រាបជូននេះ គឺ

ទាក់ទងនឹងបញ្ហាមន្ទីរ៨៧០ និងការិយាល័យនយោបាយ៨៧០។ តើតាមការសិក្សាស្រាវជ្រាវរបស់លោក លោកអាចនៅចងចាំបានទេ អំពីការិយាល័យ ឬក៏ -- ការិយាល័យ៨៧០ និងមន្ទីរ៨៧០។ តើលោកចងចាំ អាចបញ្ជាក់ជូនអង្គសវនាការនៅពេលនេះបានទេបាទ?

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** បាទ ឈ្មោះនេះ គឺបាន គេបានប្រើប្រាស់ណាស់ ច្រើនណាស់ នៅក្នុងឯកសារមួយចំនួន។

**ស៖** អរគុណ។ តើលោកអាចបញ្ជាក់បានទេ អំពីតួនាទី សិទ្ធិអំណាចនៃមន្ទីរ៨៧០ហ្នឹង តើគេបង្កើតឡើងក្នុងគោលបំណងអ្វីខ្លះ? ហើយមានសិទ្ធិអំណាចអ្វីខ្លះបាទ?

**ឆ៖** ខ្ញុំមិនអាចឆ្លើយឲ្យបានច្បាស់លាស់នោះទេ។ ឯកសារដែលនិយាយអំពីតួនាទីរបស់មន្ទីរនេះ គឺវាជាន់គ្នាទៅនឹងតួនាទីរបស់គណៈមជ្ឈិម តួនាទីរបស់គណៈអចិន្ត្រៃយ៍ និងតួនាទីរបស់ ប៉ុល ពត, នួន ជា...។ល។ ដូច្នេះហើយ វាហាក់ដូចជាតួនាទីនុំងវាមានលក្ខណៈជាន់គ្នា។ វាជាតួនាទីរបស់ខាងគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា។ តួនាទីរបស់មន្ទីរនេះ មិនមានចែងច្បាស់លាស់នៅក្នុងលក្ខន្តិកៈបក្សនោះទេ។ ដូច្នេះ ហើយតួនាទីនេះ គឺចែងស្រពេចស្រពិលណាស់។

[១៤:២៦:៥៤]

**ស៖** អរគុណ។ តើមន្ទីរ៨៧០នេះ បង្កើតឡើងពីពេលណាដែរ លោកចាំទេបាទ? លោកអាចបញ្ជូនបានទេបាទ?

**ឆ៖** ខ្ញុំគិតថា មន្ទីរ៨៧០នេះ គឺលេខកូដគេដាក់ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ហើយខ្ញុំត្រូវតែមើលទៅលើឯកសារស្រាវជ្រាវរបស់ខ្ញុំបន្ថែមទៀត ហើយខ្ញុំជឿថា មន្ទីរនេះ គឺសម្រាប់បុគ្គលប៉ុល ពត និងអ្នកដែលធ្វើការនៅក្នុងមន្ទីរនោះ ហើយមន្ទីរនេះ ប្រាកដជាបង្កើតមុនឆ្នាំ១៩៧៥។

**ស៖** អរគុណ។ តើលោកអាចបញ្ជាក់បានទេថា ក្រៅពី ប៉ុល ពត តើលោកអាចបញ្ជាក់ថាមានកម្មាភិបាលខ្មែរក្រហមណាខ្លះទៀត ដែលជាសមាជិកនៅក្នុងមន្ទីរ៨៧០ នេះ?

**ឆ៖** វាមិនពាក់ព័ន្ធទៅនឹងសមាជិកភាពនោះទេ។ វាពាក់ព័ន្ធទៅនឹងការធ្វើទំនាក់ទំនង ថាតើគេទំនាក់ទំនងតាមរបៀបណា? ពីណាទៅណា? មន្ទីរ៨៧០ គឺគេមានដាក់នៅលើក្បាលសំបុត្រ ហើយគេមានចែងនៅលើមន្ទីរនេះ លេខកូដមន្ទីរនោះ។ ពុំមានភស្តុតាងណាមួយចែងថា សមាជិករបស់មន្ទីរមជ្ឈិមនេះ នៅក្រៅគណៈសមាជិកគណៈកម្មាធិការមជ្ឈិម ឬអចិន្ត្រៃយ៍ ហើយគេទាញពីខាងក្រៅមកធ្វើការងារនៅក្នុងនោះទេ។ គឺគេគ្រាន់តែកត់លេខកូដ បង្កើតលេខកូដ ដើម្បីកំណត់មន្ទីរនេះ សម្រាប់ធ្វើ

ការងារទំនាក់ទំនងតែប៉ុណ្ណោះ។

[១៤:២៨:៤៤]

**ស៖** បាទ សូមអរគុណ។ តើលោកអាចបញ្ជាក់បានទេ ថាជនជាប់ចោទ នួន ជា, អៀង សារី, ខៀវ សំផន តើគាត់មានវត្តមាននៅទីនោះ ឬក៏មានសិទ្ធិអំណាចតួនាទី ភារកិច្ចអ្វីខ្លះនៅក្នុងមន្ទីរ៨៧០ ហ្នឹងដែរឬទេ? តើលោកបានសិក្សាស្រាវជ្រាវឃើញអត្ថបទណាដែលបាននិយាយរឿងហ្នឹងបាទ?

**ឆ៖** ខ្ញុំអត់មានកត់សម្គាល់ឃើញទេ។

**ស៖** ខ្ញុំ -- លោក ដេវីដ ឆេនដ៍ល័រ ដោយសារតែពេលវេលាមានកម្រិត ខ្ញុំសូមអនុញ្ញាតសួរលោកប្រហែលជាប្រាំសំណួរទៀតបាទ។

**លោក ច័ន្ទ តារាស្មី៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតសួរលោក ដេវីដ ឆេនដ៍ល័រ ប្រាំសំណួរទៀត ហើយបញ្ចប់ពីនេះគឺខ្ញុំទុកជូនសហការីរបស់ខ្ញុំ ដើម្បីសួរបន្ត។

[១៤:២៩:៣៩]

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** សំណួរទីមួយ គឺចង់សួរថា បើតាមការសិក្សាស្រាវជ្រាវរបស់លោក គឺលោកមានបានធ្លាប់ឮឈ្មោះ ឌឿន ទេបាទ?

**លោក អាកឡូវ វ៉ែកគែន៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក!

**លោក អាកឡូវ វ៉ែកគែន៖**

ខ្ញុំសូមអន្តរាគមន៍ ព្រោះថាជាភាសាបារាំងយើងអត់ទទួលបានការបកប្រែទេ លោកប្រធាន ជាពិសេសគឺចម្លើយរបស់លោក ដេវីដ ឆេនដ៍ល័រ អម្បាញ់មិញនេះ គឺចម្លើយចុងក្រោយរបស់គាត់។ ហើយគឺជាចម្លើយទៅនឹងសំណួររបស់ចុងក្រោយរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធទៅនឹងតួនាទី -- ទំនួលខុសត្រូវរបស់ជនជាប់ចោទក្នុងមន្ទីរ៨៧០។ យើងអត់ទទួលបានការបកប្រែទេ សូមលោកប្រធានចាត់ចែង។

**ប្រធានអង្គជំនុំ៖**

បាទ សូមលោកអ្នកជំនាញឆ្លើយតបទៅនឹងសំណួរចុងក្រោយអម្បាញ់មិញនេះ លោកបានឆ្លើយរួចហើយ គ្រាន់តែឆ្លើយបញ្ជាក់ម្តងទៀតទៅនឹងសំណួររបស់លោកតំណាងសហព្រះរាជអាជ្ញាជាតិដែលបានសួរលោក។ លោកអាចឆ្លើយបានទេ លោក ដេវីដ ឆេនដ៍ល័រ? អំមិញនេះ គឺលោកមានសំណួរមួយហើយសួរទៅហើយមានការប៉ុនប៉ងក្នុងការស្នើសុំជំទាស់ផង ប៉ុន្តែដល់លោកឆ្លើយភ្លាមទៅថាមិនដឹងទេបញ្ហានេះក៏ចប់ទៅ។ ប្រសិនបើមិនដូច្នោះទេ គឺអាចឲ្យលោកមេធាវី -- អំ! លោកតំណាងសហព្រះរាជអាជ្ញាតាំងសំណួរជាថ្មីចំពោះលោកម្តងទៀត។

[១៤:៣១:៣៦]

**លោក ដេវីដ ឆេនដ៍ល័រ៖**

ខ្ញុំចាំចម្លើយ ប៉ុន្តែសូមឲ្យសហព្រះរាជអាជ្ញាសួរឡើងវិញ ដើម្បីឲ្យខ្ញុំប្រាកដ។ ជាចម្លើយខ្លីទេដែលខ្ញុំបានឆ្លើយបាទ។ សូមសហព្រះរាជអាជ្ញាសួរឡើងវិញ ខ្ញុំនឹងឆ្លើយម្តងទៀតបាទ។

**លោក ច័ន្ទ តារាស្មី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** ដើម្បីជាការបញ្ជាក់ច្បាស់ជូនភាគីមេធាវីការពារក្តី ខ្ញុំសូមសួរសំណួរដែលខ្ញុំសួរចុងក្រោយអំមិញនេះជូនចំពោះអង្គសវនាការជ្រាបជាថ្មីម្តងទៀត។ គឺខ្ញុំសួថា សំណួរនេះបានសួរថា តើក្រៅពី ប៉ុលពតដែលគាត់បានឆ្លើយអំមិញថា មានតួនាទីសំខាន់នៅក្នុងមន្ទីរ៨៧០ហ្នឹង។ សូមសួរថាតើមានវត្តមានរបស់ជនជាប់ចោទ នួន ជា, អៀង សារី, ខៀវ សំផន នៅក្នុងមន្ទីរ៨៧០ នេះដែរឬទេ? បើសិនជាមានតើគាត់មានតួនាទី ភារកិច្ច សិទ្ធិអំណាច សម្រេចកិច្ចការអ្វីខ្លះនៅក្នុងមន្ទីរ៨៧០ នោះ? ហ្នឹងបើសិនជាគាត់អាចឆ្លើយបញ្ជាក់បាន ហើយគាត់ឆ្លើយថា អត់។

[១៤:៣២:៤៨]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ចម្លើយរបស់ខ្ញុំគឺថាទេ។ ខ្ញុំសូមបញ្ជាក់ថា នេះមិនមែនជាមន្ទីរដែលមានឧបករណ៍សម្ភារៈនោះទេ គឺគ្រាន់តែជាអាសយដ្ឋានជ្រើសរើសដើម្បីកន្លែងឆ្លើយឆ្លងតែប៉ុណ្ណោះ។ ចម្លើយទៅនឹងសំណួររបស់លោក គឺ ទេ។ ខ្ញុំអត់ដឹងទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តសូមលោកតាំងសំណួរបន្តជាថ្មី ដែលលោកបានសួរអំមិញ ហើយមិនទាន់បាន អ្នកជំនាញមិនទាន់បានឆ្លើយទេ។ សូមតាំងសំណួរនោះឡើងវិញសាជាថ្មីម្តងទៀត សំណួរចុងក្រោយបង្អស់។

**លោក ច័ន្ទ តាវារស្មី៖**

អរគុណលោកប្រធាន។ ដូចខ្ញុំបានសន្យាអំមិញថា ខ្ញុំបាទមានសំណួរប្រាំចុងក្រោយ ដើម្បីសួរសំណួរមុនបញ្ចប់ចំណែកដែលខ្ញុំត្រូវជម្រាបជូនអង្គសវនាការនាពេលនេះ។

[១៤:៣៣:៣៣]

**សួរដោយលោក ច័ន្ទ តាវារស្មី៖**

**ស៖** សំណួរទីមួយ គឺខ្ញុំសូមសួរទៅលោក ដេវីដ ឆេនដ៍ល័រ ថាតើលោកបានសិក្សាស្រាវជ្រាវឃើញដែរឬទេ អំពីមូលហេតុអ្វីបានជាមានការចាប់ខ្លួនកម្មាភិបាលឈ្មោះ សឿ វ៉ាស៊ី ហៅ ឌឿន នៅដើមឆ្នាំ១៩៧៧? បាទ ឯកសារនេះគឺខ្ញុំយោងទៅលើឯកសារ IS4.6 ដែលមានចំណងជើងថា "សំឡេងពីមន្ទីរស-២១"។ សូមជូន ERN ជាភាសាអង់គ្លេសលេខ 00192742, ERN ជាភាសាខ្មែរ 00191900, ERN ជាភាសាបារាំង 00357331។

បាទ សូម -- ឯកសារនេះ គឺជាឯកសារដែលមានសារៈសំខាន់ ហើយខ្ញុំសូមអនុញ្ញាតពីលោកប្រធាន បើសិនជាលោកប្រធានអនុញ្ញាតខ្ញុំសូមជូនឯកសារនេះ ជូនលោក ដេវីដ ឆេនដ៍ល័រ ដើម្បីពិនិត្យ។ ដើម្បីជាជំនួយស្មារតីដល់ការរំឭកដល់ការចងចាំរបស់គាត់បាទ។

[១៤:៣៤:៤៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាជាតិជូនទៅសាក្សីពិនិត្យ ជូនទៅអ្នកជំនាញពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនអ្នកជំនាញ)*

[១៤:៣៦:០៣]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** បាទ ខ្ញុំបានអានហើយ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** តើតាមការសិក្សាស្រាវជ្រាវរបស់លោក លោកមានបានរកឃើញអំពីមូលហេតុនៃការចាប់ខ្លួនកម្មាភិបាលឈ្មោះ សៀ វ៉ាស៊ី ហៅ ឌឿន នៅដើមឆ្នាំ១៩៧៧ហ្នឹងដែរឬទេ? សូមលោកបញ្ជាក់អំពីមូលហេតុនៃការចាប់ខ្លួននេះ? ហើយមានការពាក់ព័ន្ធយ៉ាងម៉េចខ្លះ?

**ឆ៖** ខ្ញុំមិនបាន មិនអាចសន្និដ្ឋានថាហេតុអីបានជាកើតរឿងហ្នឹងទេ ប៉ុន្តែនៅទំព័រ៦៣, ៦៤ ក្នុងសៀវភៅរបស់ខ្ញុំ ខ្ញុំបាននិយាយអំពីអ្នកទោសដែលបាន -- ត្រូវបានគេនាំចូលស-២១ គឺជាមនុស្សថ្នាក់ខ្ពស់ម្នាក់។ ហើយអង្គហេតុហ្នឹងបានបញ្ជាក់បន្ថែមដែលថា ខៀវ សំផន ជំនួសគាត់ ហើយមានការចាប់ខ្លួន។ ខ្ញុំមិនសន្និដ្ឋានទេ ខ្ញុំសរសេរថា "គាត់មានជាប់ខ្សែជាមួយ កុយ ធួន ហើយកុយ ធួន គឺជាមនុស្ស -- កម្មាភិបាលថ្នាក់ខ្ពស់ដែលមានខ្សែបណ្តាញដែលថាមានអ្នកក្រោមបង្គាប់។ ហើយ ឌឿន បាទ ឌឿន នៅក្នុងខ្សែរបស់ កុយ ធួន។ នេះហើយជាមូលហេតុនៃការចាប់ខ្លួនរបស់ សៀ វ៉ាស៊ី ហៅ ឌឿន ហ្នឹង។ តាមខ្ញុំគិត។

[១៤:៣៧:៣៨]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូម -- នៅពេលដែលគាត់និយាយថា ខ្ញុំគិតនៅក្នុងចុងចម្លើយ តើលោកអ្នកជំនាញហ្នឹង គឺថាធ្វើការសន្និដ្ឋានទេ គាត់មិនអាចឆ្លើយសំណួរបានទេ បើគាត់ដាក់នៅឃ្លាក្រោយថា គាត់គិតអ៊ីចឹងនោះ។

**លោក ដេវីដ ឆេនដ៍ល័រ៖**

ខ្ញុំដឹងថា ម្នាក់ៗនៅទីនេះបានដឹងហើយ គឺថានៅស-២១ ខ្ញុំមិនគិតថាវានឹងកើតទេ ប៉ុន្តែព្យាយាមចង់ឲ្យដឹងថា ការពិតនេះយ៉ាងដូចម្តេច។ នេះហើយជាអ្វីដែលខ្ញុំអាចបញ្ជាក់បាន។ ខ្ញុំមិនបញ្ជាក់ថាវាពិតជាអ៊ីចឹងនោះ។ ប៉ុន្តែឯកសារវាបង្ហាញ ដែលអាចធ្វើឲ្យយើងជឿ ឲ្យយើងអាចសន្និដ្ឋានពីឯកសារហ្នឹងបាន។ អ្វីដែលខ្ញុំគិត ខ្ញុំដែលយើងអាចធ្វើបាន គឺខ្ញុំគិតថាកើតឡើង បើផ្អែកលើតាមឯកសារហ្នឹង។

[១៤:៣៨:៣៤]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ចំណុចរបស់ខ្ញុំ ខ្ញុំមិនទិតៀនលោកអ្នកជំនាញថា មិនអាចធ្វើបែបនោះបានទេ។ ក៏ប៉ុន្តែអ្វីដែលគេសួរសំណួរជាក់លាក់អំពីបុគ្គលណាម្នាក់ គាត់អាចដឹង ឬមិនដឹង។ បើគាត់ដឹង ដឹងដោយរបៀបណា? តើដឹងកម្រិតណា? គឺពឹងផ្អែកលើចម្លើយសារភាព ឬក៏ភស្តុតាង ឬក៏ឯកសារផ្សេងណា

ទៀត។ តើអ្វី? បើសិនជាគាត់មិនដឹង បើគាត់សន្និដ្ឋាន គាត់សន្មត គាត់ឆ្លើយថា ខ្ញុំមិនដឹងទេ គាត់ឆ្លើយតែប៉ុណ្ណឹងបានហើយ។ មិនចាំបាច់ថា ខ្ញុំគិត ឬក៏ខ្ញុំសន្និដ្ឋាន គឺថាមិនអាចឆ្លើយបន្ថែមដែលថាជាការសន្និដ្ឋានអ្វីក្រៅពីការមិនដឹងនោះទេ។

[១៤:៣៩:២១]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤០:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីចៅក្រម ដើម្បីឆ្លើយតបទៅនឹងមតិជំទាស់តវ៉ារបស់មេធាវីអន្តរជាតិការពារក្តីលោក អៀង សារី គឺលោក ម៉ៃខល កាណាវាស ដែលបានលើកឡើងអម្បាញ់មិញនេះ។ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ការជំទាស់គឺត្រូវបានទទួលយកជាគោលការណ៍ ក៏ប៉ុន្តែប្រសិនបើអ្នកជំនាញរូបនេះឆ្លើយសំណួរណាមួយ ហើយគាត់បញ្ជាក់ច្បាស់ថា ចម្លើយរបស់គាត់គឺផ្អែកទៅលើការស្រាវជ្រាវ ដែលគាត់បានធ្វើនោះ ពេលនោះ នោះមិនមែនជាការសន្និដ្ឋានទេ។ មិនមែនជាការឆ្លើយគ្មានមូលដ្ឋាន ប៉ុន្តែសំណួរដែលអ្នកជំនាញដែលគាត់ចង់ដឹងឲ្យច្បាស់នោះគឺថា បញ្ហាទាក់ទងទៅនឹងការប្រើថាការស្រាវជ្រាវ គឺខ្លឹមសារនៃចម្លើយសារភាព ដែលអ្នកជំនាញបានដឹងហើយថា មិនគេទទួលស្គាល់ថាយកមកជាភស្តុតាងនៅក្នុងតុលាការទេ ចំពោះចម្លើយសារភាពនោះ។

[១៤:៤២:១៤]

ប្រសិនបើលោកនិយាយអំពីចម្លើយសារភាព ហើយនិងចម្លើយ -- និងការសិក្សាពីចម្លើយសារភាពនោះ លោកត្រូវបញ្ជាក់ថា បែបនោះ។ ថាតើខ្លឹមសារនោះត្រឹមណា ដើម្បីឲ្យតុលាការទទួលស្គាល់យក? តើច្បាស់ទេ លោកសាស្ត្រាចារ្យ ឆេនដ៍ល័រ?

**លោក ដេវីដ ឆេនដ៍ល័រ៖**

ខ្ញុំជ្រាបហើយ។ គឺថា ប្រអប់មួយនៅទំព័រ៤ និង៥ គឺមិនៗមានព័ត៌មានណាដែលដកស្រង់ពី

ចម្លើយសារភាពទេ គឺថាគឺអង្គហេតុដែលទាក់ទងទៅអ្នកជាប់ខ្សែត្រូវបានគេចោទ ហើយការប្តូរតួនាទីឡើង ពីការិយាល័យមួយ ទៅការិយាល័យមួយ គឺថាមានតែអង្គហេតុ គឺថាការសន្និដ្ឋានរបស់ខ្ញុំគឺថា គេចាប់ខ្លួនគាត់ គឺដោយសារគាត់ជាប់ខ្សែជាមួយ កុយ ធួន។ អ្វីដែលគាត់ឆ្លើយនៅក្នុងចម្លើយសារភាពរបស់គាត់ គឺថាឆ្លើយហ្នឹងគឺមិនច្បាស់លាស់ទេ ថាគាត់មិនសារភាពថាធ្វើអ្វីនោះទេ។ ចម្លើយសារភាពរបស់គាត់គឺថា បញ្ហាមួយចំនួននោះគឺថា គឺគ្មានតម្លៃទេ គឺជាការឆ្លើយឲ្យតែរួចខ្លួនទេនៅកាលនោះបើតាមខ្ញុំមើលទៅ។ ខ្ញុំមិនផ្អែកទៅលើខ្លឹមសារចម្លើយសារភាព យកមកឆ្លើយនៅពេលនេះនោះទេ។

[១៤:៤៣:៤០]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

មតិចុងក្រោយសម្រាប់ជូនលោក សាស្ត្រាចារ្យ ឆេនដ័ល័រ ចំណុចសំខាន់នោះសូមឲ្យលោកជម្រាបតុលាការថា លោកប្រើចម្លើយសារភាព ដោយហេតុថា នៅក្នុងកាលៈទេសៈមួយចំនួន ដូចជាព័ត៌មានដែលដកចេញមកពីចំណារនៅលើចម្លើយសារភាពនោះ គឺជាព័ត៌មាននោះគឺថាអាចទទួលយកថាជាភស្តុតាង ប៉ុន្តែខ្លឹមសារចម្លើយសារភាព គឺតុលាការមិនយកធ្វើជាបង្អែកទេ។ រីឯខ្លឹមសាររបស់ចម្លើយសារភាពនោះ ប៉ុន្តែសូមលោកបញ្ជាក់បែបនោះ ដើម្បីឲ្យតុលាការជ្រាប។

លោកកាណាវាស តើយើងបានគ្របដណ្តប់លើបញ្ហាអ្វីទាំងអស់?

**លោក ម៉ៃខល កាណាវាស៖**

គឺពិតហើយលោកស្រីចៅក្រម។ ខ្ញុំបាទយល់។

[១៤:៤៤:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។

ឥឡូវនេះដល់ពេលសមល្មមសម្រាកអង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការ ផ្តល់កន្លែងសម្រាកសមរម្យដល់អ្នកជំនាញ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបានកំណត់អម្បាញ់មិញនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១៤:៤៥ នាទី ដល់ម៉ោង ១៥:១២ នាទី)*

[១៥:១១:៤៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមានតែពីរសំណួរទៀតទេ នៅមុននឹងបញ្ចប់ការសួររបស់ខ្ញុំចំពោះលោក ដេវីដ ឆេនដ៍ល័រ នៅពេលនេះ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក ដេវីដ ឆេនដ៍ល័រ សូមលោកមេត្តាជួយបញ្ជាក់ឲ្យបានច្បាស់បន្តិចទៀតទាក់ទងទៅនឹងលោក សឿ វ៉ាស៊ី ហៅ ឌឿន។ ខ្ញុំចង់ដឹងថា តើក្រោយពី ឌឿន ត្រូវបានចាប់ខ្លួន តើនរណាគេមកជំនួស ឌឿន នៅកន្លែងការងារនោះបាទ?

[១៥:១២:៥១]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខៀវ សំផន។

**ស៖** អរគុណលោក ដេវីដ ឆេនដ៍ល័រ។ តើលោកដឹងថា លោក ខៀវ សំផន មកសជំនួស ឌឿន ក្រោយពេល ឌឿន ត្រូវបានចាប់ខ្លួននេះ តើលោកដឹងព័ត៌មាននេះមកពីណាដែរបាទ? លោកបានទទួលព័ត៌មាននេះមកពីប្រភពណាខ្លះបាទ?

**ប្រធានអង្គជំនុំ៖**

ម្តងៗទៀតមានបញ្ហាបកប្រែ សូមលោកអ្នកជំនាញ ឥឡូវមានការបកប្រែភាសា ភាសាបារាំងអត់មានឮ មានការបកប្រែទេ។ ចម្លើយអម្បាញ់មិញគឺដូចគ្នា។ អ៊ីចឹងសូមសួរសំណួរឡើងវិញក្រោយ

ពេលប្រព័ន្ធសំឡេងបកប្រែភាសាបានដំណើរការល្អឡើងវិញ។

ម៉េចទៅបើកបានទេ?

បាទ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាសាឡើងវិញ សំណួរចុងក្រោយអម្បាញ់មិញនេះ ពីព្រោះអត់មានការបកប្រែនូវចម្លើយដូចមុនដែរ។ អ៊ីចឹងគឺទាល់តែសួរឡើងវិញដើម្បីឲ្យជាក់ច្បាស់ហើយនិងចម្លើយសាជាថ្មីឡើងវិញដែរ។

[១៥:១៤:១៤]

**លោក ច័ន្ទ តាវារស្មី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានពីរសំណួរចុងក្រោយ។

**សួរដោយលោក ច័ន្ទ តាវារស្មី៖**

**ស៖** បាទ សំណួរទីមួយរបស់ខ្ញុំគឺផ្អែកលើឯកសារដដែល គឺឯកសារសំឡេងពីមន្ទីរស-២១ នេះ ខ្ញុំសូមសួរលោក ដេវីដ ឆេនដ៍ល័រ ថាទាក់ទិននឹងឈ្មោះ សឿ វ៉ាស៊ីៗ ហៅ ឌឿន ក្រោយពីឈ្មោះ សឿ វ៉ាស៊ី ហៅ ឌឿន ត្រូវបានចាប់ខ្លួន តើនរណាគេមកជំនួសឈ្មោះ ឌឿន នេះបាទ?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** គឺ ខៀវ សំផន។

[១៥:១៤:៥៦]

**ស៖** អរគុណលោក ដេវីដ ឆេនដ៍ល័រ។ សំណួរទីពីរចុងក្រោយរបស់ខ្ញុំ ជាសំណួរចុងក្រោយគឺសូមសួរថា លោកបានឆ្លើយថា លោកបានឆ្លើយថា ខៀវ សំផន មកជំនួសឈ្មោះ ឌឿន តើលោកបានព័ត៌មាននេះ មកពីប្រភពណាដែលលោកប៊ានអះអាងថា ខៀវ សំផន មកជំនួស ឌឿន នេះបាទ?

**ឆ៖** ខ្ញុំមិនអាចនិយាយនៅពេលនេះនោះទេ ខ្ញុំត្រូវមើលលេខយោងជើងទំព័រ៦៧ នៅក្នុងអត្ថបទនោះ ហើយអាចត្រឡប់មកប្រាប់លោកនៅថ្ងៃស្អែកវិញ។ ហើយខ្ញុំគិតថា វាមាននៅក្នុងចម្លើយសារភាពហើយខ្ញុំផ្អែកទៅលើឯកសារ ដែលខ្ញុំបានស្រាវជ្រាវមិនមែនទៅលើចម្លើយសារភាពទេ គឺលេខយោង៦៧។ ខ្ញុំគិតថា លេខយោង៦៧ នៅក្នុងសៀវភៅស្តីអំពី “សំឡេងពីស-២១” នោះគឺលោកមើលខាងចុងទំព័រខាងក្រោមទៅ គឺលេខយោង៦៧នោះ គឺគេបង្ហាញអំពីប្រភពនៃមូលដ្ឋានពាក់ព័ន្ធទៅនឹងចំណុចនេះ។

[១៥:១៦:០៩]

**ស៖** អរគុណលោក ដេវីដ ឆេនដ៍ល័រ។

**លោក ច័ន្ទ តារាស្មី៖**

អរគុណលោកប្រធាន។ ខ្ញុំសូមថ្លែងអំណរគុណ ចំពោះលោកសាស្ត្រាចារ្យ ដេវីដ ឆេនដ័ល័រ ដែលបានចំណាយពេលដ៏មានតម្លៃ ចូលរួមនៅក្នុងកម្មវិធីសវនាការផ្តល់សក្ខីកម្មនៅពេលនេះ។ ហើយខ្ញុំសូមអរគុណ ហើយសូមបញ្ចប់ការសួររបស់ខ្ញុំ ហើយខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីទុកឱកាសជូនសហការីរបស់ខ្ញុំ គឺលោក ថារីក គាត់នឹងបន្តសំណួរបន្ថែមទៅលើអ្វីដែលជាសំណួរ ដែលគាត់ចង់សួរ បាទ។

សូមអរគុណលោកប្រធាន។ សូមអរគុណលោក ដេវីដ ឆេនដ័ល័រ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៥:១៧:០៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សួស្តីលោក ដេវីដ ឆេនដ័ល័រ។ ខ្ញុំរួមជាមួយនឹងលោកចៅក្រម និងសហសេវិករបស់ខ្ញុំ សូមអរគុណលោក ដែលលោកមកជួយផ្តល់ការពិត ទៅដល់អង្គជំនុំជម្រះ។

[១៥:១៧:២៧]

បន្តទៅនឹងសំណួរដែលសហសេវិករបស់ខ្ញុំបានសួរហើយ ខ្ញុំសូមចូលទៅដល់ប្រធានបទមួយទៀត។ ខ្ញុំចង់បង្ហាញជូនលោក នូវអត្ថបទមួយចំនួន ចេញពីសៀវភៅរបស់លោក គឺ “សំឡេងពីមន្ទីរស-២១”។ ខណៈពេលដែលខ្ញុំអានលេខ ERN ពាក់ព័ន្ធនោះ គឺសហសេវិករបស់ខ្ញុំនោះគឺអាចយកឯកសារនេះទៅជូនលោកបាន ប្រសិនបើលោកអត់មាន។ ឯកសារ ERN ជាភាសាអង់គ្លេសគឺ 00192684 គឺឯកសារនេះ វាគួរតែស្ថិតនៅក្នុងសំណុំឯកសារដែលលោកបានទទួលបានអម្បាញ់មិញ។ លេខ ERN ជាភាសាអង់គ្លេស គឺ 684, ខ្មែរ ERN គឺ 00191833។ ខ្ញុំនឹងអានអត្ថបទមួយចេញពីក្នុងនោះ បន្ទាប់ខ្ញុំនឹងសួរសំណួរមួយចំនួនតូច។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រម យើងខ្ញុំសូមអនុញ្ញាតបញ្ចាំងអត្ថបទចេញពីសៀវភៅ “សំឡេងពីមន្ទីរ

ស-២១" នេះដាក់នៅលើអេក្រង់។ សៀវភៅនេះត្រូវបានយកមកដេញដោល នៅចំពោះមុខអង្គជំនុំជម្រះហើយ។ ឯកសារនេះគឺមានលេខ IS4.6។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

[១៥:១៩:០៨]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

អត្ថបទដកស្រង់នេះ ខ្លីតែប៉ុណ្ណោះ គ្មានឯកសារណាមួយភ្ជាប់ទំនាក់ទំនង ប៉ុល ពត ឬក៏ អៀង សារី ពាក់ព័ន្ធទៅនឹងការបញ្ចាលុប -- បោសសម្អាតប្រជាជននៅស-២១ នោះទេ។ ទោះបីជា ខ្សែអំណាចភ្ជាប់ជាមួយនឹងស-២១ នៅក្នុងមជ្ឈិមបក្ស ត្រូវបានគេបង្ហាញហួសពីវិមតិសង្ស័យក៏ដោយ។ យើងខ្ញុំនឹងចូលសួរពាក់ព័ន្ធនឹងមន្ទីរស-២១ ឡើងវិញ។ លោក ឲ្យលោកចាំចំណុចអត្ថបទនេះសិនបន្ទាប់មក ខ្ញុំនឹងចូលទៅលើអត្ថបទមួយទៀត ឯកសារដដែល ERN ជាភាសាអង់គ្លេស 00192694, បារាំង 00354278, ខ្មែរគឺ 00191846។ ត្រង់អត្ថបទនេះ គឺលោកបាននិយាយអំពីការបញ្ជូនរបាយ-ការណ៍ពី ស-២១ ទៅអ្នកដែលជាថ្នាក់លើ។

[១៥:២០:២១]

អត្ថបទនេះសរសេរថា "បុគ្គលពីរនាក់ដែលនៅសន្តិបាល គឺបានធ្វើរបាយការណ៍ទៅថ្នាក់លើដែលយើងហៅថាអង្គការលើ ឬក៏បងខាងលើ ទៅខាងក្រៅ ហើយនិងមជ្ឈិមបក្ស ឬក៏ក្បាលម៉ាស៊ីនទៅសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជា។ មជ្ឈិមគឺជាអង្គការមួយនៅក្នុងប្រទេស។ នៅក្នុងសមាជិកភាពនេះ គឺយើងឃើញមានសមាជិកថ្នាក់លើដែលស្ថិតនៅក្នុងចំណោមការងារប្រតិបត្តិការ ស-២១ ក្នុងនោះមាន ប៉ុល ពត, នួន ជា, តាម៉ុក, សុន សេន, និង ខៀវ សំផន ដែលអ្នកទាំងអស់នេះជាសមាជិកនៅក្នុងរបបនេះទាំងមូល ជាពិសេសរហូតមកដល់ទសវត្សរ៍ឆ្នាំ១៩៨០"។

**ស៖** លោកសាស្ត្រាចារ្យអត្ថបទទាំងពីរអម្បាញ់មិញនេះ គឺពាក់ព័ន្ធទៅនឹងក្រុមបុគ្គលមួយចំនួនដែលលោកហៅថាជាក្រុមមជ្ឈិមបក្ស។ ជាបឋម ខ្ញុំសូមឲ្យលោកធ្វើការពន្យល់បន្ថែមទៅលើមជ្ឈិមបក្សនេះមានន័យយ៉ាងម៉េច? ហើយថាតើមជ្ឈិមបក្សនេះមានលក្ខណៈខុសគ្នាទៅនឹងពាក្យដែលលោក

ប្រើនៅក្នុងថ្ងៃនេះថាក្បាលម៉ាស៊ីននោះ យ៉ាងម៉េចដែរ?

[១៥:២១:៤៨]

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** ខ្ញុំគិតថាមជ្ឈិមបក្សគឺសំដៅទៅលើគណៈមជ្ឈិម ដែលយើងហៅថាគណៈកម្មាធិការមជ្ឈិម។ ក្បាលម៉ាស៊ីនមិនមែនឈ្មោះដែលគេប្រើប្រាស់ជាផ្លូវការនោះទេ វាជាយន្តការមួយតែប៉ុណ្ណោះ។ ខ្ញុំចង់ធ្វើការកែប្រែបន្តិចបន្តួចទៅនឹងអត្ថបទដែលដកស្រង់អម្បាញ់មិញនេះ ជាពិសេសនៅក្នុងការជំនុំជម្រះករណី ឌុច ដែលគឺ ឌុច នេះគាត់ធ្វើទំនាក់ទំនងជាមួយនឹង សុន សេន។ ដូច្នេះហើយទំនាក់ទំនងជាមួយនឹងបុគ្គលផ្សេងដែលនៅក្នុងមជ្ឈិមបក្សនោះ គឺមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់នោះឡើយ។ ឌុច គឺគាត់ដឹងថា សុន សេន និង នួន ជា គឺស្ថិតនៅក្នុងមជ្ឈិមបក្ស ហើយគាត់រាយការណ៍ទៅអ្នកទាំងពីរនោះ។ ដូច្នេះហើយ គឺគាត់ឃើញតែមនុស្សមួយ ឬក៏ពីរនេះតែប៉ុណ្ណោះ។ នៅពេលដែលខ្ញុំនិយាយនៅក្នុងអត្ថបទផ្សេង ទំនាក់ទំនងជាមួយនឹងមជ្ឈិមបក្សជាមួយនឹង ស-២១ គឺមិនបានបង្ហាញជូនការជំនុំជម្រះនៅក្នុងឆ្នាំ១៩៧៩ នោះទេ ក៏ប៉ុន្តែយ៉ាងណាក៏ដោយទំនាក់ទំនងនេះត្រូវបានបង្កើតឡើង។ អង្គជំនុំជម្រះនៅក្នុងឆ្នាំ១៩៧៩ គឺភ្ជាប់ទំនាក់ទំនងតែជាមួយនឹង ប៉ុល ពត ទៅនឹង អៀង សារី តែប៉ុណ្ណោះ។

[១៥:២៣:១៣]

**លោក ម៉ៃខល កាណាវាស៖**

ប្រសិនបើខ្ញុំសូមអនុញ្ញាតលើកនូវយោបល់របស់ខ្ញុំ លោកប្រធាន។ យើងទំនងជាមានបញ្ហានៅត្រង់នេះ។ លោកអ្នកជំនាញ ខ្ញុំមិនមែនរិះគន់ទៅលើគាត់ទេ គាត់ផ្ដល់សក្ខីកម្មផ្អែកទៅលើភស្តុតាងដែលផ្ដល់ជូនដោយ ឌុច នៅក្នុងការជំនុំជម្រះរបស់ ឌុច។ នេះជាបញ្ហាមួយ។ បញ្ហាមួយទៀត ដែលខ្ញុំមើលឃើញមុននេះ គឺខ្ញុំបានចង្អុលបញ្ជាក់ផងដែរ ហើយនៅពេលនេះ ខ្ញុំសូមបញ្ជាក់តែម្ដង។ អ្នកជំនាញបានលើកឡើងជាច្រើនដងនៅថ្ងៃនេះ គឺគាត់បានថា គាត់ហ្នឹងមើលទៅលើដីកាដំណោះស្រាយ ហើយវាហាក់ដូចជាគាត់នេះ ទាញសេចក្ដីសន្និដ្ឋាន លើកសេចក្ដីថ្លែងការណ៍របស់គាត់ ផ្អែកទៅលើអ្វីដែលគាត់អាននៅក្នុងដីកាដំណោះស្រាយ គឺផ្ទុយទៅនឹងអ្វីដែលគាត់ស្រាវជ្រាវ និងសិក្សាក្នុងពេលដែលគាត់វិភាគប្រវត្តិសាស្ត្រដែលមាននៅក្នុងឯកសារ។

ផ្អែកទៅលើចំណុចនេះ គឺខ្ញុំមានចំណុចដែលត្រូវលើកឡើង ប្រហែលជាអង្គជំនុំជម្រះ គឺមិនអាច

បញ្ចោក់ទៅលើចំណុចនេះ ហើយដកព័ត៌មាននេះចេញពីអ្វីដែលគាត់ដឹងនោះទេ។ អង្គជំនុំជម្រះគួរតែបង្គាប់ទៅដល់អ្នកជំនាញថាតើនៅពេលណាដែលគាត់ផ្អែកចម្លើយរបស់គាត់ទៅលើឯកសារដែលគាត់ ដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ ដើម្បីឲ្យអង្គជំនុំជម្រះនោះផ្តល់ទម្ងន់ទៅលើសក្ខីកម្មដែលគាត់បានឆ្លើយ។ ខ្ញុំគិតថា អ្វីដែលខ្ញុំលើកឡើងនេះ គឺលើកឡើងបានច្បាស់លាស់ហើយ ជូនអង្គជំនុំជម្រះ។ សូមអរគុណ។

[១៥:២៥:០០]

**លោក អាប់ឌុលឡាក់ ថារីក៖**

ប្រសិនបើអនុញ្ញាតឲ្យខ្ញុំឆ្លើយតប លោកប្រធាន។ សូមអរគុណលោកប្រធាន។ បញ្ហាដែលមេធាវីការពាក្តីលើកឡើង គឺនឹងលើកឡើងជាពីរ។ ទីមួយ នឹងការសួរឆ្លង សួរដេញដោលទៅលើអ្នកជំនាញ។ ទីពីរ គឺនៅពេលដែលយើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ក្នុងពេលជំនុំជម្រះនេះ។ បញ្ហាដែលលើកឡើងរបស់អ្នកជំនាញ គឺជាយោបល់ជំនាញរបស់គាត់ ហើយគឺយើងធ្វើការចង់ដឹងទៅលើប្រភព និងយថាភាពនៃឯកសារ។ ការយោងរបស់លោក ដេវីដ ឆេនដ៍ល័រ ទៅលើការដឹកាដំណោះស្រាយក្នុងសំណុំរឿង០០១។ វាគឺជាការងារធ្វើការរបស់គាត់។ គាត់មានការប្រុងប្រយ័ត្ន ទៅលើអ្វីដែលគាត់ផ្អែកលើមូលដ្ឋាន លើការស្រាវជ្រាវរបស់គាត់។ ការជំនុំជម្រះនៅទីនេះ មិនមានក្រុមប្រឹក្សាវិនិច្ឆ័យនោះទេ។ ហើយអង្គជំនុំជម្រះនឹងធ្វើការផ្តល់ទម្ងន់ជាក់លាក់ទៅលើសក្ខីកម្ម និងភស្តុតាង ថាតើភស្តុតាងណាមួយដែលផ្អែកទៅលើដីកាដំណោះស្រាយ។ យោបល់របស់អ្នកជំនាញ គឺវាពាក់ព័ន្ធទៅនឹងតម្លៃនៃភស្តុតាងដែលអង្គជំនុំជម្រះនឹងផ្តល់នាពេលក្រោយ។ នៅពេលដែលយើងសួរដេញដោលឆ្លងទៅកាន់សាក្សីផ្សេង។

ដូច្នេះហើយ មិនមានមូលដ្ឋានណាមួយសមរម្យ ដូចដែលមេធាវីការពារក្តីបានលើកឡើងនោះឡើយ។

[១៥:២៦:៣២]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមធ្វើការកត់សម្គាល់មួយ ពាក់ព័ន្ធទៅនឹងការជំទាស់របស់មេធាវីការពារក្តី ពីព្រោះថា វាអាចមានឥទ្ធិពលទៅលើសំណួរទាំងអស់របស់ភាគី។ ខ្ញុំគិតថា ខ្ញុំចង់ស្នើថា សុំឲ្យអ្នកជំនាញ

បញ្ជាក់ឲ្យបានច្បាស់ នៅពេលដែលគាត់ឆ្លើយទៅនឹងសំណួរ ថាតើអ្វីដែលគាត់ឆ្លើយនេះ កើតចេញពីអ្វីដែលគាត់កត់សម្គាល់ឃើញនៅសម័យនោះ ឬក៏គាត់យកចេញមកពីអ្វីដែលគាត់បានអានក្នុងឯកសារ? ខ្ញុំគិតថា សូមឲ្យគាត់ឆ្លើយបញ្ជាក់ឲ្យបានច្បាស់ ដើម្បីបំភ្លឺនូវចំណុចដែលគាត់ឆ្លើយ។ ហើយនិងអ្វីដែលគាត់យោងនោះ សូមគាត់បញ្ជាក់ផង ថាគាត់ដឹងថានៅពេលដែលគាត់សរសេរឯកសារឬក៏ដឹងនៅពេលក្រោយ។ ដូច្នេះ យើងឃើញថា មានការជំទាស់ពីខាងមេធាវីការពារក្តី ហើយមានការអន្តរាគមន៍ពីខាងសហព្រះរាជអាជ្ញា ដើម្បីកុំឲ្យមានបញ្ហាបែបនេះកើតឡើង។ សូមលោកប្រធាន។

[១៥:២៧:៣៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣១:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមផ្តល់ -- ប្រគល់ភារៈជូនទៅលោកស្រីចៅក្រមដើម្បីឆ្លើយតបទៅនឹងការលើកឡើងរបស់ភាគីពាក់ព័ន្ធនឹងបញ្ហាប្រឈមចំពោះមុខនៅពេលនេះ ដើម្បីដោះស្រាយបញ្ហានេះឲ្យបានជ្រះស្រឡះ និងក្នុងបំណងបង្កើនល្បឿននៃកិច្ចពិភាក្សារបស់យើងឲ្យបានលឿន និងឆាប់រហ័ស។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

អង្គជំនុំជម្រះបានពិចារណាឃើញថា អ្នកជំនាញមានសិទ្ធិក្នុងការអានដីកាដំណោះស្រាយ ដែលជាឯកសារសាធារណៈ និងពិនិត្យនូវសេចក្តីសន្និដ្ឋានដែលគាត់បានរកឃើញនៅក្នុងការស្រាវជ្រាវរបស់គាត់នៅក្នុងឆ្នាំមុនៗកន្លងមក។ ហើយជម្រាបតុលាការនៅពេលដែលទស្សនៈទាំងនោះ ដែលផ្អែកទៅលើការសិក្សារបស់គាត់ តម្រូវឲ្យមានការកែតម្រូវក្រោយពីការអានដីកាដំណោះស្រាយ។ ដូច្នេះ យើងមិនទទួលយកការជំទាស់នោះទេ ប៉ុន្តែសូមឲ្យអ្នកជំនាញ ដែលថាគាត់បានធ្វើភារកិច្ចរបស់គាត់កន្លងមកក្នុងការពន្យល់។

[១៥:៣៣:១៩]

ខ្ញុំកែតម្រូវមតិរបស់ខ្ញុំ ទាក់ទង -- ក្រោយពីការអានឯកសារ ឬក៏ដីកាដំណោះស្រាយ ឬក៏ការវិភាគផ្សេងៗ។ អង្គជំនុំជម្រះយល់ឃើញច្បាស់ថា ការស្រាវជ្រាវរបស់សាស្ត្រាចារ្យ ឆេនដ័រ ជាង

មួយទសវត្សរ៍មកហើយនោះ គាត់មានសិទ្ធិក្នុងឋានៈជាអ្នកជំនាញក្នុងប្រធានបទនេះ ក្នុងការបន្តធ្វើការពិនិត្យឡើងវិញនូវការសន្និដ្ឋានរបស់គាត់ ផ្អែកទៅលើអ្វីដែលបានធ្វើពីមុន ហើយអង្គជំនុំជម្រះក៏ចង់ដឹងថាតើដើម្បីវាយតម្លៃទៅលើភស្តុតាង ទម្ងន់ត្រឹមណាដែលថា ជាចម្លើយពិតប្រាកដរបស់គាត់នោះ។ ជាពិសេសកាលណាព័ត៌មានវាមានការខ្វែង ឬក៏ខុសគ្នាចំណុចណាមួយ។

ដូច្នេះ ដោយសេចក្តីសង្ខេបគឺថា ការជំទាស់គ្មានប្រសិទ្ធភាពទេ។

[១៥:៣៤:២៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន លោកស្រីចៅក្រម។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ឥឡូវនេះ យើងត្រឡប់ទៅរកអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ទាក់ទងទៅនឹងបញ្ហាដែលយើងបាន -- ទាក់ទងនឹងចំណុចនោះគឺថា ទស្សនៈរបស់លោកបានកែប្រែក្នុងកម្រិតខ្លះ ទាក់ទងទៅនឹងការនិយាយអំពីសៀវភៅ "សំឡេងពីស-២១"។ សំណួរបឋមមួយទាក់ទងទៅនឹងដែលថា មិនមានអ្វីគួរឲ្យសង្ស័យទេនៅបច្ចុប្បន្ននេះ គឺផ្អែកទៅលើការស្រាវជ្រាវរបស់លោក ហើយនិងបទពិសោធន៍របស់លោក តើលោកចាត់ទុកថា គណៈមជ្ឈិមបក្សអាចនឹងដាក់បញ្ចូលទាំងជនជាប់ចោទទាំងអស់នេះ ឬក៏លោកមិនចាត់ទុកទេ នៅពេលដែលខ្ញុំនិយាយថា ជនជាប់ចោទ គឺមាន នួន ជា, អៀង សារី, ខៀវ សំផន?

[១៥:៣៥:១៤]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** គឺបាទ។ ហើយអាចមានអ្នកផ្សេងទៀតផងដែរ។ តាមពិតគឺថា យើងដឹងច្បាស់ថាអ៊ីចឹង។

**ស៖** តើលោកអាចប្រាប់តុលាការបានទេ ថាតើទស្សនៈរបស់លោក ប្រហែលជាតាមន័យទូលាយគឺ -- ខ្ញុំចង់ឲ្យលោកប្រុងប្រយ័ត្នអំពីការប្រើពាក្យថា តើទំនាក់ទំនងរវាងស-២១ ហើយនិងមជ្ឈិមបក្សនោះ តើមានការកែប្រែអ្វីឬទេ ឬក៏ដូចដែលលោកថែងនៅក្នុងសៀវភៅរបស់លោកនោះដដែលទេ?

**ឆ៖** រហូតទាល់តែមានអ្វីផ្សេងពីហ្នឹង។ ខ្ញុំមិនមានការកែប្រែទេ នេះជាទំនាក់ទាក់ទងផ្ទាល់ជាមួយ សុន សេន ហើយ សុន សេន នៅក្នុងគណៈអចិន្ត្រៃយ៍ គណៈមជ្ឈិម ហើយទាក់ទងនឹងស-២១

ជាចំណុចសំខាន់ដែលថា សុន សេន ជាមនុស្សសំខាន់ ហើយតាមពិតនោះគឺ ឯកសារមួយចំនួនក៏បានបាត់បង់។ អ៊ីចឹងគឺគណៈមជ្ឈិមទទួលបានព័ត៌មានអ្វីៗពីស-២១។ ខ្ញុំមិនចង់ឲ្យតុលាការច្រឡំ ឬក៏សាធារណជនច្រឡំអំពីសៀវភៅរបស់ខ្ញុំទាក់ទងទៅនឹងការជំនុំជម្រះ ឌុច ទេ គឺថាឯកសារមួយចំនួនគឺថាអាចធ្វើឲ្យគេពិនិត្យនៅស-២១។ ប៉ុន្តែមិនមែនជាការព្រួយបារម្ភចម្បងរបស់មជ្ឈិមបក្សទេ។

[១៥:៣៧:០២]

ការព្រួយបារម្ភនោះគឺថា ចម្លើយនោះគឺបានឆ្លើយតប ប៉ុន្តែគឺថាមតិយោបល់និយាយអំពីកសិកម្មវៀតណាម ខ្មាំងផ្ទៃក្នុង ដែលគេនិយាយនោះ។ ប៉ុន្តែជាមូលដ្ឋាន ស-២១ គឺជាអ្វីៗដែលគេយកចិត្តទុកដាក់មួយក្នុងចំណោមបញ្ហាផ្សេងៗ ប៉ុន្តែគេមានឯកសាររាប់ពាន់ទំព័រ ដែលថាយើងអាចនឹងឆ្លុះបញ្ចាំងអំពីសកម្មភាពទូទៅនៅក្នុងរបបនោះ។

**ស៖** សំណួរមួយទៀត ទាក់ទងទៅនឹងដែលលោកនិយាយរចនាសម្ព័ន្ធរបៀបជាពីរ៉ាមីត គឺមេដឹកនាំសមូហភាពនៅកំពូល។ ហើយយើងមើល យើងត្រឡប់ទៅរកទំនាក់ទំនងបែបពីរ៉ាមីតនេះ តើលោកអាចបញ្ជាក់មតិយោបល់ជាអ្នកជំនាញ ថាតើលោកចាត់ទុកស-២១ ត្រង់កន្លែងណា? នៅចំណុចណាក្នុងបក្សកុម្មុយនីស្តកម្ពុជា ឬក៏លោកចាត់ទុកថា ស-២១ នេះជាស្ថាប័នក្នុងកម្រិតណាមួយនៅពេលនោះ?

**ឆ៖** មិនមែនជាផ្នែករបស់មជ្ឈិមបក្សទេ វាគ្រាន់តែជាស្ថាប័នមួយក្នុងចំណោមស្ថាប័នទាំងឡាយដែលត្រូវរាយការណ៍ទៅសមាជិកម្នាក់ក្នុងមជ្ឈិមបក្ស ទៅតាមការងាររបស់គេ។ ឌុច មិនបានចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈមជ្ឈិមនោះទេ ឬគណៈអចិន្ត្រៃយ៍នោះទេ។ គាត់បានដឹងជាបុគ្គលនោះ គឺថាអ្នកម្នាក់ជាសមាជិកនៅក្នុងនោះ។

[១៥:៣៨:៤១]

**ស៖** អ្វីដែលខ្ញុំចង់បាននោះ គឺថា ថាតើលោកចាត់ទុកថា វាមានទំនាក់ទំនងរវាងមេដឹកនាំ ថ្នាក់លើ និងថ្នាក់ក្រោមនោះដែរឬទេរវាង ឌុច និងថ្នាក់មជ្ឈិមនោះ?

**ឆ៖** នេះហើយជាវិធីដែលគេធ្វើការ។ ឌុច គាត់បានធ្វើការរបៀបហ្នឹង គាត់ជាថ្នាក់ក្រោម ហើយគាត់ដើរតួនាទីរបស់គាត់ដោយប្រុងប្រយ័ត្នចំពោះថ្នាក់លើ ហើយដោយយកចិត្តទុកដាក់ផង។

**ស៖** សូមអរគុណ។ សំណួរមួយចុងក្រោយទាក់ទងនឹងបរិបទនេះ គឺទាក់ទងទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាជាតិនោះ លោកបាននិយាយថា "ខៀវ សំផន បានទៅជំនួស ឌឿន។ ហើយ

លោកនឹងផ្តល់ *ហ្វូតណូត* ជាលេខយោងទៅលោក នៅថ្ងៃស្អែក"។ តើលោកនៅចាំទេ ថាតើតួនាទីរបស់ ខៀវ សំផន មកជំនួស ឌឿន ហ្នឹងជាតួនាទីអ្វីដែរ?

**ឆ៖** ប្រធានមន្ទីរ៨៧០ គឺជាភារកិច្ច គាត់និយាយថា គាត់មិនបានធ្វើអ្វីជាសំខាន់ទេនៅក្នុងការងារនេះទេ។ នេះជាភស្តុតាងផ្ទុយផ្សេងមួយទៀតពីគាត់។ ប៉ុន្តែនៅក្នុងឯកសារសាធារណៈ គឺថាការប្តូរ -- ការតែងតាំងបានប្តូរពី ឌឿន ទៅគាត់។ អ៊ីចឹងគឺគាត់មានការងារហ្នឹង។ មិនមែនជាការសម្ងាត់ ប៉ុន្តែអ្វីដែលគាត់បានធ្វើ គេបញ្ជាឲ្យគាត់ធ្វើអ្វី តើការងារបានកែអ្វី ដែលពេលគាត់ទទួលយើងមិនបានដឹងនោះទេ យើងមិនអាចស្មានបានទេ។

**ស៖** ខ្ញុំមិនចង់សួរសំណួរមួយទៀតទេ ជាសំណួរចុងក្រោយ ប៉ុន្តែដើម្បីបំភ្លឺ មុននឹងយើងបញ្ចប់ប្រធានបទនេះ។ នៅពេលដែលលោកនិយាយថា ប្រធានមន្ទីរ៨៧០ ដែលលោកបានបញ្ជាក់ថាខាងដើមនៅក្នុង -- ដែលលោកថាជាលេខកូដរបស់មន្ទីរ បញ្ជាក់ពីការផ្ញើជូនទៅជាដើមហ្នឹង។ នៅពេលដែលលោកនិយាយថា ប្រធាននៃមន្ទីរ៨៧០នោះ ថាតើប្រធានហ្នឹងមានតួនាទីដូចម្តេចដែរ? ហើយខ្ញុំ -- ខ្ញុំសូមឲ្យលោកថាឡើងវិញ ឆ្លើយឡើងវិញ។

[១៥:៤១:០១]

**ឆ៖** អ្វីដែលខ្ញុំយល់កាន់តែច្បាស់នោះ ខ្ញុំទទួលស្គាល់ថាតាមដីកាដំណោះស្រាយនេះ មិនមែនអ្វីដែលខ្ញុំដឹងពីមុនតាមការស្រាវជ្រាវរបស់ខ្ញុំទេ។ គឺថានៅមន្ទី៨៧០ ជាឈ្មោះកូដរបស់ ប៉ុល ពត ទេ ប៉ុន្តែមន្ទីរ៨៧០នេះ គឺចាត់ចែងកិច្ចការក្រុងសស្នាមចេញ និងចូលទៅមជ្ឈិមបក្ស នេះគឺជាការិយាល័យដែលមានការងារលើក្រដាសស្នាម។ វាអាចមានការភ័ន្តច្រឡំ គឺថាប្រធានមន្ទីរនោះគឺថា ឌឿន ឬ ខៀវ សំផន នោះ ប៉ុន្តែប្រធានមន្ទីរ៨៧០នោះគឺ ប៉ុល ពត។ ប៉ុន្តែចំពោះមេដឹកនាំសមូហភាពវិញ គឺថាវាអាចនឹងត្រួតគ្នារវាងបុគ្គល ហើយនិងមន្ទីរហ្នឹង។

**ស៖** សូមអរគុណបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

[១៥:៤២:០៦]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនជំទាស់ទេ ប៉ុន្តែយើងតាមដានអ្វីដែលបានពិភាក្សាពីខាងដើម

ដែលថាអ្នកជំនាញបានអានដីកាដំណោះស្រាយ។ ចៅក្រម ខាតវ៉ាយថ៍ បានបញ្ជាក់ហើយ បានសម្រេចរួចហើយ ហើយនេះជាការសំខាន់ដើម្បីបញ្ជាក់ថាតើ ហេតុអ្វីបានលោកសួរសំណួរនេះ ថាតើហេតុអ្វីបានលោកអានឯកសារនៅក្នុងដីកាដំណោះស្រាយ ហើយលេខយោង ហើយគាត់អានតែដីកាដំណោះស្រាយ ហើយផ្អែកទៅលើសេចក្ដីសន្និដ្ឋានដូចដែលសហចៅក្រមស៊ើបអង្កេតសន្និដ្ឋាន។ អ៊ីចឹងហើយនេះជាចំណុចពាក់ព័ន្ធ ពីព្រោះយើង -- អ្នកជំនាញដូចជាផ្អែកទៅលើសេចក្ដីសន្និដ្ឋានរបស់ដីកាដំណោះស្រាយ។ អ៊ីចឹងហើយសូមឲ្យសាក្សីហ្នឹងបំផ្លាញ(ស៊ើក) ថាតើគាត់ផ្អែកទៅលើឯកសារណាមួយដែលគាត់បានវិភាគ ហើយនិងគាត់បានសិក្សា។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្ដី លោក ខៀវ សំផន!

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្ថែមទៅលើអ្វីដែលខាងមេធាវី នួន ជា បាននិយាយ។ វាជាគួរ -- ជាការសំខាន់ណាស់ក្នុងការសួរទៅកាន់ អ្នកជំនាញនេះ គាត់និយាយអំពីដីកាដំណោះស្រាយណាមួយ ពីព្រោះអម្បាញ់មិញនេះ គឺ -- បានន័យថាគាត់បានដីកាដំណោះស្រាយ០០១។ ដូច្នេះ គាត់ធ្វើការយោងទៅលើដីកាដំណោះ -- នៅពេលនេះគឺគាត់យោងទៅលើដីកាដំណោះស្រាយ០០២។ ដូច្នេះសូមឲ្យគាត់ បញ្ជាក់ឲ្យបានច្បាស់ថាតើដីកាដំណោះស្រាយមួយណា។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៤:១០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ថា មេធាវីការពារក្ដីមានការព្រួយបារម្ភ ប៉ុន្តែដោយស្មោះត្រង់ គឺថា យើងសួរឲ្យសាក្សីឆ្លើយអ្វីដែលអាចធ្វើទៅបាន។ គឺថា ដីកាដំណោះស្រាយមានលេខយោងរាប់ពាន់ អ៊ីចឹងហើយអ្វីដែលគាត់បានដឹងក្នុងករណីច្រើន ប្រសិនបើឯកសារបានយោងទៅរកក្នុងលេខយោងហ្នឹង ក្នុងលេខយោងហ្នឹងគឺក៏ត្រូវទាក់ទងនឹងខ្លឹមសារសៀវភៅរបស់គាត់នេះដែរ។ អ៊ីចឹងហើយអង្គជំនុំជម្រះបានណែនាំឲ្យអ្នកជំនាញគឺថា គាត់មិនត្រូវយកឯកសារទាំងអស់ ឬក៏ឯកសារត្រៀមរៀប

ចំមកទាំងអស់ទេ ហើយឥឡូវនេះបើយើងស្នើឲ្យគាត់ធ្វើដូច្នោះ ដូចជា យើងធាក់ថយឲ្យយកគាត់យកអ្វីទាំងអស់មកផ្ទៀងផ្ទាត់ឡើងវិញ។ អ៊ីចឹងហើយ យើងសួរត្រឹមគាត់ថា តើប្រភពណាមួយដែលគាត់យោងទៅរក? តើអ្វីជាចំណេះដឹងរបស់គាត់មុនអានដីកាដំណោះស្រាយនោះដូចម្តេច? ប៉ុន្តែបើធ្វើតាមសំណើរបស់មេធាវីការពារនោះ យើងមិនអាចធ្វើទៅបានទេ ដើម្បីឲ្យអ្នកជំនាញគាត់ធ្វើការផ្ទៀងផ្ទាត់សិក្សាវិភាគឡើងវិញ គឺថាជាការងារធំធេងណាស់។

[១៥:៤៥:៣៦]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមអនុញ្ញាតឆ្លើយតបដោយសង្ខេប។ ថាតើយើងអាចតទល់នឹងគាត់ដូចម្តេចបាន បើសិនបើយើងមិនដឹងថា គាត់យោងទៅរកឯកសារណាមួយណានោះ? ខ្ញុំគិតថា លោកស្រីចៅក្រម ខាតវ៉ាយថ៍ បានសម្រេចរួចហើយ ហើយយើងក៏គោរពតាមហ្នឹង ហើយយើងត្រូវដឹងថា តើចំណុចណាមួយក្នុងដីកាដំណោះស្រាយដែល -- តើលេខយោងមួយណាដែលគាត់យោង ដែលធ្វើឲ្យយើងធ្វើការពិនិត្យផ្ទៀងផ្ទាត់ឲ្យបានត្រឹមត្រូវ? បើគាត់ត្រឹមតែនិយាយថា ដីកាដំណោះស្រាយ គឺមិនមានប្រយោជន៍សម្រាប់យើង គឺថា ហើយក៏វាមិនមានអ្វីភាពចាំបាច់ថា ឲ្យសហព្រះរាជអាជ្ញាទៅរើ -- ឲ្យយើងទៅរកម្ជុលនៅក្នុងសមុទ្រនោះរកមិនឃើញទេ ពីព្រោះវាធំធេងណាស់។

**លោក ហ្សាស្តើ ប៉ោ៖**

ឆ្លើយតបទៅនឹងចំណុចដែលលើកខាងដើមនេះ គឺថាយើងត្រូវតែមានលទ្ធភាព ដើម្បីពិនិត្យផ្ទៀងផ្ទាត់អំពីចម្លើយរបស់សាក្សីរូបនេះ។ ម្តងទៀត គឺថាគាត់បានយោងទៅដីកាដំណោះស្រាយ តើដីកាមួយណា? តើគាត់ត្រឡប់ទៅឯកសារប្រភព ឬក៏ឯកសារទាំងអស់នៅក្នុងដីកាដំណោះស្រាយ ឬក៏ដីកាដំណោះស្រាយឯកឯងនោះ? អ៊ីចឹងហើយ ខ្ញុំគិតថា លោក ដេវីដ ឆេនដ័ល័រ គាត់អាចឆ្លើយនឹងសំណួរនេះបាន។ បាទ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៨:០១]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ សូមជម្រាបជូនភាគីថាអ៊ីចេះ ដើម្បីដោះស្រាយបញ្ហានេះឲ្យបានទៅមុខនោះគឺសូមជម្រាបជូនទៅអ្នកជំនាញថា ប្រសិនបើអ្នកជំនាញអាចបញ្ជាក់បាននូវឯកសារដែលពាក់ព័ន្ធហ្នឹង គឺ

ក៏ឆ្លើយទៅ ហើយបើមិនបានទេ លទ្ធភាពនេះគឺ ភាគីការពារក្តីមានឱកាសកត់ត្រានូវបញ្ហាទាំងអស់នុ៎ង ហើយនិងសួរបញ្ជាក់លើបញ្ហានេះជាក្រោយ នៅពេលដែលដល់វេនខ្លួនមានសិទ្ធិ ឬក៏ឱកាសក្នុងការដែលខ្លួនតាំងសំណួរសួរ។

ហើយបញ្ហាមួយទៀត ខ្ញុំ យើងខ្ញុំគិតថា ប្រសិនបើការផ្តល់សក្ខីកម្មហ្នឹង ដោយមិនមានមូលដ្ឋានពេញលេញ ឬក៏មានការខ្វះចន្លោះនោះ គឺកិច្ចដំណើរការចុងក្រោយ គឺនៅមានឱកាសបង្ហាញ លាតត្រដាងនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលសម្រាប់សំណុំរឿងទាំងមូល ឬក៏អាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ នៅពេលដែលបញ្ចប់នូវកិច្ចពិភាក្សាដេញដោលចំពោះសាក្សីរូបនេះ ពីព្រោះបញ្ហាវាទូលំទូលាយពេកនៅក្នុងក្របខ័ណ្ឌអង្គហេតុសំណុំរឿង០០២។ ហើយវិសាលភាពនៃសំណុំរឿងនេះ ហើយនិងពាក់ព័ន្ធទៅនឹងស្នាដៃដែលលោកសាស្ត្រាចារ្យបានសិក្សាស្រាវជ្រាវ វាមានលក្ខណៈទូលំទូលាយ ប្រសិនបើរង់ចាំដល់ពេលថា តាំងសំណួរជាក់លាក់នោះ ទំនងជាត្រូវការពេលវេលាច្រើនណាស់ក្នុងការសួរដេញដោលរូបនេះ អ៎! អ្នកជំនាញរូបនេះនោះ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរ!

[១៥:៤៩:៥៦]

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។ ដូចដែលបានជម្រាបនោះគឺថា ខ្ញុំនឹងព្យាយាមដើម្បីធានាសួរដើម្បីឱ្យគាត់អាចនឹងឆ្លើយបានមតិយោបល់ដ៏ត្រឹមត្រូវរបស់គាត់ ជាពិសេសនៅក្នុងឯកសារដែលគាត់បានសិក្សាស្រាវជ្រាវ និងគាត់បានអាន។

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** លោកសាស្ត្រាចារ្យ ឆេនដ័ល័រ ដោយសារនៅពេលខ្លីទៀតទេ ខ្ញុំសូមសួរលោកទៅលើប្រធានបទផ្សេងទៀត គឺថាជាសំណួរទូទៅ ដែលថាយើងនឹងត្រូវអនុវត្តបន្តថ្ងៃនេះ និងថ្ងៃស្អែក។ ខ្ញុំចង់តាមដានចំណុចសំខាន់មួយចំនួនអំពីការអភិវឌ្ឍន៍របស់បក្សកុម្មុយនីស្តកម្ពុជា ដែលថាតើមុនសម័យឆ្នាំ១៩៧៥ តើបង្កើត ហើយវាមានការវិវឌ្ឍន៍ដូចម្តេចចំពោះបក្សនេះ។ បន្ទាប់មក យើងនឹងចូលទៅដល់ការពិភាក្សាអំពីកម្ពុជាប្រជាធិបតេយ្យ ជាស្ថាប័នមួយ ហើយយើងចាត់ទុកចំណុចសំខាន់មួយចំនួនទាក់ទងទៅនឹងការជម្លៀសដោយបង្ខំ និយាយពីការចោទប្រកាន់ ហើយនិងការបង្កើតសហករណ៍សមូហភាវូបនីយកម្ម ការកម្ទេចខ្មាំងជាដើម ហើយនិងប្រព័ន្ធទំនាក់ទំនងនៅក្នុងរបបនោះ។ នេះជា

របៀបវារៈ ហើយខ្ញុំនឹងព្យាយាមសួរលោកទៅតាមលំដាប់លំដោយនីមួយៗ។

[១៥:៥១:៣០]

បាទ សូមលោករង់ចាំមីក្រូហ្វូនបើកភ្លើងសិនបាទ។

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** នៅក្នុងគំនិតមួយដែលថាខ្ញុំមិនបានឃើញសំណួរដែលបានសួរថ្ងៃនេះទេ។ ដូច្នេះខ្ញុំមិនបានត្រៀមរៀបចំ។ ខ្ញុំ សំណួរទាំងអស់នេះបាន បើសិនជាបញ្ជូនឲ្យខ្ញុំៗអាចត្រៀមរៀបចំ ដូចជាជាអ្នកជំនាញ ប៉ុន្តែអាចនឹងឆ្លើយត្រឹម ប៉ុន្តែសំណួរ តើលោកបានដឹង តើលោកដឹងទេ អានកំណត់ហេតុនោះទេ? សៀវភៅ ខ្ញុំមិនអាចបើកភ្លាមៗដើម្បីរកទំព័រ និងឆ្លើយភ្លាមបាន បើខ្ញុំបានអាន គឺថាអានប្រភពច្រើនណាស់ ដែលថា -- ប៉ុន្តែខ្ញុំមិនអាចយោងថា ជាក់លាក់បានទេ ប៉ុន្តែនៅក្នុងសៀវភៅនេះ។ ដូច្នេះគំនិតខ្ញុំអាចដឹងថា អាចធ្វើឲ្យការគិតគូរ ឬប្តូរនូវយោបល់របស់ខ្ញុំ ផ្អែកទៅលើការស្រាវជ្រាវរបស់ខ្ញុំ។ ជាញឹកញាប់ខ្ញុំអាចនិយាយគឺថាត្រឹមត្រូវ ខ្ញុំមិនបានសរសេរបែបនេះទេ ប៉ុន្តែខ្ញុំបានអានឃើញបែបនេះ។ ហើយបើសុំឲ្យខ្ញុំទៅយោងទៅជាក់លាក់ដោយមានការត្រៀមរាមនេះ ដែលសួរមកខ្ញុំនេះ ខ្ញុំមិនអាចសួរ -- អំមិនអាចឆ្លើយបានទេ។ ហើយបើសិនជាថា លេខយោង៦០ អំ! ៨៩ ទំព័រ៣០០ ជាដើម គឺថាមិនអាចឲ្យខ្ញុំឆ្លើយអ៊ីចឹងទេ វាអាចសមស្រប ប៉ុន្តែជាការទាមទារដែលខ្ញុំមិនអាចឆ្លើយបានទេ។ បាទ សូមទោស។

[១៥:៥៣:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ដេវីដ ឆេនដ័ល័រ សូមលោកអនុវត្តនូវវិធីសាស្ត្រនៃការឆ្លើយតបដែលបានបញ្ជាក់គ្នារួចហើយ គឺចម្លើយសំណួរឯណាវែងអន្លាយ ដែលលោកស្តាប់មិនយល់ គឺប្រាប់ថាមិនអាចឆ្លើយបានទេ។ សំណួរឯណាដែលលោកមិនដឹង មិនមានលទ្ធភាពឆ្លើយ លោកថាមិនអាចឆ្លើយបានទេនេះជាចម្លើយខ្លី ហើយចប់ ហើយនិងឲ្យលោក ឲ្យភាគីដែលពាក់ព័ន្ធហ្នឹងបន្តសំណួរទៀត។ ចៀសវាងលោកមិនដឹងហើយ ហើយលោកនៅតែបន្តការធ្វើអត្ថាធិប្បាយនៅក្នុងកម្រិតពន្យល់ពីភាពមិនដឹងរបស់លោក។ បើសិនជាលោកថាឆ្លើយមិនដឹង ឬក៏មិនអាចឆ្លើយតបបាន គឺចប់ហើយ បញ្ហាសំណួរហ្នឹងហើយតទៅសំណួរផ្សេងទៀត ហើយសំណួរនេះដដែល អង្គជំនុំជម្រះនឹងខិតខំកត់ត្រាឲ្យបាន ហើយនិងគ្រប់គ្រងឲ្យបានក្នុងការតាំងសំណួរដដែលនេះ គឺមិនឲ្យសួរ មិនឲ្យលោកឆ្លើយទៀតទេ។

សូមអញ្ជើញលោក ម៉ែខល កាណាវាស!

[១៥:៥៤:១៨]

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន ដើម្បីឲ្យប្រាកដថាកំណត់ត្រានោះ គឺថាបានច្បាស់ហើយ ដោយប្រមើលឃើញស្ថានភាពនេះហើយ យើងមានបទពិសោធអំពីអ្នកជំនាញកាលពីមុននៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ យើងបានដាក់ជូនឯកសារមួយទៅអង្គជំនុំជម្រះនោះដែរ។ យើងស្នើថាសាក្សី ឬអ្នកជំនាញត្រូវតែតាមដានព័ត៌មានទាំងអស់ដែលពេលគេពិនិត្យមុននឹងមកឆ្លើយ ហើយយើងបានផ្តល់គំរូជាមួយនឹងសំណើនៅថ្ងៃទី១១ មិថុនា ឆ្នាំ២០១២ នេះ តម្រូវការដែលយើងចង់ឲ្យបាន មានតម្លាភាព។

[១៥:៥៥:០០]

សហព្រះរាជអាជ្ញាបានឆ្លើយថា ដូចជាបន្ថែមលក្ខខណ្ឌមួយទៀត ឬក៏គុណសម្បត្តិមួយទៀត គឺថាគេមិនត្រូវបន្ថែមអ្វីទេ ពិនិត្យ -- ហើយនៅថ្ងៃទី៣ កក្កដា ឆ្នាំ២០១២ ដូចដែលខ្ញុំយល់នោះ លិខិតនោះបានបញ្ជូនទៅសាស្ត្រាចារ្យ ឆេនដ័ល័រ តាមពិតបានសុំឲ្យគាត់ធ្វើបញ្ជីឯកសារមួយ។ គាត់បានពិនិត្យ ហើយគាត់បានត្រៀមរៀបចំ E172/24/4/3 នេះជាឯកសារ។ ខ្ញុំគ្រាន់តែលើកចំណុចនេះដោយសារដើម្បីកុំឲ្យសាក្សីនេះ យល់ថាមិនយុត្តិធម៌សម្រាប់គាត់ គឺថាគេបានជូនដំណឹងឲ្យគាត់ត្រៀមរៀបចំ គឺថាគាត់មានការងារដ៏សំខាន់ នោះវាមានសម្ពាធនៅក្នុងតុលាការ។ ប៉ុន្តែយើងបានធ្វើការងារនេះជាមុន ឲ្យគាត់បានត្រៀមរៀបចំ ឲ្យគាត់បានដឹង ដើម្បីឲ្យគាត់ចុចយកថាលេខយោងមួយណា ៤៨ ឬក៏ឯកសារណាមួយ ដើម្បីឲ្យយើងពិនិត្យមើលឡើងវិញ ថាតើពិតអ៊ីចឹងដែរឬទេ ដែលអ្នកជំនាញឆ្លើយនោះ គឺត្រឹមត្រូវ ឬក៏មានឯកសារគាំទ្រនូវចម្លើយរបស់គាត់។ នេះជាចំណុចដែលខ្ញុំលើកចំណុចនេះ ហើយខ្ញុំបានប្រុងប្រយ័ត្នធ្វើការងាររបស់នេះ។ សូមអភ័យទោសដែលលើកឡើងពីចំណុចនេះ ហើយសហព្រះរាជអាជ្ញា ក៏បានគាំទ្រពីជំហរនេះដែរ ថាយើងបានធ្វើអ៊ីចឹង ដើម្បីឲ្យអ្នកជំនាញបានត្រៀមរៀបចំ។

[១៥:៥៦:៣៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

ដើម្បីបញ្ជាក់ ខ្ញុំបានយោងទៅរកចំណុចនេះខាងដើមទេ ប៉ុន្តែយើងមិនស្នើឲ្យគាត់យកឯកសារទាំងអស់មកជាមួយគាត់ទេ ចំពោះអ្នកជំនាញនោះ។ ប៉ុន្តែយើងស្នើសុំឲ្យគាត់ធ្វើបញ្ជីដែលទាក់ទង

ហើយយើងអាចនឹងពិនិត្យមើលប្រហែលជា ថាតើលោកអ្នកជំនាញគាត់បានទទួលការឆ្លើយសួរសុំហ្នឹងដែរឬទេបាទ?

**លោក ដេវីដ ឆេនដ៍ល័រ៖**

បាទ ខ្ញុំបានទទួលនូវសំណើហ្នឹង គឺថាគឺ១០ថ្ងៃមុន ខ្ញុំមកនេះ ខ្ញុំបានអាន ប៉ុន្តែខ្ញុំមិនបានត្រៀមបញ្ជីនោះទេ។ ប៉ុន្តែខ្ញុំបានមើលដោយសង្ខេបៗ នូវចម្លើយសារភាពដែលបញ្ជូនឲ្យខ្ញុំ ហើយមានឯកសារមួយចំនួន ខ្ញុំយល់ថា ខ្ញុំបានអានដីកាដំណោះស្រាយរឿងក្តី០០២ មិនមែនដីកាដំណោះស្រាយរឿងក្តី ឌុច ទេ។ ចំណុចនេះ មានសារប្រយោជន៍សម្រាប់ខ្ញុំ ដើម្បីពិនិត្យមើលថាតើភាគីនឹងសួរដូចម្តេច? នេះហើយជាការងាររបស់ខ្ញុំ ដែលខ្ញុំបានមកពីរថ្ងៃមកហើយ ហើយខ្ញុំបានអាន។ ឥឡូវនេះ បញ្ហាដែលសេសសល់ ខ្ញុំនឹងត្រឡប់ទៅវិញ ខ្ញុំទៅមើលឯកសារបឋម គឺថាអាចឯកសារដែលគាំទ្រសៀវភៅទាំងបីរបស់ខ្ញុំនោះ ខ្ញុំនឹងអានឡើងវិញ។ នៅពេលដែលសំណួរចោទសួរមកនោះ គឺថាៗចេញមកពីគ្រប់ទិសតំបន់ គឺថាដែលលោករំពឹងឲ្យខ្ញុំឆ្លើយឲ្យចំនោះ គឺថាខ្ញុំពិបាកនឹងឆ្លើយ បើលោកបញ្ជូនសំណួរនេះមកឲ្យខ្ញុំជាមុន ខ្ញុំបានត្រៀមរៀបចំ ដោយថាមានប្រភព។ អានេះហើយ គឺជាគោលការណ៍វិជ្ជាជីវៈ បើថាសួរភ្លាម ឲ្យឆ្លើយភ្លាមនោះ មិនបានត្រៀមមុនអ៊ីចឹង អាហ្នឹងគឺថាពិបាក ខ្ញុំឆ្លើយមិនរួច។ បាទ គឺថាខ្ញុំសូមទោស ដែលយើងស្ថិតក្នុងស្ថានភាពនេះ។

[១៥:៥៨:៣៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

ពិតហើយ គឺថាមធ្យោបាយគឺថាការសួរដេញដោល គឺផ្តោតទៅលើតែឯកសារ ហើយឯកសារហ្នឹង គឺជាសៀវភៅរបស់លោក ដេវីដ ឆេនដ៍ល័រ គឺឯកសារថ្មីៗ ឬក៏ឯកសារដែលនិយាយអំពីកម្ពុជាប្រជាធិបតេយ្យ។ ហើយយើងនឹងឲ្យសួរគាត់ ដើម្បីឲ្យគាត់ឆ្លើយអ្វីដែលមាននៅក្នុងឯកសារទាំងនោះហើងនិងអាចពន្យល់បន្ថែម។ ហើយយើងនឹងត្រឡប់ទៅនឹងបញ្ហាទាំងនោះ នៅថ្ងៃស្អែកនោះបាទ។

**លោក ដេវីដ ឆេនដ៍ល័រ៖**

ខ្ញុំនឹងនិយាយពីអ្វីដែលខ្ញុំបានដឹង ហើយខ្ញុំមិននិយាយពីអ្វីដែលខ្ញុំមិនដឹងនោះទេ ជាការពិត។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។

[១៥:៥៩:៣១]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញ ឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រាកហើយ សម្រាប់កិច្ចដំណើរការសវនាការថ្ងៃនេះ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តទៅធ្វើការនៅថ្ងៃស្អែក គឺថ្ងៃព្រហស្បតិ៍ ទី១៩ ខែកក្កដា ឆ្នាំ២០១២ ដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ ហើយសវនាការនៅថ្ងៃស្អែកនេះ ដែលនឹងបន្តធ្វើដោយការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ ដេវីដ ឆេនឌ៍ល័រ ដោយតំណាងសហព្រះរាជអាជ្ញា ហើយសូមភាគី និងសាធារណជនជ្រាប។ ហើយលោកសាស្ត្រាចារ្យ ដេវីដ ឆេនឌ៍ល័រ ការស្ដាប់សក្ខីកម្មរបស់លោកជាអ្នកជំនាញនៅមិនទាន់ចប់នៅឡើយទេ។ អង្គសវនាការត្រូវបន្តធ្វើនៅថ្ងៃស្អែកទៀត ដូច្នេះអង្គជំនុំជម្រះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការបញ្ជូនអ្នកជំនាញវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់សម្រាក ឬគាត់ស្នាក់នៅ ហើយនិងឲ្យនាំគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។

មានការអីទៅ?

[១៦:០០:៤៥]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខាងមេធាវីអន្តរជាតិ ខាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីងាយស្រួលនៅក្នុងការចាត់ចែងការងាររបស់គាត់ គាត់ចង់ស្នើសុំលោកប្រធានជួយបញ្ជាក់ថា តើនៅថ្ងៃសុក្រសប្ដាហ៍នេះយើងនឹងមានសវនាការដែរឬទេ? ដោយសារថា មានសំណើមួយរបស់ខាងមេធាវីអន្តរជាតិរបស់លោក អៀង សារី សុំមិនឲ្យមានសវនាការថ្ងៃសុក្រនេះ។ អ៊ីចឹងយើងខ្ញុំ ចង់បានព័ត៌មាននេះ។

សូមអរគុណលោកប្រធាន។

[១៦:០១:១៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០១:៥២]

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅសំណើសុំនេះ? ហើយលោកមេធាវីអន្តរជាតិការពារក្ដីលោក អៀង សារី អង្គជំនុំ

ជម្រះមិនទាន់បានទទួលព័ត៌មានអ្វីពីការសំណើសុំរបស់លោកពាក់ព័ន្ធទៅនឹងថា ដំណើរការសវនាការ ឬមិនធ្វើសវនាការនៅថ្ងៃសុក្រនោះទេ។ តាមធម្មតានៅថ្ងៃសុក្រ យើងបានឯកភាពព្រមព្រៀងគ្នារួច ហើយនៅក្នុងកិច្ចដំណើរការសវនាការយើងមិនធ្វើទេ។ លើកលែងតែករណីពិសេសមួយចំនួន ដែល តម្រូវ ដូចជាការបញ្ចប់នូវការស្តាប់សក្ខីសាក្សីណាមួយដើម្បីឱកាស ផ្តល់ឱកាសឲ្យគាត់បានវិលត្រឡប់ ទៅលំនៅដ្ឋានវិញ ឬករណីខ្លះដូចករណីនៃកិច្ចដំណើរស្តាប់អ្នកជំនាញរូបនេះ គឺយើងគ្រោងធ្វើចាប់ ពីថ្ងៃចន្ទ ទី១៦។ ប៉ុន្តែពីរថ្ងៃកន្លងទៅនេះ ដោយមានបញ្ហាសុខភាពតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ មួយរូប គឺលោកមិនមានឱកាស លទ្ធភាពក្នុងការចូលមក -- ចូលរួមនៅក្នុងកិច្ចដំណើរការសវនាការ បានដោយគាត់ទទួលបន្ទុកនៅក្នុងការរៀបចំការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ អ៊ីចឹងហើយ បានជាអាក់ខានមិនបានដំណើរការពីរថ្ងៃកន្លងមកហើយ។ ហើយជាធម្មតានៅក្នុងមួយសប្តាហ៍យើងធ្វើ បួនថ្ងៃ។ បួនថ្ងៃនេះ កន្លងមកយើងធ្វើជាប់ៗ បានន័យថា ថ្ងៃចន្ទ អង្គារ ថ្ងៃពុធ និងថ្ងៃព្រហស្បតិ៍។

[១៦:០៣:០៨]

ហើយនាពេលខាងមុខ អង្គជំនុំជម្រះនឹង -- នៅក្នុងកិច្ចប្រជុំពិភាក្សារៀបចំកិច្ចដំណើរការ សវនាការគ្រោងនឹងមានការផ្លាស់ប្តូរបន្តិចបន្តួចនូវពេលវេលាសម្រាប់សវនាការនេះ។ បានន័យថាបួនថ្ងៃ ដដែល គ្រាន់តែឲ្យមានចន្លោះនៅក្នុងកណ្តាលពេលណាមួយ នៃកណ្តាលសប្តាហ៍ ដើម្បីឲ្យស្ថានភាព វាធូរស្រាល ហើយមានឱកាសក្នុងការសិក្សាស្វែងយល់ ស្រាវជ្រាវឯកសារដែលពាក់ព័ន្ធនឹងកិច្ចដំណើរ ការ ដើម្បីឲ្យដំណើរការប្រព្រឹត្តទៅបានមានប្រសិទ្ធភាពនិងឆាប់រហ័ស។ ហើយព័ត៌មានអំម្បាញ់មិញ នេះ មានហេតុផលយ៉ាងម៉េចទៅ? ឬក៏មិនមានបញ្ហាអីទេ? ជាការគិត អង្គជំនុំជម្រះមានបំណងនៅ ក្នុងការស្តាប់សក្ខីកម្មសាក្សី ដេវីដ ឆេនដ័ល័រ នៅថ្ងៃសុក្រទៀត ដោយមូលហេតុដូចខ្ញុំបានជម្រាបអ៊ីចឹង គឺយើងគ្រោងធ្វើបួនថ្ងៃនៅក្នុងសប្តាហ៍នេះ។ ប៉ុន្តែដោយសារស្ថានភាពមិនអំណោយផលឲ្យយើងធ្វើតាម កាលវិភាគដែលបានគ្រោងទុក។ អ៊ីចឹងហើយបានជាយើងខាតពីរថ្ងៃកន្លងទៅយើងមិនបានធ្វើ។

[១៦:០៤:០៩]

អ៊ីចឹងប្រសិនបើយើងធ្វើថ្ងៃសុក្រទៀត បានន័យថា ក្នុងសប្តាហ៍នេះយើងធ្វើបានតែបីថ្ងៃទេ ហើយកាលវិភាគ និងការអញ្ជើញសាក្សីដែលពាក់ព័ន្ធផ្សេងទៀតទាំងលោក ដេវីដ ឆេនដ័ល័រ ផងតាម ផែនការគឺខុស។ បានន័យថា យើងមានរៀបចំខុសក្នុងការផ្តល់ដំណឹងទៅភាគី និងសាធារណជនកន្លង មក។ យើងត្រូវប្រឹងប្រែងកែសម្រួលនូវកាលវិភាគនេះឲ្យបានល្អប្រសើរ និងមានប្រសិទ្ធភាព។

**លោក ម៉ៃខល កាណាវ៉ាស៖**

ខ្ញុំសូមជម្រាបជូនលោកប្រធានថា យើងគោរពនីតិវិធីដូចគ្នា ដូចដែលសហព្រះរាជអាជ្ញាបានជម្រាបអង្គជំនុំជម្រះអំពីការពន្យារពេល។ ឥឡូវនេះ ខ្ញុំបានឮជាដំបូង គឺថាអង្គជំនុំជម្រះមិនបានទទួលដំណឹងទេ ខ្ញុំឃើញថាមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះ ស៊ូហ្សាន ឡេម នោះ គឺថាមិនបានបញ្ជូនការឆ្លើយតបរបស់យើងទៅអង្គជំនុំជម្រះទេ។ ខ្ញុំសង្ស័យថា នេះជាករណីនោះហើយ ប៉ុន្តែអាចជាការខ្វះចន្លោះ។ យើងបានកត់សម្គាល់ថា អ៊ីម៉ែល លោក ស្មីត បានបញ្ជូនទៅ ស៊ូហ្សាន ឡេម ជូនដំណឹងអំពីស្ថានភាព។ យើងបានត្រៀមរៀបចំ ដើម្បីចាប់ផ្តើមថ្ងៃចន្ទ ហើយយើងបានពិភាក្សាជាមួយភាគីថាតើគេបានយល់ស្រប ឬមិនយល់ស្រប។

អង្គជំនុំជម្រះ តាមឆន្ទៈរបស់ខ្លួន គឺថា ខ្លួនបានពន្យារពេលពីរថ្ងៃជូនសហព្រះរាជអាជ្ញា។ យើងយល់ថាសមស្របទាក់ទងទៅនឹងកាលៈទេសៈ។ យើងបានរៀបចំសម្រាប់សាក្សី គឺសាក្សីអ្នកជំនាញដែលប្រើពេលមួយសប្តាហ៍ -- ពីរសប្តាហ៍ដើម្បីត្រៀមរៀបចំ។ ហើយៗស្ទើរតែមិនអាចធ្វើឲ្យមេធាវីទីមួយ។ ទីពីរ ដើម្បីមកជំនួសមេធាវីដែលបានរៀបចំហើយនោះ។

[១៦:០៦:០៨]

ផ្អែកទៅលើចំណុចនេះ គឺការជំនុំជម្រះពីរថ្ងៃ ដែលពន្យារពេលពីរថ្ងៃនេះ លទ្ធភាពក្នុងការបើកសវនាការនៅថ្ងៃសុក្រនោះ គឺថាយើងបានទាក់ទងភ្លាមទៅនៅតាមរយៈ ស៊ូហ្សាន ឡេម ទៅអង្គជំនុំជម្រះសាលាដំបូង ដោយជូនដំណឹងទៅលោក លោកស្រីចៅក្រមថា គឺថាមិនល្អសម្រាប់យើងទេ គឺថាយើងមិនបានបង្កឲ្យមានហេតុការណ៍នេះទេ គឺជាករណីប្រធានស័ក្តិ។ ប៉ុន្តែទោះជាយ៉ាងហ្នឹងក្តី ដោយសារតែកាលវិភាគដែលកំណត់ហើយ គឺថាពីថ្ងៃចន្ទ ដល់ថ្ងៃព្រហស្បត្តិ៍នោះ ខ្ញុំបានធ្វើការបណ្តុះបណ្តាលមួយដែលខ្ញុំបានសន្យាសម្រាប់មេធាវីអន្តរជាតិផ្សេងទៀត ដែលឲ្យចូលរួមពីរថ្ងៃ សម្រាប់ថ្ងៃសុក្រហ្នឹង។ ដោយសារហេតុហ្នឹង ដោយសារខ្ញុំមានការរៀបចំរួចស្រេចហើយ ធ្វើឲ្យខ្ញុំអាច -- មិនអាចទៅកែប្រែកាលវិភាគដែលខ្ញុំបានឯកភាពនោះទេ។ ដូច្នេះហើយ ដោយមានការឆ្លើយឆ្លងអ៊ីម៉ែលនេះរួមមក យើងខ្ញុំបានរង់ចាំចាប់ពីនោះមក រង់ចាំការសម្រេច។ ប៉ុន្តែខ្ញុំមានច្បាប់ចម្លងនៃអ៊ីម៉ែល ខ្ញុំអាចជូនទៅអង្គជំនុំជម្រះ។

នៅក្នុងអតីតកាល យើងរងការរិះគន់ គឺថាមិនបានជូនព័ត៌មានគ្រប់គ្រាន់ដែលធ្វើឲ្យគេយល់ថាយើងមានការទាក់ទងដោយមិនឲ្យភាគីផ្សេងទៀតដឹង។ ដូច្នេះយើងចង់ជូនដំណឹងឲ្យបានគ្រប់គ្រាន់។

ក្នុងករណីនេះ វាមិនអាចធ្វើទៅបានទេ ដើម្បីឲ្យខ្ញុំចូលរួមសវនាការថ្ងៃសុក្រ។ ហើយខ្ញុំមិន បើសិនជាអង្គជំនុំជម្រះសម្រេចថា បើកសវនាការ ខ្ញុំមិនអាចចូលរួមបានទេ។ ព្រោះខ្ញុំសន្យាការបណ្ដុះបណ្ដាលខាងណោះរួចទៅហើយ ហើយខ្ញុំមានប្រតិចារឹក។

[១៦:០៨:០១]

ប៉ុន្តែខ្ញុំចង់ជម្រាបចំណុចមួយ នៅពេលសហព្រះរាជអាជ្ញាទទួលបានការឯកភាពថាពន្យារពេល ប៉ុន្តែអង្គជំនុំជម្រះមិនយល់ស្របទៅតាមសំណួរ -- សំណើរបស់យើង។ នេះហើយជាចំណុចមួយ គឺហេតុការណ៍នេះបណ្ដាលដោយសហព្រះរាជអាជ្ញាទេ មិនដោយមេធាវីការពារក្ដីទេដែលយឺតពីរថ្ងៃ។ ខ្ញុំគោរពទៅតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះដែលថាមាន សេចក្ដីត្រូវការស្ដាប់សាក្សីរូបនេះ ដែលត្រូវមើលឯកសារទាំងអស់នេះ គាត់នឹងមកក្នុងសម្ភាធ -- រងសម្ពាធជាច្រើនដោយសារមានការសួរដេញដោលពីភាគីខាងយើងខ្ញុំ។ ហើយគាត់ក៏បានទទួលមួយថ្ងៃទៀត ដើម្បីការរៀបចំរបស់គាត់ ដែលថាគាត់មិនបានត្រៀមរៀបចំពីមុនដោយមិនរំពឹងថា នឹងបានទទួលសំណួរលំបាកៗនេះ។

ហើយយើងខ្ញុំស្នើអង្គជំនុំជម្រះថា សុំមិនបាច់បើកសវនាការនៅថ្ងៃសុក្រទេ ដោយសារផ្អែកលើការគោលការណ៍សមភាព យុត្តិធម៌ គឺថាយើងមិនបាត់បង់ពេលវេលាទេ។ ពីព្រោះថាយើងមិនអាចកែបានទេ បើសិនជាសម្រេចថាត្រូវតែបើកថ្ងៃសុក្រ គួរតែឆ្លើយថា សហព្រះរាជអាជ្ញាមិនអាចពន្យារពេលពីរថ្ងៃទេ។ នេះហើយដើម្បីជាការឆ្លើយតបទៅនឹងគោលការណ៍យុត្តិធម៌ ស្មើភាព គឺអង្គជំនុំជម្រះមិនគប្បីបើកសវនាការនៅថ្ងៃសុក្រនេះទេបាទ។

[១៦:០៩:៣២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន!

**លោក អាកទួរ វ៉ែកកែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំនិយាយដោយខ្លីទេ គ្រាន់ជាការកត់សម្គាល់ពីព្រោះថាលោកចៅក្រមបានមានរយៈពេលបួនថ្ងៃសម្រាប់ការផ្ដល់សក្ខីកម្មរបស់លោក ដេវីដ ឆេនដ័ល័រ ក៏ប៉ុន្តែមាន -- ក្នុងផ្ដោះប្ដូរអ៊ីម៉ែលជាមួយនឹងអ្នកស្រី ស៊ូហ្សាន ឡេម គឺនិយាយថារយៈពេលប្រាំថ្ងៃទេ។ អ៊ីចឹងខ្ញុំសូមបញ្ជាក់កន្លែងនេះ។ នេះគឺជាអ៊ីម៉ែលនៅថ្ងៃទី៧ ខែ៦ ដែលផ្ញើជូនទៅភាគីទាំងអស់។ ជូនដំណឹងដល់ភាគីទាំងអស់។ ខ្ញុំគ្រាន់តែចង់រំឮកថា ត្រូវការរយៈពេលជាអតិបរិមាប្រាំថ្ងៃ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

[១៦:១០:៥៣]

**លោក ហ្សាស្គើ ប៉ោះ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងនិយាយដោយខ្លីទេ ខ្ញុំគ្រាំទ្រការលើកឡើងរបស់មេធាវី កាណាវាស ដូចកាណាវាស បានបញ្ជាក់អ៊ីចឹង នៅពេលដែលសហព្រះរាជអាជ្ញាស្នើសុំការពន្យារសវនាការពីរថ្ងៃ គ្មានការជំទាស់។ យើងក៏មិនការជំទាស់ដែរ ដោយសារយើងគិតថាវាជាហេតុផលសមរម្យពិចារណាទៅលើកាលៈទេសៈដែលសហព្រះរាជអាជ្ញាបានលើកឡើង។ ដូចលោក កាណាវាស បានបញ្ជាក់ដូច្នោះ។ លោកមេធាវីបានស្នើសុំមិនឱ្យបើកសវនាការនៅក្នុងថ្ងៃសុក្រ ហើយយើងដឹងហើយនៅថ្ងៃនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកចំណុចនេះឡើង។ លោកមេធាវី កាណាវាស បានបញ្ជាក់ៗរួចមកហើយដែលថា គាត់មិនអាចមានលទ្ធភាពធ្វើការចូលរួមនៅក្នុងថ្ងៃសុក្រ។ ហើយដូច្នេះប្រសិនបើមិនអាចចូលរួមនោះទេគឺ វាមិនអាចឱ្យមានការតំណាងទៅលើសិទ្ធិរបស់លោក អៀង សារី។ ដូច្នេះហើយយើងចង់បានសេចក្តីសម្រេចមួយ ដែលវាមានលក្ខណៈយុត្តិធម៌ ហើយយើងគិតថាមិនគួរបើកសវនាការនៅថ្ងៃសុក្រនោះឡើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ដោយអង្គជំនុំជម្រះកត់សម្គាល់ឃើញបញ្ហានេះ ថានឹងអាចកើតមានឡើងនៅក្នុងដំណើរការសវនាការនេះ នឹងអាចលើកយកពីស្ថានភាពនៃការធ្វើឱ្យអាក់ខានពីរថ្ងៃដោយខាងតំណាងសហព្រះរាជអាជ្ញា។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះបានលើកបញ្ហានេះ ជម្រាបទៅភាគីយ៉ាងច្បាស់លាស់កាលពីព្រឹកមិញ អំពីការសោកស្តាយរបស់ខ្លួនចំពោះបញ្ហានេះកើតឡើង។ ហើយអង្គជំនុំជម្រះបានព្យាយាមក្នុងការប្រឹងប្រែងជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីរកសាក្សីផ្សេងទៀត ដែលទំនងជាមានលទ្ធភាពមកផ្តល់សក្ខីកម្មជំនួសពេលវេលាពីរថ្ងៃ ដែលមានបញ្ហាខាងសុខភាពរបស់តំណាងព្រះរាជអាជ្ញាទទួលបន្ទុក នៅក្នុងការតាំងសំណួរដេញដោលចំពោះអ្នកជំនាញរូបនេះដែលបានរៀបចំ និងចាត់តាំងរួចហើយនោះ មិនមានលទ្ធភាពអាចចូលរួមសវនាការបាន។

[១៦:១៣:០៣]

ហើយការធ្វើដូច្នេះ គឺអង្គជំនុំជម្រះសង្ឃឹមថាការកត់សម្គាល់នេះ គឺជាការបង្ហាញមួយថា បញ្ហា

នេះនឹងមិនអាចកើតមានឡើង ដោយយកហេតុផលនៃបញ្ហារបស់សហព្រះរាជអាជ្ញាហ្នឹង យកធ្វើជាមេរៀនសម្រាប់ភាគីផ្សេងៗទៀតយកធ្វើជា -- បង្កើតជាបញ្ហានេះបន្តបន្ទាប់ក្នុងអំឡុងពេលដំណើរការសវនាការរឿងក្តីនេះទេ។ នេះជាគោលបំណងនៃហេតុផលអង្គជំនុំជម្រះ បានលើកឡើងបញ្ហានេះកាលពីព្រឹកមិញដំបូងៗនៃដំណើរការសវនាការ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:១៤:០៦]

បាទ អរគុណណាស់នូវសំណើសុំសួរបញ្ជាក់នូវបញ្ហានេះ ហើយមានព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងបញ្ហានៃថាសំណួរថា តើអង្គជំនុំជម្រះធ្វើសវនាការនៅថ្ងៃសុក្រខាងមុខនេះដែរឬទេ? ហើយអង្គជំនុំជម្រះនឹងជម្រាបជូនភាគីពាក់ព័ន្ធ និងសាធារណជនជ្រាបនៅព្រឹកថ្ងៃស្អែក។

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ ហើយអង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនពួកគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនេះវិញ នៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក អៀង សារី នៅព្រឹកថ្ងៃស្អែកនេះ ទោះបីជាគាត់ស្នើសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ មុនពេលកិច្ចដំណើរការសវនាការចាប់ផ្តើមក៏ដោយ អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងត្រូវតែនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះដែរ។

ប្រសិនបើមានសំណើលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ របស់ អៀង សារី ដោយសុំនៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ជាលាយលក្ខណ៍អក្សរមកអង្គជំនុំជម្រះ ដូចសព្វដងនោះ អង្គជំនុំជម្រះនឹងពិនិត្យពិចារណាសម្រេចលើសំណើសុំរបស់គាត់នៅមុនពេលអង្គជំនុំជម្រះចាប់ផ្តើមដំណើរការសវនាការស្តាប់សក្ខីកម្មអ្នកជំនាញ។

[១៦:១៥:២៦]

ទន្ទឹមនឹងនេះអង្គជំនុំជម្រះកត់សម្គាល់ផងដែរថា តាមរបាយការណ៍របស់ក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដែលទទួលបន្ទុកពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ អៀង សារី ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ បានកត់សម្គាល់អំពីអាការៈរបស់ អៀង សារី នាពេលចេញរបាយការណ៍នេះ ចេញរបាយការណ៍នោះដូចនេះ៖ អៀង សារី មានអាការៈវិលមុខ ហេវហត់ពិសេសពេលឡើងជណ្តើរ និងពុំផ្តល់លទ្ធភាពឲ្យអង្គុយបានយូរ។ ហើយក៏បានផ្តល់អនុសាសន៍ដែរថា សូមប្រធានអង្គជំនុំ

ជម្រះមេត្តាអនុញ្ញាតផ្តល់លទ្ធភាពឲ្យជនជាប់ចោទ -- សវនាការពីចម្ងាយពីបន្ទប់ខាងក្រោមក្នុងរយៈពេលដប់ថ្ងៃបន្តទៀត ដោយគិតចាប់ពីថ្ងៃ១៣ ខែមិថុនា ឆ្នាំ២០១២ ដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១២។ ហើយបើគិតរហូតដល់ពេលនេះ គឺរយៈពេលនោះគឺបានកន្លង់ផុតទៅបួនសប្តាហ៍ហើយ។ នេះជាហេតុផលដែលតម្រូវឲ្យលោក អៀង សារី បង្ហាញខ្លួននៅក្នុងបន្ទប់សវនាការនៅព្រឹកថ្ងៃស្អែក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១៧ នាទី)*